ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Sep-2015, 08:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៣២៨**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

កញ្ញា រ៉ូប៊ីនី ក្រូហ្វត៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក ស្រ៊ា រតនៈ

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី គួច វលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ស្រ៊ា រតនៈ | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក សេង ស្រ៊ុន (2-TCW-880) | ខ្មែរ |
| លោក សំរិត មុយ (2-TCW-883) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សេង ស្រ៊ុន** (2-TCW-880)

សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី ....................ទំព័រ ៣

**ការសួរសំណួរទៅសាក្សី៖ លោក សំរិត មុយ** (2-TCW-883)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ១៣

សួរដោយលោក ស្រ៊ា រតនៈ ផ្ដើមពី ....................ទំព័រ ១៦

សួរដោយលោក វីល្លៀម ស្មីត ផ្ដើមពី....................ទំព័រ ៣០

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៥៦

សួរដោយលោក លីវ សុវណ្ណា ផ្ដើមពី ....................ទំព័រ ៦៩

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី....................ទំព័រ ៧១

សួរដោយលោក គង់ សំអុន ផ្ដើមពី ....................ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣៤]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី សេង ស៊្រុន បញ្ចប់ ហើយនិងផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-883។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិ នៅព្រឹកនេះ អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់ថ្ងៃនេះ គឺលោក សេង ស៊្រុន ។ លោកមានវត្តមានរួចហើយ នៅក្នុងបន្ទប់សវនាការនេះ។ នៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-883។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានជាប់ទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។

សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខលោកតាដំបងដែកកាលពីម្សិលមិញ។ សាក្សីមានមេធាវីប្រឹក្សា គឺលោក ម៉ម រិទ្ធា។

សូមអរគុណលោកប្រធាន។

[០៩:០៤:00]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះ សម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឱ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ដែលបានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ និងកាន់តែឈឺខ្លាំងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងបទបញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ក្នុងរយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ។ ហើយជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

[០៩:០៥:៥០]

**បន្តការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួលោក សេង ស៊្រុន! ខ្ញុំត្រឡប់មកសំណួរខ្ញុំវិញ។ កាលពីម្សិលមិញយើងបានឈប់ត្រឹមកម្លាំងប្រដាប់អាវុធដែលបានចូលរួមក្នុងការចាប់ខ្លួនជនជាតិចាម ហើយលោកក៏បានចូលរួមជួយចាប់ដែរ។ កាលពីម្សិលមិញលោកបានបញ្ជាក់ថា មនុស្សប្រាំបួននាក់នៅក្នុងក្រុមដាវវែងហ្នឹងមានវត្តមាននៅទៅនោះដែរ។ ហើយកាលពីម្សិលមិញលោករៀបរាប់ឈ្មោះបានប្រាំ ដែលលោកចាំថាជាសមាជិកដាវវែង គឺប្រាំនាក់។ ខ្ញុំចង់បញ្ជាក់លោកអំពីឈ្មោះទាំងអស់នេះ លោកថាឈ្មោះ ឡាវ ខួយ ដែលក្រោយមកក្លាយជាបងថ្លៃរបស់លោក។ អ៊ីចឹងខ្ញុំចង់ដឹងថាឈ្មោះហ្នឹង គាត់មានវត្តមានទេ នៅពេលចាប់ខ្លួនជនជាតិចាមនេះ?

**លោក សេង ស៊្រុន៖**

**ឆ៖** ខ្ញុំសូមជម្រាបលោកថា វត្តមានគាត់នៅពេលចាប់ខ្លួនហ្នឹង ខ្ញុំអត់បានឃើញគាត់ទេ។ បាទគាត់ ដូចខ្ញុំបានជម្រាបពីម្សិលមិញថាពួកដាវវែងហ្នឹងគេចែកគ្នាជាក្រុមដើម្បីគេចុះតាមភូមិមួយៗបាទ។ គេចែកកម្លាំងខ្លះទៅតាមខាងភូមិសំបួរមាស “ក” អ៊ីចឹងទៅ។ ខ្លះទៀតគេទៅខាងសាច់សូទៅ ហើយខ្លះគេនៅភូមិសំបួរមាស “ក” ហ្នឹង ព្រោះបងប្អូនប្រជាជនចាមហ្នឹងគាត់បានគេពង្រាយឲ្យនៅគ្រប់ភូមិ គេអត់ឲ្យនៅផ្តុំគ្នាទេ គេឲ្យមកលាយលំជាមួយបងប្អូនខ្មែរនៅតាមភូមិមួយៗ បាទ។

[០៩:០៧:៤៦]

**ស៖** ខ្ញុំនឹងសួរតាមរបៀបផ្សេងវិញ។ តើអ្នកណាខ្លះនៅក្នុងក្រុមដាវវែងហ្នឹង ដែលលោកបានឃើញចូលរួមនៅក្នុងការចាប់ខ្លួនជនជាតិចាមនៅថ្ងៃនោះៗ?

**ឆ៖** ក្រុមដាវវែងដែលខ្ញុំឃើញក្នុងការចូលរួមចាប់បងប្អូនចាមនៅក្នុងភូមិសំបួរមាស ក ហ្នឹង គឺខ្ញុំឃើញច្បាស់គឺឈ្មោះ តាយ គឹមហ៊ាន់ ហ្នឹងមួយ ហើយនិងប្រមាណនាក់ទៀតខ្ញុំអត់បានឃើញគេផ្ទាល់ទេ។ ក៏ប៉ុន្តែគេមកមុខខ្ញុំ ៗគឺគេឲ្យមកក្រោយទេ ដោយសារដូចខ្ញុំបានជម្រាបអ៊ីចឹង គឺការដែលខ្ញុំមកនេះគេអត់ប្រាប់ថា ឲ្យយើងមកធ្វើអី ក៏គេអត់មានប្រាប់ដែរ បាទ។ គឺយើងទើបនឹងដឹងនៅពេលគេចាប់បងប្អូនចាមមកឲ្យយើងមើលហ្នឹង បានដឹងថាគេចាប់ចាមហ្នុង។ ពីដំបូងមក យើងអត់បានសួរព័ត៌មានអីទាំងអស់។

**ស៖** បើក្រៅពី តាយ គឹម ប៊ាន់ ហ្នឹងតើលោកស្គាល់អ្នកណាខ្លះផ្សេងទៀតដែលមានវត្តមាននៅក្នុងពេលចាប់ខ្លួននោះ?

**ឆ៖** ក្នុងការចាប់ខ្លួនបងប្អូនចាមហ្នឹង វាពិបាកនឹងយើងមើលទៅពីណាៗខ្លះ ព្រោះថាពេលហ្នឹងវាអត់មានភ្លើងទេ គ្រាន់តែមានតែពន្លឺខែអីចឹងទៅ។ វាអត់មានភ្លើងអី យើងអាចឲ្យមើលមនុស្សច្បាស់ទេ។ បាទ ឃើញតែដូចស្រមោលៗអីចឹង ទាល់តែមកជិតបានយើងឃើញ។ ហើយខ្ញុំគេអត់ឲ្យទៅជិតផង គេគ្រាន់តែឲ្យឈរនឹងផ្លូវនេះ។ ដូច្នេះខ្ញុំអត់ស្គាល់ថាពីណាជាពីណាខ្លះទេ ប៉ុនថាខ្ញុំស្គាល់ច្បាស់តែ តាយ គឹម ប៊ាន់ ហ្នឹងមួយ ព្រោះគេជាអ្នកនាំបងប្អូនចាមនឹងយកមកផ្លូវដែលកន្លែងខ្ញុំឈរនៅរង់ចាំហ្នឹង។

[០៩:១០:១១]

**ស៖** នៅក្នុងចម្លើយរបស់លោកគឺឯកសារ E3/5252, ERN ជាភាសាបារាំង 00269892, ERN ជាភាសាអង់គ្លេស 00235517, ERNជាភាសាខ្មែរ 00235022។ លោកបានឆ្លើយដូចតទៅខ្ញុំសូមដកស្រង់៖ "ក្នុងពេលចាប់ខ្លួន ពួកដាវវែងហ្នឹងចែកគ្នាជាបីក្រុម។ មួយក្រុមមានគ្នាបួននាក់។ ក្រោយពីចាប់ចាមហើយ ពួកដាវវែងហ្នឹងទៅបាត់ទៅ ហើយទុកឲ្យយើងជាអ្នកនាំជនជាតិចាមដែលគេចាប់បានហ្នឹងទៅមន្ទីរសន្តិសុខនៅវត្តអូរត្រកួន។" សូមបញ្ចប់ការដកស្រង់។ តាមរយៈចម្លើយរបស់លោកនេះ យើងយល់ថាលោកបានឃើញពួកដាវវែងហ្នឹងចែកគ្នាជាបីក្រុម ប្រសិនបើលោកមិនអាចមើលឃើញមនុស្សច្បាស់ មិនស្គាល់មនុស្សផង លោកស្គាល់តែ តាយ គឹមប៊ាន់ ម៉េចបានជាលោកដឹងថាអ្នកទាំងអស់នោះជាក្រុមដាវវែង ហើយបែងចែកគ្នាជាបីក្រុមដើម្បីចាប់ជនជាតិចាមនោះ?

**ឆ៖** ខ្ញុំសូមជម្រាបលោកមេធាវីថា ពួកដាវវែងនេះ មិនមែនខ្ញុំមិនស្គាល់ទេ គឺខ្ញុំស្គាល់ទាំងអស់។ ក៏ប៉ុន្តែពេលថ្ងៃ បើយើងជួបគ្នា ខ្ញុំស្គាល់ តែដល់ពេលយប់ វាពិបាកថា អ្នកណាមួយជាអ្នកណាណាស់។ សូម្បីតែយើងនៅក្នុងផ្ទះមានកូនចៅនៅទាំងអស់គ្នាហ្នឹង បើសិនជាឆ្ងាយ ៥ម៉ែត្រទៅ ៦ម៉ែត្រ ពេលយប់ក៏យើងមិនអាចស្គាល់កូនយើងអាមួយណាដែរ។ អាហ្នឹងខ្ញុំគ្រាន់តែជម្រាបអីចឹង។ ប៉ុន្តែក្រុមដាវវែងដែលនៅក្នុងឃុំពាមជីកង គឺខ្ញុំស្គាល់ទាំងអស់បាទ។

[០៩:១២:១៨]

**ស៖** អីចឹងម៉េចបានជាលោកដឹងថា ក្រុមហ្នឹងជាក្រុមដាវវែង បើលោកមើលមិនស្គាល់អ្នកណាផងនោះ?

**ឆ៖** បានជាខ្ញុំស្គាល់ថាជាក្រុមដាវវែង ព្រោះថា ដូចពួកខ្ញុំ ហើយពួកប្រជាជនធម្មតាគឺគេអត់

មានកាន់អាវុធអីទេ។ បាទ មានតែពួកដាវវែងនេះទេ គេស្ពាយដងដាក់ទៅក្រោយដូចក្នុងរឿងអ៊ីចឹង ដាវគេអ៊ីចឹង គឺមានស្រោម មានអីត្រឹមត្រូវអ៊ីចឹង មិនមែនដាវទទេទេ។ ហើយយើងមើលទៅ អ្នកដែលពាក់ដាវហ្នឹងគឺសុទ្ធតែក្រុមដាវវែងហើយ។ ចំពោះប្រជាពលរដ្ឋ ប្រជាជនធម្មតា ដូចខ្ញុំជាអ្នកឡើងត្នោតហ្នឹង ក៏អត់មានអីជាសម្គាល់ដែរ។ ខ្ញុំស្គាល់ដោយសារអ៊ីចឹង។

**សៈ** តើលោកដឹងថានៅក្នុងពេលចាប់ខ្លួនហ្នឹង មានអ្នកមកពីខាងឈ្លបទេ ខាងកងឈ្លបមានទេ?

**ឆៈ** នៅខាងកងឈ្លបហ្នឹង ខ្ញុំដូចជាអត់បានដឹងទេ។ ដូចខ្ញុំបានជម្រាបអ៊ីចឹង បើសិនជាថ្ងៃទៅយើងអាចស្គាល់ថាជាឈ្លប ជាពួកដាវវែង ជាអ្នកណា យើងអាចស្គាល់។ តែពេលម៉ោងប្រាំមួយ គឺវាព្រលប់ៗ ហ្នឹងវាដូចថាវាងងឹតហើយ ដូច្នេះ ខ្ញុំមិនអាចស្គាល់ដឹងថាឈ្លប ឬមិនឈ្លបទេ ព្រោះពេលដែលគេប្រើខ្ញុំមកនេះ គេអត់បានប្រាប់ដូចខ្ញុំជម្រាបច្រើនដងហើយថា គេអត់នឹងមានឲ្យ ព័ត៌មានយើងថា ទៅណាៗផង គ្រាន់តែគេថា "ឥឡូវមិត្តឯងទៅថ្នល់ ទៅតាមហ្នឹងទៅថ្នល់ទៅ ទៅ គេនៅហ្នឹងហើយ" ហើយគេអត់ប្រាប់យើងថាទៅធ្វើអីៗ គឺគេអត់ប្រាប់យើងទាំងអស់ បាទ។

[០៩:១៤:២៣]

**សៈ** គេមិនប្រាប់លោកថា លោកត្រូវធ្វើអីទេ ក៏ប៉ុន្តែតាមរយៈអ្វីដែលខ្ញុំបានអាននោះ ខ្ញុំយល់ថាក្រុមដាវវែងហ្នឹងពេលដែលទៅបាត់ទៅ គឺនៅសល់តែលោក ហើយនិងគ្នាលោកបីនាក់ទៀតទេ ជាអ្នកបណ្ដើរពួកចាមហ្នឹងយកទៅវត្ត។ ដូច្នេះ ខ្ញុំចង់ដឹងថា អ្នកណាជាអ្នកប្រាប់លោកថាឲ្យបណ្ដើរចាមទាំងអស់ហ្នឹងទៅវត្តហ្នឹង? ហើយពេលបណ្ដើរទៅហ្នឹង គឺប្រហែលជាពេលណា ម៉ោងប៉ុន្មានដែរ?

**ឆៈ** ក្នុងពេលយកបងប្អូនចាមទៅក្នុងវត្តហ្នឹង វាមូលហេតុវាអ៊ីចេះ ប្រជាជនហ្នឹងត្រូវគេចាប់ច្រើន ដូច្នេះពីរបីរយនាក់ មិនមែនជារឿងធម្មតាអីណា ផ្លូវយើងទទឹងប្រហែលជា៤ម៉ែត្រៗអ៊ីចឹង គេដាក់បណ្ដាក់គ្នារហូតទៅក្នុងទៅ ហើយខ្ញុំគឺនៅក្រោយគេបង្អស់បាទ។ នៅខាងក្រោយបង្អស់ហ្នឹង ហើយខ្ញុំអត់ដឹងថានៅខាងមុខហ្នឹងជាអ្នកណាៗ គឺខ្ញុំអត់ដឹងទេ។ ហើយខ្ញុំគឺគេឲ្យនៅខាងក្រោយៗដែលបងប្អូនចាមដែលនៅក្រោយគេបង្អស់ហ្នឹង គឺខ្ញុំនៅជាប់នឹងបងប្អូនចាមដែលនៅក្រោយគេហ្នឹង។ ហើយអ្នកនៅកណ្ដាល នៅមុខហ្នឹង ខ្ញុំអត់ដឹងថាអ្នកណាគេអ្នកនាំទៅទេ។ ខ្ញុំអត់បានឃើញទេបាទ។

**សៈ** ខ្ញុំសួរម្ដងទៀតថា អ្នកណាជាអ្នកបញ្ជាលោកហ្នឹងឲ្យបណ្ដើរជនជាតិចាមហ្នឹងទៅវត្តនុំង?

**ឆៈ** អ្នកប្រាប់ខ្ញុំថា ឲ្យ -- គេមិនមែនប្រាប់បញ្ជាខ្ញុំឲ្យនាំបងប្អូនចាមទៅវត្តទេ ក៏ប៉ុន្តែគេគ្រាន់តែប្រាប់ខ្ញុំថាឲ្យនៅកន្លែងត្រង់ហ្នឹង ហើយកាលណាគេនាំនេះ បងប្អូនចាមទៅ ឲ្យខ្ញុំដើរតាមក្រោយ

បងប្អូនចាមហ្នឹងទៅ។ បាទ គេមិនមែនបញ្ជាឲ្យខ្ញុំនាំបងប្អូនចាមទៅទេ ព្រោះខ្ញុំវាគ្មានសិទ្ធិអំណាចតួនាទីអីទៅបណ្ដើរបងប្អូនចាមទៅវត្តទេ។ ប៉ុន្តែខ្ញុំគ្រាន់ថា បងប្អូនចាមដើរខាងមុខ ហើយ--

**ស៖** សូមអភ័យទោសលោកសាក្សី។ ពេលវេលាខ្ញុំខ្លីណាស់ លោកសាក្សីសូមអភ័យទោស សូមឲ្យលោកឆ្លើយដោយខ្លីទៅនឹងសំណួររបស់ខ្ញុំ។ ខ្ញុំសួរថា អ្នកណា? ឈ្មោះអី? ដែលជាអ្នកនាំលោក -- ដែលជាអ្នកបញ្ជាលោកឲ្យនាំជនជាតិចាមហ្នឹងទៅនោះ?

**ឆ៖** អ្នកដែលបញ្ជាខ្ញុំតាំងពីកន្លែងរោងបាយរហូតមកដល់ពេលដែលខ្ញុំនាំបងប្អូនចាម គឺមេកងរោងបាយនៅសំបួរមាស "ក" ហ្នឹងតែម្ដង។

**ស៖** លោកបានឆ្លើយថា នៅពេលដែលលោកកំពុងធ្វើការហ្នឹង គេអត់មានប្រាប់ថា លោកត្រូវធ្វើអីឲ្យប្រាកដទេ។ អ៊ីចឹងនៅពេលដែលលោកទៅដល់កន្លែងហ្នឹងតែម្ដង បានលោកដឹងថា លោកត្រូវធ្វើអីនោះ។ អ៊ីចឹងអ្នកណាដែលប្រាប់លោកនោះ ពេលដែលលោកទៅដល់កន្លែងដែលលោកត្រូវឈរយាមចាំហ្នឹង អ្នកណាអ្នកប្រាប់លោកថា ឲ្យនាំអ្នកចាមដែលគេចាប់ខ្លួនបានទៅវត្តនុ៎ង?

**ឆ៖** ខ្ញុំបានបញ្ជាក់ប្រាប់ហើយតើ ថាអ្នកដែលប្រាប់ខ្ញុំឲ្យនាំបងប្អូនចាមហ្នឹង គឺមេកងនៅភូមិសំបួរមាស "ក" ហ្នឹងបាទ គឺគាត់ឈ្មោះ ហុក ហឿន ជាមេកងនៅប្រចាំកន្លែងត្រង់ហ្នឹង។

[០៩:១៨:១៨]

**ស៖** ពេលលោកទៅដល់ជិតជនជាតិចាមដែលគេចាប់ខ្លួនបានហ្នឹង មេកងហ្នឹងមានវត្តមាននៅទីនុ៎ងដែរមែនទេ?

**ឆ៖** ពេលដែលខ្ញុំទៅដល់កន្លែងដែលគេចាប់បងប្អូនចាមហ្នឹង មេកងហ្នឹងអត់មានវត្តមាននៅកន្លែងហ្នឹងទេ?

**ស៖** សូមអភ័យទោស លោកអាចនិយាយម្ដងទៀតបានទេ អម្បាញ់មិញនេះអ្នកបកប្រែបកចម្លើយលោកអត់បានទេ។

**ឆ៖** ខ្ញុំចង់និយាយថា អ្នកដែលប្រាប់ឲ្យខ្ញុំទៅកន្លែងនុ៎ង ហើយនិងឲ្យនាំបងប្អូនចាមទៅហ្នឹង គឺឈ្មោះ ហុក ហឿន ជាមេកងនៅប្រចាំភូមិសំបួរមាស "ក" ហ្នឹង។

**ស៖** ពេលគាត់ប្រាប់លោកហ្នឹង គឺលោកនៅពេលកំពុងធ្វើការ ប៉ុន្តែអ្វីដែលខ្ញុំចង់ដឹងហ្នឹង គឺថានៅពេលដែលលោកទៅដល់ជិតជនជាតិចាមពីរបីរយនាក់ដែលគេចាប់បានហ្នឹង លោកឃើញក្រុមដាវវែងដែលនៅជិតហ្នឹងដែរ។ អ៊ីចឹងអ្នកណាជាអ្នកប្រាប់លោកនោះ ថាត្រូវធ្វើយ៉ាងម៉េចជាមួយជនជាតិ

ចាមដែលគេចាប់បានហ្នឹង? អ្នកណាមួយ ហើយឈ្មោះអី? ដែលនៅពេលដែលលោកទៅដល់ក្បែរជនជាតិចាមហ្នឹង គេប្រាប់លោកឲ្យនាំទៅវត្តហ្នឹង អ្នកដែលប្រាប់ហ្នឹងឈ្មោះអី?

[០៩:២០:០៥]

**ឆ៖** ទៅដល់កន្លែងកើតហេតុហ្នឹងគឺគេមិនបានប្រាប់ខ្ញុំថា ឲ្យនាំបងប្អូនចាមទៅវត្តទេ គេគ្រាន់តែឲ្យខ្ញុំនៅចាំបងប្អូនចាមដែលគេនាំចេញពីផ្ទះមកបាទ ពីផ្ទះមកហ្នឹង ដើម្បីឲ្យខ្ញុំនៅផ្លូវខាងៗនេះហ្នឹង ដើម្បីកុំឲ្យបងប្អូនចាមរត់ចុះទៅខាងទន្លេ។

**ស៖** ហើយអ្នកដែលប្រាប់លោកថាឲ្យមើលពួកចាមហ្នឹង ឈ្មោះអី?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក សេង ស៊្រុន៖**

**ឆ៖** ខ្ញុំដូចជាពិបាកឆ្លើយ ហើយខ្ញុំឆ្លើយនេះដូចថាបញ្ជាដដែលៗ។ ដូចខ្ញុំបានប្រាប់ហ្នឹង ខ្ញុំថា ហុក ហឿន ហ្នឹងជាអ្នកបញ្ជាខ្ញុំ ហើយពេលដែលគេទៅដល់កន្លែងហ្នឹង ក៏គេអត់ប្រាប់ខ្ញុំថាឲ្យទៅធ្វើអីដែរ ក៏ប៉ុន្តែដល់ពេលខ្ញុំទៅដល់កន្លែង ខ្ញុំឃើញសន្តិសុខហ្នឹង គេនាំចាមមក ហើយគេប្រាប់ខ្ញុំថា “មិត្តឯងនៅមើលបងប្អូនចាមត្រង់ហ្នឹងហើយ” គេប្រាប់អ៊ីចឹង។ ឈ្មោះដែលនេះហ្នឹង តាយ គឹមហ៊ាន់ គាត់ហ្នឹងជាអនុប្រធានក្រុមដាវវែង។

[០៩:២១:៤២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** កាលពីម្សិលមិញ លោកបានឆ្លើយជូនអង្គជំនុំជម្រះថា ក្រុមដាវវែងគឺត្រូវបានបង្កើតឡើងនៅក្នុងចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧។ ក៏ប៉ុន្តែនៅក្នុងចម្លើយរបស់លោកគឺក្នុងឯកសារ E3/5252, ERN ជាភាសាបារាំង 00269891, ERN ជាភាសាខ្មែរ 00235021, ERN ជាភាសាអង់គ្លេស 00235516។ លោកបានឆ្លើយថា ក្រុមដាវវែងហ្នឹងបង្កើតឡើងនៅខែ៦ ឆ្នាំ៧៦។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ថា ក្រុមដាវវែងហ្នឹង គេបង្កើតនៅចុងឆ្នាំ៧៦ ដើម៧៧ ឬក៏ពាក់កណ្ដាលឆ្នាំ៧៦?

**ឆ៖** ការឆ្លើយរបស់ខ្ញុំនេះ ដូចខ្ញុំបានជម្រាបហើយ សម័យ ប៉ុល ពត គឺយើងអត់ដឹងថាខែប៉ុន្មានៗ ថ្ងៃណាៗ ក៏យើងអត់ដឹងដែរ។ នេះជាការប៉ាន់ស្មាន ដូចខ្ញុំបានជម្រាបថា អាក្រុមដាវវែងនេះ គេ

អាចបង្កើតនៅចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧បាទ។

**ស៖** អ៊ីចឹងចម្លើយនៅក្នុងឯកសាររបស់លោកកាលពីខែតុលា ឆ្នាំ២០០៨ ហ្នឹងគឺមិនត្រឹមត្រូវទេ ដែលថាខែពាក់កណ្ដាលឆ្នាំ៧៦ហ្នឹង មែនទេ មិនត្រឹមត្រូវទេចម្លើយហ្នឹង?

**ឆ៖** អាហ្នឹងខ្ញុំមិនអាចសន្និដ្ឋានថាត្រឹមត្រូវ ឬមិនត្រឹមត្រូវទេ ព្រោះក៏ខ្ញុំបាននិយាយថាច្បាស់ថា ប្រហែលជាចុងឆ្នាំ៧៦ ឬក៏ដើមឆ្នាំ៧៧ ដែលគេបង្កើតក្រុមដារវែងហ្នឹងឡើង។

**ស៖** លោកបានឆ្លើយជាច្រើនដងច្រើនសានៅក្នុងកំណត់ហេតុរបស់លោក លោកបានឆ្លើយថា មិនមានការបូជា ឬក៏បញ្ចុះ សូមទោស មិនមានការបញ្ចុះសពហ្នឹងឲ្យបានត្រឹមត្រូវទេ។ លោកថា ប្រជាជនបានជីកដីដើម្បីរករបស់របរផ្សេងៗ។ តើលោកអាចបញ្ជាក់បានដែរ ថានៅពេលដែលគេជីក កកាយគាស់រណ្ដៅហ្នឹង គេរកឃើញរបស់អីខ្លះ?

**ឆ៖** ក្នុងការដែលគេជីកសាកសពរណ្ដៅក្រោយពីឆ្នាំ១៩៧៩មក តាមការពិនិត្យខ្ញុំទៅ គឺមាន ដូចជាសម្ភារៈដែលគេជីកបាន វាមានដូចជាមាស ដូចជាស្អីចិញ្ចៀនស្អីៗនៅក្នុងរឿងដែលគេលាក់ ដែល តាមធីវអាវធីវអីហ្នឹង ហើយក៏មានខ្លះទៅ មានជាកញ្ចប់។ ហើយវត្ថុទាំងហ្នឹង គឺដែលខ្ញុំឃើញ គឺមាន រណ្ដៅខ្លះ គេបាន មានបានមាសរហូតដល់ទៅ២គីឡូជាងអីក៏មានដែរ។ ហើយខ្លះទៅបានប្រាំជី មួយ តម្លឹងអ៊ីចឹងទៅ ហើយរណ្ដៅខ្លះដូចជារណ្ដៅដែលខ្ញុំសន្និដ្ឋានថា គេកប់បងប្អូនចាមហ្នឹង គឺវាមានខោអាវ មានបង្វិច មានសម្លៀកបំពាក់បងប្អូនចាមហ្នឹងទៅ ដែលគាត់យកមកតាមខ្លួនហ្នឹងខ្លះ គាត់ក៏អត់បាន យកមក ហើយមានដូចថាលាយឡំជាមួយក្បាលកូនក្មេងអ៊ីចឹងទៅ ដែលខ្ញុំថាជារណ្ដៅកប់បងប្អូនចាម ហ្នឹង គឺវាដោយឡែក។ ហើយរណ្ដៅកប់បងប្អូនខ្មែរហ្នឹង គឺដោយឡែក គឺអត់មានឡូកឡំគ្នាទេបាទ។

[០៩:២៥:៥៥]

**ស៖** កាលពីម្សិលមិញ លោក គឺក្រោយម៉ោង ០៩:២១ នាទី បន្តិចគឺប្រហែលជាម៉ោង០៩:៣២ នាទី គឺលោកបានឆ្លើយថា នៅឆ្នាំ៧៦ គេហាមជនជាតិចាមមិនឲ្យគោរពសាសនារបស់ពួកគេទេ ហើយ ពួកចាមមិនមានសិទ្ធិពាក់សម្លៀកបំពាក់ចាម ប្រពៃណីចាមទេ។ នៅក្នុងកំណត់ហេតុរបស់លោក គឺ លេខ E3/5302, ERN ជាភាសាបារាំង 00623193, ជាភាសាខ្មែរ គឺ00635179, ERN ជាភាសា អង់គ្លេស 00210490។ លោកបាននិយាយថា នៅក្នុងរណ្ដៅទាំងនោះ លោកឃើញសម្លៀកបំពាក់ និង កន្សែងចាម។ លោកថា តាំងពីឆ្នាំ៧៦មក ជនជាតិចាមត្រូវពាក់សម្លៀកបំពាក់ខោអាវ ស្លៀកខោអាវដូច ខ្មែរដែរ។ អ៊ីចឹងម៉េចក៏នៅក្នុងរណ្ដៅហ្នឹង រកឃើញខោអាវចាមទៅវិញ ដែលគេសម្លាប់នៅឆ្នាំ៧៦ហ្នឹង

ម៉ែចក៏មានខោអាវប្រពៃណីចាម បើគេហាមឃាត់មិនឲ្យពាក់ហ្នឹង តាំងពី៧០មកហើយនោះ?

**ឆ៖** ការហាមឃាត់របស់ខ្មែរក្រហមសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង វាអ៊ីចេះ គឺវាគ្រាន់ថា ក្នុងការដើរ ក្នុងការធ្វើការ ឬក៏មកប្រជុំអីអ៊ីចឹងទៅ គេអត់ឲ្យយើងស្លៀកពាក់ទេ ហើយសម្លៀកបំពាក់ដែលបន្សល់ទុកហ្នឹងគឺជារបស់របរគាត់ពីមុនមក ហើយកប់ទុកនៅផ្ទះ បាទ មិនមែនជាគាត់ស្លៀកមកតាមខ្លួនតាមអីទេ បាទ ធម្មតារបស់ស្អីក៏ដោយ កាលនុ៎ង ក៏សូម្បីតែមានការហាមឃាត់ម៉ែច ក៏ថាជាប្រពៃណីទំនៀមទម្លាប់ក៏ធ្វើនៅតែមានដែរ រឿងរបស់ដែលពីៗកេរកាលពីមុនមក។ ដូច្នេះរបស់គាត់អារបស់គាត់ហ្នឹង មិនមែនជារបស់គាត់ដែលស្លៀកពាក់ទៅជាប់នឹងខ្លួនទេ គឺជារបស់ដែលគាត់វេចខ្ចប់ទុកនៅផ្ទះ ក្នុងការគេហាមឃាត់ គឺគាត់អត់ហ៊ានពាក់ទេ តែដល់មកផ្ទះយប់អីទៅ ក៏គាត់អាចស្លៀកពាក់បានដែរ បាទ មិនមែនថាគេមករើរុះយកពីផ្ទះទៅយើង -- ពីយើងទៅ ក៏មានដែរ គឺរបស់ហ្នឹងនៅរបស់យើង គ្រាន់តែគេហាមឃាត់មិនឲ្យយើងស្លៀកពាក់។

[០៩:២៨:៣១]

**ស៖** ខ្ញុំសួរសំណួរនេះ ពីព្រោះថានៅក្នុងរបាយការណ៍បេសកកម្ម E3/2654 សហព្រះរាជអាជ្ញាបានសួរបុរសម្នាក់ឈ្មោះ លឹប សុល, ERN ជាភាសាបារាំង គឺ00620050, ជាភាសាអង់គ្លេស 00211169, ជាភាសាខ្មែរ គឺ00640495 បន្តទៅដល់ទំព័របន្ទាប់ខាងមុខទៀត។ សាក្សីនោះបានឆ្លើយថា គាត់ទៅអូរត្រកួននៅក្រោយឆ្នាំ៧៩ ហើយគាត់ឃើញសាកសព គាត់មិនអាចកំណត់ថាសាកសពណាជាជនជាតិចាម សាកសពណាជាជនជាតិខ្មែរបានទេ។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេ នៅពេលដែលមានកំណាយកាយរណ្ដៅ ដើម្បីរករបស់របរដូចជា មាស ប្រាក់ អីដែលលោកបានបញ្ជាក់ហ្នឹងគឺថាគេមិនអាចកំណត់បានថា សាកសពណាជាជនជាតិចាម ឬជាជនជាតិខ្មែរអីអ៊ីចឹងបានទេ មែនទេ?

**ឆ៖** ខ្ញុំអត់យល់ដូចថា គាត់ សាក្សីរឿងគាត់អះអាងថាគាត់ ពីឆ្នាំ៧៩ គាត់អាចចុះទៅពិនិត្យសាកសពថា មិនមែនជាបងប្អូនចាម មិនមែនជាបងប្អូនខ្មែរ គឺគ្រាន់តែជាការសន្និដ្ឋានគាត់ ដោយស្មានៗទេ តែខ្ញុំរស់នៅកន្លែងវត្តអូរត្រកួនហ្នឹង ដូចខ្ញុំបានជម្រាបតាំងពីខ្ញុំអាយុមួយឆ្នាំ រហូតដល់ខ្ញុំអាយុជាង៣០ឆ្នាំ បាទ ខ្ញុំស្គាល់ច្បាស់ណាស់ភូមិសាស្ត្រកន្លែងនោះ។ ហើយខ្ញុំស្គាល់ច្បាស់ណាស់ដែលសម្លៀកបំពាក់ជាបងប្អូនខ្មែរ ជាបងប្អូនចាម គឺខ្ញុំស្គាល់ច្បាស់ណាស់ បាទ។ ហើយខ្ញុំបានទទួលព័ត៌មានដែលគេសម្លាប់បងប្អូនចាមហ្នឹង ដូចខ្ញុំបានរៀបរាប់ថា ខ្ញុំមានមិត្តភក្តិមួយនៅក្នុងមន្ទីរសន្តិសុខឈ្មោះ មឿនជាអ្នកឡើងត្នោតជាមួយខ្ញុំហ្នឹង គាត់បានប្រាប់កន្លែងដែលគេកប់រ៉ៃបងប្អូនចាមហ្នឹងនៅកន្លែងត្រង់ណាៗ

គឺគាត់អាចប្រាប់ខ្ញុំ។ ដល់ពេលរួចទៅ គឺកន្លែងដែលគាត់ប្រាប់ខ្ញុំ គេទៅគាស់ ខ្ញុំទៅមើលកន្លែងហ្នឹង គឺពិតដូចពាក្យគាត់និយាយមែន បាទ។ តែចំពោះសាក្សីក្រៅទៀត គ្រាន់តែជាការគាត់ប៉ាន់ស្មាន និយាយតៗគ្នា អត់ភស្តុតាង អត់មានការជាក់ស្តែងអី។ បាទ គាត់ចេះតែនិយាយទៅ ដើម្បីចេះតែគេសួរទៅ ឲ្យតែមានពាក្យនិយាយ។ តែការពិតគឺវាអត់អីចឹង។

[០៩:៣១:១៦]

**ស៖** លោកបាននិយាយពីឈ្មោះ មឿន ដែលជាមិត្តភក្តិរបស់លោកជាច្រើនលើកច្រើនសា។ អីចឹងខ្ញុំចង់ដឹងថា ក្រៅពីជួបជាមួយ មឿន ហ្នឹងគឺថាលោកមិនដែលបានជួបនិយាយគ្នាអីជាមួយក្រុមដាវវែងទេ មែនទេ?

**ឆ៖** បាទ រឿងក្រុមដាវវែងនិងខ្ញុំ វាដូចអត់មានទំនាក់ទំនងអីទេ ព្រោះគេតួនាទីគេផ្សេង។ ដូចខ្ញុំអីថ្វីដ្បិតតែខ្ញុំនៅក្នុងអ្នកឡើងត្នោត ប៉ុន្តែពេលខ្ញុំឃើញពួកដាវវែងមកហ្នឹង ខ្ញុំក៏ភ័យដែរ មិនដឹងជាមករកគេ មករកឯង។ បាទ ដូច្នេះខ្ញុំអត់ដែលមានទំនាក់ទំនងអីជាមួយពួកដាវវែងទេ ហើយពួកហ្នឹងក៏គេអត់ទៅរាប់អានយើងដែរ បាទ ព្រោះតួនាទីគេវាខ្ពស់ យើងវាសមត្ថភាពយើងវាតូចតាច គេមិនសូវរាប់អានយើងទេ។ ដូច្នេះការទំនាក់ទំនងគឺអត់មានទេ។

**ស៖** អីចឹង ខ្ញុំអាចនិយាយបានថា លោកអត់មានទំនាក់ទំនងអ្វីជាមួយនឹងឈ្លបឃុំទេ។ មែនទេ?

**ឆ៖** បាទ រឿងឈ្លបឃុំហ្នឹង ក៏ខ្ញុំអត់មានទំនាក់ទំនងរឿងដាវវែងហ្នឹង ក៏ខ្ញុំអត់មានទំនាក់ទំនងដែរ ព្រោះខាងឈ្លបឃុំហ្នឹងគេធ្លាប់ចាប់ខ្ញុំយកទៅដាក់ខ្នោះ ដាក់អីម្តងហើយ។ ដូច្នេះការទំនាក់ទំនង ខ្ញុំក៏អត់ដែលទៅទំនាក់ទំនងជាមួយអ្នកណាទាំងអស់។

**ស៖** ក្រៅពីធ្វើជាអ្នកឡើយត្នោត តើខ្ញុំអាចនិយាយបានទេថា អត់មានមុខងារអ្វីជាផ្លូវការនៅក្នុងឃុំ ក្នុងស្រុក នៅថ្នាក់តំបន់អ្វីទេ។ ត្រឹមត្រូវទេ បើខ្ញុំនិយាយអីចឹងនោះ?

**ឆ៖** បាទ នៅក្នុងតួនាទីនៅក្នុងរបបខ្មែរក្រហមហ្នឹង គឺខ្ញុំអត់មានតួនាទីអីទាំងអស់បាទ។ ខ្ញុំគ្រាន់តែជាមុខសញ្ញាមួយសម្រាប់គេបម្រុងយកទៅសម្លាប់ទេ តែដោយសារគេប្រើខ្ញុំទៅណា គឺខ្ញុំអាចធ្វើបានទាំងអស់។ ដូច្នេះ ទើបខ្ញុំមានការរស់រានមានជីវិតរហូតដល់សព្វថ្ងៃ។

**ស៖** ដូច្នេះ លោកមិនអាចដឹងថាអ្នកណាជាអ្នកសម្រេច ហើយនៅពេលប្រជុំផ្សេងៗហ្នឹងគឺនៅពេលប្រជុំថ្នាក់ឃុំ ថ្នាក់តំបន់ ថ្នាក់ស្រុកអីហ្នឹង គឺលោកមិនដឹងថាអ្នកណាជាអ្នកនិយាយអ្វី អ្នកណាសម្រេចអ្វីទេ។ ខ្ញុំនិយាយអីចឹងត្រឹមត្រូវទេ?

**ផ៖** បាទ និយាយអ៊ីចឹងគឺត្រឹមត្រូវ។

**ស៖** លោកបាននិយាយថា ក្រោយឆ្នាំ៧៩ហ្នឹង គេរកឃើញឯកសារនៅក្នុងពាង។ តើលោកដឹងថាគេយកឯកសារនៅក្នុងពាងហ្នឹងយកទៅណាទេ? ហើយអ្នកណាជាអ្នកប្រមូលឯកសារនៅក្នុងពាងហ្នឹង?

[០៩:៣៤:៥០]

**ផ៖** ឯកសារនៅក្នុងពាងហ្នឹង បើតាមខ្ញុំពិនិត្យមើលទៅ ដូចវាគ្មានជាឯកសារអីមួយជាកំណត់សម្គាល់ទេ ព្រោះអ្នកដែលជីកហ្នឹងគឺមិនមែនរកឯកសារហ្នឹងទេ។ ជីកពាងហ្នឹង គ្រាន់តែឃើញពាងហ្នឹងនាំគ្នារោម ជិតក្រែងលោវាមានស្អី របស់មានតម្លៃនៅក្នុង ដល់ពេលរើទៅវានាំគ្នាបាចអាក្រដាសនោះ ពេញតែនុំងទៅ គ្មានពីណាគេចាប់អារម្មណ៍រឿងស្អីៗ ហើយខ្ញុំរើសបានដែរ គឺរើសបានទៅមានបញ្ជីឈ្មោះអ៊ីចឹងទៅដែរ មិនមែនថាអត់មាននោះទេ គ្រាន់តែឈ្មោះណាៗ ប៉ុន្តែមិនដឹងនៅឃុំណាស្រុកណាអី ខ្ញុំអត់បានចាប់អារម្មណ៍ទេ តែក្រដាសហ្នឹងវាក៏គ្មានវាជាឯកសារអីសម្រាប់កំណត់សម្គាល់ថាប្រជាជនដែលគេត្រូវសម្លាប់ហ្នឹង ២ ទៅ៣០.០០០ នាក់ក៏អត់មានដែរ គឺអត់មានទាំងអស់។ អ្នកដែលនិយាយនុំង សុទ្ធតែនិយាយក្នុងការប៉ាន់ស្មានទេបាទ។

**ស៖** សំណួរខ្ញុំគឺច្បាស់ណាស់ ខ្ញុំចង់ដឹងថា អ្នកណាជាអ្នកប្រមូលយកឯកសារហ្នឹងទៅ ហើយយកទៅធ្វើស្អី?

**ផ៖** ឯកសារហ្នឹងបើតាមខ្ញុំមើលឃើញ គឺអត់មានពីណាប្រមូលផង បោះចោល រាត់រាយហ្នឹងអត់មានអ្នកណាមួយប្រមូលយកទៅណាទេ។ ហើយមួយជំនាន់នុំងគឺគ្មានអ្នកដឹកនាំឯណាមករើឯកសារអីឯណា គឺអត់មានទាំងអស់។ ហើយខ្ញុំប៊ានធានាថា តើអ្នកណាមួយដែលថាគាត់អះអាងថា មានឯកសារពីតួលេខបងប្អូនខ្មែរដែលគេត្រូវយកទៅ -- បងប្អូនប្រជាជនខ្មែរចាមក្តី ខ្មែរក្តី គេត្រូវសម្លាប់ ២ ទៅ ៣០.០០០នាក់ហ្នឹង ឥឡូវខ្ញុំប៊ានប្រឈមមុខ តើយកឯកសារនោះយកមក ខ្ញុំប៊ានតតាំង បាទ មកនិយាយជាមួយខ្ញុំ។ ខ្ញុំឈ្មោះ សេង ស្រ៊ុន នៅពាមជីកង ខ្ញុំប៊ាន។ លោកណាក៏ដោយ ដែលគាត់អះអាងថា មានឯកសារជាជាក់ស្តែងថា ៣៥០០០ នុំង។

[០៩:៣៦:៥៦]

**ស៖** សូមអភ័យទោសលោកសាក្សី ខ្ញុំសូមឲ្យលោកសហការជាមួយខ្ញុំ ពេលវេលាខ្ញុំខ្លីណាស់ ខ្ញុំសួរសំណួរជាក់លាក់ និងសាមញ្ញបំផុត។ ខ្ញុំមិនចង់ឲ្យលោកឆ្លើយវែងទេ សូមលោកស្តាប់សំណួរខ្ញុំឲ្យ

ច្បាស់ ឆ្លើយឲ្យខ្លី១។ ខ្ញុំនិយាយអំពីរយៈកាលក្រោយឆ្នាំ៧៩ លោកបាននិយាយអំពីគណៈកម្មការវត្ត ដែលមានរហូតមកដល់សព្វថ្ងៃនេះ ហើយលោកបញ្ជាក់ថា តាយ គឹមប៊ាន់ នេះក៏ស្ថិតនៅក្នុងគណៈកម្មការវត្តដែរ។ ក្នុងឯកសាររបស់លោក គឺE3/5252, ជាភាសាបារាំង គឺ 00269891, ជាភាសាខ្មែរ គឺ 00235021 -- សូមអភ័យទោស ខ្ញុំត្រូវការពេលបន្តិចដើម្បីរក ERN ជាភាសាអង់គ្លេស។ ខ្ញុំនឹងផ្តល់នៅពេលបន្តិចទៀត។ នៅក្នុងចម្លើយនោះ លោកបញ្ជាក់ថា សមាជិកគណៈកម្មការវត្តទាំងអស់ សុទ្ធតែជាពួកខ្មែរក្រហម សុទ្ធតែជាសមាសភាពខ្មែរក្រហម។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ លោកសំដៅលើអ្នកណាខ្លះនៅពេលដែលលោកនិយាយថា សមាជិកគណៈកម្មការវត្តទាំងអស់នោះ សុទ្ធតែជាសមាសភាពខ្មែរក្រហមនោះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយដោយខ្លី។ សមាសភាពដែលជាគណៈកម្មការវត្តជាប្រធានគណៈកម្មការវត្តអូរត្រកួន និងជាអាចារ្យវត្ត ប្រចាំវត្តអូរត្រកួន ទី១ គឺឈ្មោះ ពិន ភី គាត់ជាប្រធានរោងបាយនៅសំបួរមាសលើ ហើយ តាយ គឹមប៊ាន់ ហ្នឹង គាត់ជាអនុប្រធានដាវវែង គាត់ជាគណៈកម្មការវត្តអូរត្រកួន មករហូតដល់សព្វថ្ងៃ។ បាទ ខ្ញុំនិយាយខ្លី។

**ស៖** ខ្ញុំសូមផ្តល់លេខ ERN ជាភាសាអង់គ្លេស គឺ 00235517។ ហេតុអ្វីបានជាលោកនិយាយថាសមាជិកគណៈកម្មការវត្តទាំងអស់ហ្នឹងជាសមាសភាពខ្មែរក្រហម។ អ៊ីចឹងមនុស្សពីរនាក់ ដែលលោករៀបរាប់ប្រាប់ខ្ញុំអម្បាញ់មិញនេះ គាត់មានមុខតំណែងនៅក្នុងឃុំ នៅក្នុងសម័យកម្ពុជា ប្រជាធិបតេយ្យមែនទេ?

**ឆ៖** បាទ ពីរនាក់ហ្នឹង គឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់មានតួនាទីជាអនុប្រធានកងសន្តិសុខដាវវែងគឺ លោក តាយ គឹមប៊ាន់។ ទី២ លោក ពិន ភី ហ្នឹងគាត់ជាប្រធានកងនៅ -- ប្រធានភស្តុភារឃុំ១ និងជាប្រធានរោងបាយនៅខាងសំបួរមាសលើ។ បាទ ដូច្នេះ ក្នុងរបបហ្នឹង គឺគាត់មានតួនាទីទាំងពីរនាក់ហ្នឹង។

[០៩:៤០:២៦]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំដឹងអំពីពេលវេលាដែលបានផ្តល់ជូន ទោះបីជាខ្ញុំនៅសល់សំណួរផ្សេងទៀតក៏ដោយ ក៏ប៉ុន្តែខ្ញុំសូមបញ្ចប់ការសួរសំណួរត្រឹមនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សវនាការស្ដាប់សក្ខីកម្មសាក្សី សេង ស្រ៊ុន បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោក សេង ស្រ៊ុន ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលជាងមួយថ្ងៃកន្លងមកនេះ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ ហើយវត្តមានរបស់លោកលែង -- នៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោក សេង ស្រ៊ុន ជួបតែសំណាងល្អ មានសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ពេលវេលា។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និង អ្នកជំនាញក្នុងការជូនលោក សេង ស្រ៊ុន វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយនិងឲ្យអញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-883 រួមទាំងមេធាវីប្រឹក្សាសាក្សី សេង រិទ្ធា មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការនេះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:៤៣:៣២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកសាក្សី តើលោកឈ្មោះអី?

**លោក សំរិត មុយ៖**

**ឆ៖** បាទ ខ្ញុំបាទ ឈ្មោះ សំរិត មុយ សូមជម្រាបសួរលោកប្រធាន។

**ស៖** អរគុណលោក សំរិត មុយ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេថា តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** បាទ ខ្ញុំកើតនៅឆ្នាំ១៩៤៧។

**ស៖** ១៩៤៧ អ៊ីចឹង? ឆ្លើយ ១៩៤៧មែនទេ?

**ឆ៖** បាទ ១៩៤៧។

**ស៖** លោក សំរិត មុយ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំពីឆ្នាំ១៩៧០ ខ្ញុំធ្វើការនៅចៀរជ័រនៅពាមជាំង។

**ស៖** ទីកន្លែងកំណើត កន្លែងដែលលោកកើតៗនៅភូមិអី? ស្រុកអី? ខេត្តអី?

**ឆ៖** បាទ កើតនៅភូមិសំបួរមាស “ក” ឃុំពាមជីកង ស្រុកកងមាស។

**ស៖** បាទ អរគុណ។ ចុះទីលំនៅបច្ចុប្បន្នរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** បាទ ខ្ញុំរស់នៅភូមិសំបួរមាស “ក” ឃុំពាមជីកង ស្រុកកងមាសនេះដែរ។

**ស៖** អរគុណ។ ឪពុកបង្កើតរបស់លោកឈ្មោះអី ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកឈ្មោះ សំរិត ម៉ុច ម៉ាយឈ្មោះ អ៊ិន យាង។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** គ្រួសារខ្ញុំបាទឈ្មោះ សំរិត សំអឿន មានកូនប្រាំនាក់។

[០៩:៤៦:០៣]

**ស៖** បាទ អរគុណលោក សំរិត មុយ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអំមិញនេះ អម្បាញ់មិញនេះ ថាតាមសមត្ថភាពដែលលោកអាចដឹង គឺថាលោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទពីររូប នួន ជា និង ខៀវ សំផន និងបណ្ដាលបុគ្គលទាំងឡាយដែលបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតមែន។

**ស៖** ហើយថាលោកបានស្បថ មុននឹងចូលមកកាន់កន្លែង ចំពោះផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ បានន័យថាលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែកនៅពីខាងកើតនៃបន្ទប់សវនាការនេះកាលពីម្សិលមិញ។ តើពិតមែនដែរទេ?

**ឆ៖** បាទ ពិតហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក សំរិត មុយ ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះ លោកមានសិទ្ធិបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការឲ្យធ្វើលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ចក្នុងនាមលោកជាសាក្សីត្រូវតែឆ្លើយរាល់សំណួរទាំងឡាយ ដែលអង្គចៅក្រមនៃអង្គជំនុំ

ជម្រះ ឬក៏ភាគីសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់អំពីសិទ្ធិរបស់សាក្សីរួចមកហើយអម្បាញ់មិញនេះ។

[០៩:៤៧:៥៦]

ហើយក្នុងឋានៈជាសាក្សី ត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយ ដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោក សំរិត មុយ តើលោកធ្លាប់បានផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមក ប្រសិនបើធ្វើៗប៉ុន្មានដង? ធ្វើនៅពេលណា? នៅទីកន្លែងណា? លោកចាំដែរទេ?

**ឆ៖** បាទ ធ្វើពីរដងនៅនឹងផ្ទះ ប៉ុន្តែខ្ញុំអត់បានចាំថ្ងៃយូរណាស់មកហើយ។

**ស៖** បាទ មិនអីទេ។ អរគុណ ហើយមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកបានស្តាប់ចម្លើយ បានផ្តល់ចម្លើយកាលពីពេលមុនចំនួនពីរដងនៅនឹងផ្ទះរបស់លោក ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ បានរំឭកហើយ។

**ស៖** តាមសមត្ថភាពដែលលោកអាចដឹង និងចងចាំថាតើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុស្តាប់ចម្លើយដែលលោកបានអាន ឬក៏ស្តាប់ការអាន ដើម្បីរំឭកការចងចាំនោះ ពិតជាត្រឹមត្រូវសមស្រប ស៊ីចង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានធ្វើសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត កាលពីពេលមុននៅនឹងផ្ទះរបស់លោកនោះដែរឬទេ?

[០៩:៤៩:៤០]

**ឆ៖** បាទ បានពិនិត្យហើយ ប៉ុន្តែខ្ញុំវាមិនបានចាំគ្រប់ជ្រុងជ្រោយទេលោក។

**ស៖** មិនចាំទេ ប៉ុន្តែវាសមស្របទៅនឹងអ្វីដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុននោះទេ លោកពិនិត្យមើលឯកសារនុ៎ង ខ្លឹមសាររបស់វាៗសមស្របទេ ចម្លើយចម្លើយរបស់លោក?

**ឆ៖** បាទ សមស្រប។

**ប្រធានអង្គជំនុំ៖**

បាទ ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសាលាដំបូង ផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញា សួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ បាទ សូមអញ្ជើញ!

**លោក ស្រ៊ា រតនៈ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។

[០៩:៥០:៤៥]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** សូមជម្រាបសួរលោក សាក្សី។ ខ្ញុំបាទ ឈ្មោះ ស្រ៊ា រតនៈ ជាសហព្រះរាជអាជ្ញារងជាតិនៃការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ខ្ញុំបាទមានសំណួរទូទៅមួយចំនួនដែលចង់ជម្រាបសួរលោក។ តើមុនរបបខ្មែរក្រហមលោករស់នៅឯណា?

**លោក សំរិត មុយ៖**

**ឆ៖** មុនរបបខ្មែរក្រហម ខ្ញុំនៅកម្មករចៀរជ័រនៅពាមជាំង ជប់។

**ស៖** សូម ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់ជាងនេះបន្តិច ដែលខ្ញុំសំដៅថារបបខ្មែរក្រហមនេះ គឺក្នុងចន្លោះឆ្នាំចាប់ពី ថ្ងៃ១៧ មេសា ឆ្នាំ៧៥ ដល់ថ្ងៃ០៧ មករា ឆ្នាំ១៩៧៩។ អ៊ីចឹងលោកបានបញ្ជាក់អម្បាញ់មិញថា លោកនៅចំការកៅស៊ូពាមជាំង។ តើនៅតាំងពីឆ្នាំណា ដល់ឆ្នាំណា? ហើយក្រោយមកលោកនៅកន្លែងហ្នឹងរហូត ឬក៏លោកមានការផ្លាស់ប្ដូរទីកន្លែងស្នាក់នៅ និងធ្វើការដែរ?

**ឆ៖** ពីឆ្នាំ ខ្ញុំនៅតាំងពី៦០ នៅកម្មករចៀរជ័រនៅជប់ ហើយមកដល់ឆ្នាំ១៩៧០ ខ្ញុំទៅរស់នៅឯភូមិស្ដៅ ហើយដល់អាបេទម្លាក់ខ្ទេចខ្ទី ខ្ញុំរស់នៅមកនៅស្រុកកំណើតវិញ។

**ស៖** លោកបានលើកឡើងថា ដល់បេទម្លាក់ នៅឆ្នាំណាដែរ?

**ឆ៖** បាទ ឆ្នាំ១៩៧២, ៧៣ ហ្នឹង។

**ស៖** តើខ្មែរក្រហមបានចូលមកដល់ស្រុកកំណើតរបស់លោកនៅឆ្នាំណាដែរ?

**ឆ៖** កាលខ្ញុំរស់នៅឯស្ដៅនុ៎ង ចូលមកតាំងពីឆ្នាំ១៩៧១ ចូលមកដល់ភូមិស្ដៅ។

**ស៖** ខ្ញុំសំដៅទៅលើភូមិកំណើតដែលលោកបានស្នាក់នៅក្រោយឆ្នាំ ក្រោយពេលដែលលោកថា លោកត្រឡប់មកស្រុកកំណើតវិញ ក្រោយពេលមានការទម្លាក់គ្រាប់បែក អ៊ីចឹងខ្ទង់ឆ្នាំ៧២, ៧៣ លោកបានលើកឡើងអំមិញហ្នឹង។ អ៊ីចឹងខ្ញុំអត់ៗសំដៅទៅលើភូមិស្ដៅដែលលោកបានលើកឡើងពីខាងដើមនោះទេ។ ខ្ញុំសួរថា តើខ្មែរក្រហមចូលមកគ្រប់គ្រងភូមិរបស់លោក ដែលលោកស្នាក់នៅហ្នឹង តាំងពីឆ្នាំណា ភូមិកំណើត?

**ប្រធានអង្គជំនុំ៖**

លោកៗសហព្រះរាជអាជ្ញារងជាតិ គួរកំណត់ទីតាំងឲ្យច្បាស់លាស់ទៅ ភូមិកំណើតហ្នឹង ភូមិអីគាត់បានឆ្លើយរួចហើយអំមិញ ភូមិឃុំ ស្រុកឲ្យច្បាស់លាស់ទៅ អាចច្រឡំរវាងកន្លែងដែលគាត់ស្នាក់នៅបណ្ដោះអាសន្ន ហើយគាត់ចាកចេញពីកន្លែងមួយ ទៅកន្លែងមួយ ហើយនិងកន្លែងស្រុកកំណើត។

[០៩:៥៤:៣០]

ទី២ និយាយពីរបបកម្ពុជាប្រជាធិបតេយ្យវាជាក់លាក់ជាង ហើយប្រសិនបើយើងនិយាយខ្មែរក្រហមហ្នឹង វាស្ដាប់ទូទៅបាន ហើយបើនិយាយពីឆ្នាំ៧០, ៧១ ហ្នឹងក៏ត្រូវដែរ កាលណានិយាយពីខ្មែរក្រហមគេមានវត្តមានតាំងពីយូរណាស់មកហើយ តែបើកម្ពុជាប្រជាធិបតេយ្យ គឺជាក់លាក់ជាង។ បានន័យថា សំដៅលើ១៧ មេសា ៧៥ ហើយដល់៧៩ មក -- ០៦ មករា ៧៩។ អានេះ វាច្បាស់លាស់ព្រោះសួរអង្កន់នៅសំណួរឲ្យបានច្បាស់លាស់ទៅ ដើម្បីឲ្យគាត់ឆ្លើយនឹងវាចំ។ កាលណាសួរមិនច្បាស់លាស់ទេ គាត់ឆ្លើយទំនងជាលំបាក។

**លោក ស្រ៊ា រតនៈ៖**

បាទ លោកប្រធាន។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញពាក់ព័ន្ធនឹងទីកន្លែង និងការចូលកាន់ ចូលមកគ្រប់គ្រងដោយខ្មែរក្រហមហ្នឹង។ លោកបានឆ្លើយថា លោកត្រឡប់មករស់នៅភូមិកំណើតវិញ។ គឺ -- ហើយភូមិកំណើតហ្នឹង តាមដែលលោកបានឆ្លើយជម្រាបជូនអង្គសវនាការមុននេះ គឺនៅភូមិសំបួរមាស "ក" ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។ តើពេលដែលលោកត្រឡប់មករស់នៅភូមិកំណើតហ្នឹងខ្មែរក្រហមបានចូលមកគ្រប់គ្រងហើយឬនៅ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ ខ្ញុំវិលមកនៅស្រុកកំណើតវិញ ខ្មែរក្រហមចូលមកនៅហើយ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី គង់ សំអុន!

[០៩:៥៦:១៧]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមអធ្យាស្រ័យខាងសហព្រះរាជអាជ្ញាជាតិដែលខ្ញុំកាត់។ ទាក់ទងទៅនឹងចម្លើយរបស់លោកសាក្សី គាត់បានបញ្ជាក់ថា គាត់បានសម្ភាសពីរដង ហើយកន្លងមក យើងមាននៅក្នុងឯកសារនេះតែមួយទេ នៅសក្ខីកម្មរបស់គាត់។ អ៊ីចឹងសុំឲ្យសហព្រះរាជអាជ្ញាជួយ បញ្ជាក់ពីវត្តមានឯកសារនេះផង ថាតើមានពីរ ឬមួយមានតែមួយទេ។ បាទ សូមអរគុណ។

**លោក ស្រ៊ា រតនៈ៖**

ករណីនេះ លោកប្រធាន អនុញ្ញាតឲ្យខ្ញុំសួរបញ្ជាក់ ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ នេះជានីតិវិធីភាគីដែលពាក់ព័ន្ធនឹងរឿងក្ដីមានសិទ្ធិសួរ ប៉ុន្តែគប្បីគិតគូររឿងខ្លួនឯងជាជាង ទៅផ្ដល់ទៅឲ្យសក្ខីកម្ម -- ទៅដល់សាក្សីដែលជាគោលដៅនៃការសួរ។ ចង់ដឹងរឿងទាំងអស់ សូម្បីតែ នីតិវិធីតុលាការក៏សួរសាក្សីដែរ នោះដូចជាមិនទំនងទេ។

[០៩:៥៧:១៤]

**លោក ស្រ៊ា រតនៈ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** តើនៅពេលក្នុងអំឡុងពេលដែលលោករស់នៅក្នុងភូមិកំណើតហ្នឹង លោកមានប្រកបកិច្ច ការងារជាអ្វីដែរ? បានន័យថាមានមុខរបបជាអ្វីដែរ?

**លោក សំរិត មុយ៖**

**ឆ៖** ខ្ញុំរស់នៅក្នុងសហករណ៍ហ្នឹង។

**ស៖** លោកបន្តរស់នៅក្នុងសហករណ៍រហូត ឬក៏លោកត្រូវបានគេផ្ដល់តួនាទីជាអ្វីដែរនៅក្នុង

ភូមិនុ៎ង?

**ឆ៖** ខ្ញុំរស់នៅក្នុងសហករណ៍ ធ្វើការងារនៅក្នុងសហករណ៍ ប៉ុនគេឲ្យខ្ញុំធ្វើឈ្លបៗភូមិ។

**ស៖** សូមលោកជួយបញ្ជាក់កន្លែងនេះឲ្យច្បាស់បន្តិច លោកធ្វើជាឈ្លបភូមិ ឬក៏ឈ្លបឃុំ?

**ឆ៖** ពី៧៤ មករហូត៧៥ គឺខ្ញុំនៅឈ្លបភូមិ។

**ស៖** ចុះក្រោយមកទៀត បន្ទាប់ពីឆ្នាំ៧៥មក លោកប្តូរតួនាទី ឬក៏នៅអ៊ីចឹងដដែល?

**ឆ៖** ខ្ញុំ ក្រោយមកទៀត ខ្ញុំនៅតែសហករណ៍ដដែល ប៉ុនគេឲ្យនៅតែធ្វើឈ្លបភូមិហ្នឹងដដែល ការពារស្រុកភូមិ យាមកាម។

**ស៖** នៅ -- ដោយសារលោកផ្តល់ចម្លើយនៅចំពោះអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបសួរតាមរយៈឯកសារ E3/9346 ដែលក្នុងនោះមាន ERN ជាភាសាខ្មែរ 00235015, ERN ជាភាសាអង់គ្លេស 00235507 និង ERN ជាភាសាបារាំង 00283947 លោកធ្លាប់បានឆ្លើយថា៖ "ប៉ុន្តែគេឲ្យខ្ញុំចូលធ្វើឈ្លបឃុំ"។ អ៊ីចឹងសូមលោកបញ្ជាក់ន្លែងនេះឲ្យច្បាស់ទៅមើល៍ តើជាឈ្លបភូមិ ឬឃុំ? ហើយតើពីរហ្នឹងខុសគ្នាយ៉ាងម៉េច?

**ឆ៖** បាទ ដោយរឿងដែលខ្ញុំ ទី១ ដែលខ្ញុំធ្វើឈ្លបឃុំរហូតពីឆ្នាំ៧៥ ដល់គេឲ្យខ្ញុំទៅការដ្ឋានលើកភ្លឺ លើកអីបកមកវិញ គេសុំភូមិឲ្យខ្ញុំមកនៅ ប៉ុន្តែយាមកាមនៅកន្លែងឃុំ ប៉ុន្តែឃុំនោះនៅក្នុងសហ-ករណ៍ដែរ លោក។

[១០:០១:០១]

**ស៖** នៅត្រង់នេះ ខ្ញុំចង់សុំឲ្យលោកបញ្ជាក់តែមួយម៉ាត់ទេ តើជាឈ្លបភូមិ ឬឃុំ? ព្រោះនៅក្នុងចម្លើយដែលលោកបផ្តល់ឆ្លើយពីមុនមកនៅចំពោះមុខអ្នកស៊ើបអង្កេត លោកថាឈ្លបឃុំ។

**ឆ៖** បាទ រួចពីឆ្នាំ៧៥ ហ្នឹងរហូតមកដល់ ៧៦ គេបញ្ចូលខ្ញុំជាឈ្លបឃុំទៅវិញ។

**ស៖** តើតួនាទីរបស់លោកជាឈ្លបហ្នឹង សុំទោស -- ខ្ញុំសូមត្រឡប់មកសំណួរមួយវិញ។ លោកថាគេឲ្យចូលធ្វើជាឈ្លប។ "គេ" ហ្នឹងជាអ្នកណា?

**ឆ៖** បាទ មេឃុំគេបញ្ជូនមក មេភូមិគេឲ្យមកនៅជាមួយឃុំ។

**ស៖** ខ្ញុំស្តាប់ចម្លើយលោកអត់បាន តើមេភូមិ ឬមេឃុំដែលអ្នកចាត់តាំងលោកឲ្យធ្វើជាឈ្លបឃុំហ្នឹង? ហើយគាត់មានឈ្មោះអីដែរ?

**ឆ៖** បាទ មេភូមិ ឈ្មោះមិត្តអ៊ី ឲ្យខ្ញុំមកនៅកន្លែងឃុំហ្នឹងជាមួយ ចាត់តាំងឲ្យខ្ញុំមកនៅឃុំ។

រើសខ្ញុំមក ឲ្យនៅជាមួយឃុំ អ្នកយាមកាមមក។

**ស៖** គេចាត់ឲ្យលោកយាមកាមហ្នឹង យាមអីគេ? យាមមនុស្ស យាម ឬក៏យាមអី យាមយ៉ាងម៉េច លោកជួយបញ្ជាក់ឲ្យច្បាស់ទៅមើល ពាក្យថា "យាមកាម"ហ្នឹង យាមអី ហើយនៅកន្លែងណា?

**ឆ៖** បាទ រឿងយាមកាម ខ្ញុំធ្វើការដូចគេថ្ងៃអីចឹងទៅ យប់គេឲ្យយាម ប៉ុនយាមហ្នឹង មិនដឹងយាមអី បើយាមនៅតាមភូមិគេថា ដើម្បីនេះគ្រាន់តែយាមៗ ពួកខ្ញុំនាំគ្នាយាមទៅ។

**ស៖** គេមានប្រាប់លោកថា ឲ្យនៅចាំឃ្លាំ ឬក៏យ៉ាងម៉េចទេ យាម ឲ្យយាម ហើយលោកសកម្មភាពលោកនៅពេលនោះធ្វើអីដែរ?

**ឆ៖** ខ្ញុំកាលនោះជាឈ្លបហ្នឹងហើយ គេសម្រាប់ឲ្យយាមភូមិ គ្រាន់តែយាមមើលខុសត្រូវ យប់ព្រលប់ហ្នឹង មិនមានយាមអី យាមក្នុងភូមិហ្នឹងតែម្តង។

[១០:០៤:១៤]

**ស៖** ភូមិអី?

**ឆ៖** ខ្ញុំកាលនោះ គេឲ្យរស់ គេឲ្យខ្ញុំ កាលដែលយាមនោះ គេឲ្យទៅនៅឃុំ ខ្ញុំនៅក្នុងភូមិសាច់សូក្នុងសហករណ៍សាច់សូនោះ។

**ស៖** នៅឆ្នាំណាដែរ?

**ឆ៖** ឆ្នាំ១៩៧៦ ខ្ញុំនៅសាច់សូនោះ។

**ស៖** និយាយអំពីភូមិសាច់សូហ្នឹង តើភូមិសាច់សូហ្នឹងនៅចម្ងាយប៉ុន្មានពីភូមិសំបួរមាស ដែលជាភូមិកំណើតរបស់លោក?

**ឆ៖** ជាប់គ្នាលោក សំបួរមាស"ក" និង សាច់សូជាប់គ្នា។

**ស៖** ហើយនៅទីនោះ មានប្រជាជនប្រហែលជាប៉ុន្មានគ្រួសារដែរអង្កាល់សម័យនុ៎ង?

**ឆ៖** បាទ នៅច្រើនលោក សម័យនុ៎ងនៅគ្នាច្រើនណាស់។

**ស៖** ខ្ញុំគិតថាលោកមិនអាចដឹងចំនួនតួលេខជាក់លាក់ថាប៉ុន្មានឲ្យពិតប្រាកដទេ ប៉ុន្តែតើលោកអាចឲ្យជាតួលេខខ្ទង់រយ ប៉ុន្មានរយ ប៉ុន្មានពាន់បានទេ?

**ឆ៖** បាទ គ្រាន់ថា ខ្ញុំដឹងថាច្រើន អង្កាល់នុ៎ងនៅពេញភូមិគ្មានដែលទៅណាទេ ប៉ុន្តែរឿងចំនួនខ្ញុំអត់ដឹង ព្រោះខ្ញុំអត់ដឹងដែរ។

[១០:០៦:១៤]

**ស៖** ចុះពួកគាត់ទាំងអស់ហ្នឹង លោកអាចសម្គាល់បានទេជាខ្មែរទាំងអស់ ឬក៏មានជនជាតិដោយឡែកៗនៅក្នុងហ្នឹងដែរ?

**ឆ៖** បាទ រស់នៅហ្នឹងមានចាម មានខ្មែរ នៅសាច់សូ លោក។

**ស៖** បើនិយាយអំពីជនជាតិចាមវិញ តើនៅសាច់សូហ្នឹងមានចំនួនច្រើនគ្រួសារទេ?

**ឆ៖** បាទ ចំនួនចាមច្រើនជាង ខ្មែរតិចណាស់សាច់សូ សុទ្ធចាម។

**ស៖** តើពួកគាត់ហ្នឹងជាអ្នកដែលរស់នៅកន្លែងហ្នឹងតាំងពីដើមមក ឬក៏ជាអ្នកចំណូលស្រុក? បានន័យថាត្រូវបានគេបញ្ជូនពីកន្លែងផ្សេងឲ្យមកតាំងទីនៅកន្លែងហ្នឹង នៅពេលដែលលោកទៅដល់ហ្នឹង?

**ឆ៖** បាទ ស្រុកកំណើតគាត់តាំងពីដូនពីតាមកនៅហ្នឹង។

**ស៖** ពាក់ព័ន្ធនឹងប្រជាជនចាមនៅភូមិសាច់សូនេះដែរ តើលោកបានដឹងពីហេតុការណ៍ដែលមានការចាប់ជនជាតិចាមទាំងនោះទេ?

**ឆ៖** បាទ ក្រោយចុងឆ្នាំ៧៦ ចូល៧៧ គេឲ្យខ្ញុំរស់នៅតាមសហករណ៍វិញ បានឃើញគេចាប់ចាមបន្តពីក្រោយមក។

**ស៖** សូមលោកបញ្ជាក់កន្លែងហ្នឹងបន្តិច តើលោកឃើញគេចាប់ចាម ៗនៅឆ្នាំណា?

**ឆ៖** ឆ្នាំ១៩៧៧ ហ្នឹងលោក។

**ស៖** ចាប់ហ្នឹងក្នុងចំនួនប្រហែលប៉ុន្មានដែរ?

**ឆ៖** ចាប់ទាំងអស់អត់មានទុកទេ រួចតែមួយទេ ពីរនាក់ប្ដីប្រពន្ធ។

[១០:០៩:២៩]

**ស៖** បាទ សេចក្ដីថាចាមមួយភូមិសាច់សូហ្នឹងត្រូវបានចាប់ទាំងអស់ រួចតែមួយគ្រួ -- តែពីរនាក់ប្ដីប្រពន្ធទេ។ ខ្ញុំយល់អីចឹងត្រូវទេ តាមចម្លើយរបស់លោកឆ្លើយអម្បាញ់មិញនេះ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកមានប្រសាសន៍ថា ចាប់ទាំងអស់ បានន័យថាមួយគ្រួសារបើមានទាំងកុមារ មានទាំងកូនង៉ែតក៏គេចាប់ដែរ?

**ឆ៖** បាទ ព្រោះឃើញបណ្ដើរមក ព្រោះខ្ញុំនៅសហករណ៍ ផ្ទះបាយខ្ញុំនៅជាប់នឹងផ្លូវ ឃើញបណ្ដើរទាំងតូចទាំងតាចមកទាំងអស់ អត់មានទុកមួយទេលោក។

**ស៖** ចុះអ្នកដែលៗលោកលើកឡើងថារួចខ្លួនអំមិញហ្នឹង លោកបានដឹងទេ ថាហេតុអីបានរួច

ខ្លួន? គាត់អត់នៅក្នុងភូមិហ្នឹង ឬក៏គេមិនចាប់គាត់តែម្តង?

**ឆ៖** កាលនោះ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំមកនៅសហករណ៍លោក ប៉ុន្តែដល់នេះឃើញទ័ពមក ដល់ឃើញរស់នៅបានពីរនាក់គ្រួសារហ្នឹង។

**ស៖** លោកចង់មានប្រសាសន៍ថា នៅក្រោយពេលលោកត្រឡប់មកនៅភូមិហ្នឹងវិញ ឃើញតែពីរនាក់គ្រួសារ ឬក៏យ៉ាងម៉េចបានលោកអះអាងថាមានអ្នករួចខ្លួនតែពីរនាក់ប្តីប្រពន្ធ?

[១០:១១:២៧]

**ឆ៖** ព្រោះអង្កាល់នោះ ខ្ញុំនៅសហករណ៍ ខ្ញុំដេកយាមរោងពោត។ នៅរោងពោតឈ្មោះហ្នឹងគេរួចខ្លួនមកដេកជាមួយខ្ញុំនៅរោងពោតហ្នឹងលោក។

**ស៖** តើការចាប់ខ្លួនហ្នឹង គេធ្វើយ៉ាងដូចម្តេច? គេចាប់ប្រមូលម្តងមួយភូមិហ្នឹងតែម្តងឲ្យស្រេច ឬក៏គេចាប់ជាច្រើនលើកច្រើនសា?

**ឆ៖** ព្រោះខ្ញុំឃើញតែម្តងហ្នឹងលោក ចាមចាប់ប្រមូលមកទាំងអស់ ព្រោះខ្ញុំនៅនឹងបាយ ខ្ញុំអត់បានប៊ានចូលជិតគេផង គ្រាន់ឃើញបណ្តើរមក។

**ស៖** តើអ្នកណាជាអ្នកចាប់ខ្លួនពួកគាត់ទាំងអស់ហ្នឹង?

**ឆ៖** កាលនោះ ខ្ញុំអត់បានដឹងដែរលោក ព្រោះខ្ញុំមកនៅសហករណ៍ ប៉ុនគ្រាន់ថាចាប់ហ្នឹង ពួកនិរតីចូលទៅដល់នុ៎ងលោក?

**ស៖** ចុះនៅពេលដែលគេបញ្ជូនមនុស្សហ្នឹង មានអ្នកអមដំណើរ បានន័យថាអ្នកយាមជនដែលជនជាតិចាមដែលត្រូវគេចាប់ខ្លួនទាំងអស់ហ្នឹង លោកបានឃើញទេ មានចំនួនប៉ុន្មាននាក់? ខ្ញុំសំដៅលើអ្នកដែលបញ្ជូនមនុស្ស។

**ឆ៖** ខ្ញុំឃើញនៅពីចម្ងាយលោក អត់ប៊ានចូលជិតគេទេ ខ្ញុំនៅហូបបាយ ហូបបបរហ្នឹង ឃើញតែគេបណ្តើរ មិនដឹងមានប៉ុន្មាននាក់ផង ខ្ញុំអត់បានឃើញ។

[១០:១៣:៣៦]

**ស៖** ចុះលោកអាចសម្គាល់បានថាពួកគេជាអ្នកណា? មកពីក្រុមណាទេ?

**ឆ៖** ខ្ញុំអត់បានដឹង ព្រោះខ្ញុំអត់ប៊ានចូលជិតគេ អត់ដឹងនេះទេ ព្រោះខ្ញុំគិតតែធ្វើការងារនៅក្នុងសហករណ៍ ខ្ញុំអត់បានទៅពិនិត្យពីណាឯណា ព្រោះអត់ប៊ាន កំពុងតែនេះដែរ ខ្លាចគេ។

**ស៖** ចុះលោកធ្លាប់ឮសួរក្រុមកងដាវវែងទេ?

**ឆ៖** បាទ ក្រុមដាវវែង ពួកនិរតីហ្នឹង លោគេអ្នកបង្កើតមក គេបង្កើតអាក្រុមដាវវែងហ្នឹង។

**ស៖** តើលោកមានស្គាល់សមាជិកក្រុមដាវវែងណាខ្លះទេ?

**ឆ៖** ឃើញតែពួកសន្តិសុខហ្នឹងលីដាវ លីអី លីកាំបិត លីដាវ ខ្ញុំអត់ប៉ានមើលគេទេ។

**ស៖** តើពួកក្រុមដាវវែងហ្នឹង ខុសពីខាងក្រុមឈ្លបពួកលោកដូចម្ដេចដែរ? ពីរក្រុមហ្នឹងខុសគ្នាម៉េចដែរ?

**ឆ៖** ក្រុមដាវវែង ក្រុមពួកខ្ញុំខុសគ្នា។ ពួកខ្ញុំព្រលឹមឡើងចេញធ្វើការ យប់គ្រាន់យាមប៉ុណ្ណឹង។

**ស៖** ចុះពីរក្រុមហ្នឹងមានទំនាក់ទំនងគ្នាទេ? ធ្វើការមានទំនាក់ទំនងគ្នា ឬក៏ធ្វើការដាច់ដោយឡែកពីគ្នា?

**ឆ៖** បាទ កាលនោះអត់មានអីនេះទេ ព្រោះក្រុមដាវវែងគេបង្កើតក្រោយពួកខ្ញុំ។ ខ្ញុំមកនៅសហករណ៍ផុតទៅហើយ មិនដែលមានអីទំនាក់ទំនងគ្នា អត់ដែលស្គាល់គ្នាផង ពួកអស់ហ្នឹង។

**ស៖** បកទៅអ្នកដែលធ្វើការចាប់ខ្លួនជនជាតិចាមទាំងនោះវិញ ដែលលោកមើលពីចម្ងាយហ្នឹង ឃើញពួកគេមានប្រើបាស់អាវុធទេ?

**ឆ៖** អត់ប៉ានពិនិត្យទេលោក អត់បានពិនិត្យមើល ខ្លាចគេគិតថាម៉េច។ ហូបបបររួចប្រួចទៅធ្វើការងារវិញអត់បានពិនិត្យទេ អត់ប៉ានចូលជិតកៀកគេ។

[១០:១៦:៥១]

**ស៖** ចុះមុនពេលចាប់ខ្លួន លោកមានដឹងថាពួកទាំងនោះមានរៀបចំផែនការ ឬប្រជុំអីទេ?

**ឆ៖** កាលដែលខ្ញុំរស់នៅឯសាច់ស្ងួជាមួយបងប្អូនចាម អត់មានដឹងខ្លួនអីទេ គេរៀបចំអី លោក ប៉ុនដល់ពួកនិរតីចូលមកហ្នឹង គេហៅទៅប្រជុំដំណាក់ស្វាយប្រជាពលរដ្ឋទាំងអស់ គេហៅទៅប្រជុំដំណាក់ស្វាយ។ ក្រោយពីប្រជុំហ្នឹងរួច ចាប់ផ្ដើមចាប់ហ្នឹងហ្មង លោក។

**ស៖** ពេលនោះលោកបានចូលរួមប្រជុំទេ?

**ឆ៖** បាទ ចូលរួមប្រជុំទាំងអស់គ្នាលោក ព្រោះឲ្យតែនៅក្នុងសហករណ៍គេហៅទៅប្រជុំដំណាក់ស្វាយហ្នឹង ព្រោះនិរតីគេចូលទៅដល់ រួមគេចាប់ផ្ដើមចាប់រហូតមកតែម្ដង។

**ស៖** ចុះអ្នកណាជាអ្នកដឹងនាំកិច្ចប្រជុំនោះ?

**ឆ៖** ឈ្មោះ កាន ដែលនៅខាងនិរតី ចៅហ្វាយស្រុកហ្នឹងគេហៅឈ្មោះ កានៗ។ ខ្ញុំមិនដែលនេះប៉ុនឮគេហៅឈ្មោះ កានៗ។

**ស៖** គាត់និយាយអីខ្លះនៅពេលនោះ?

**ឆ៖** នៅពេលនោះ គេមាននិយាយអី គ្រាន់តែនិយាយថាឲ្យគោរពអង្គការ គោរពអីហ្នឹង រួចគេថាអំបោសធំណាស់ បោសអីម៉េចទេ រួចស្ដាប់បានតែប៉ុណ្ណឹង រួចខ្ញុំនាំគ្នាមកធ្វើការងារវិញមក។ បន្តបន្ទាប់មក គេ -- អត់បានចូលជិតគេ លោក។

**ស៖** តើនៅក្រោយពេលកិច្ចប្រជុំហ្នឹង រយៈពេលប៉ុន្មានដែរ ទើបមានការចាប់ៗជនជាតិចាមទាំងនោះ?

**ឆ៖** ខ្ញុំមិនចាំទេលោក ព្រោះខ្ញុំមកនៅសហករណ៍មក ចាប់ ប៉ុនមិនយូរប៉ុន្មានទេ។ វាប្រជុំរួមមិនបានប៉ុន្មានវាចាប់ ប៉ុនខ្ញុំអត់ចាំថ្ងៃ ចាំខែទេ។

**ស៖** តើមានកិច្ចប្រជុំប៉ុន្មានដែរ មុនពេលមានការចាប់ខ្លួនហ្នឹង? លោកធ្លាប់បានចូលរួមប្រជុំម្ដងអំមិញម្ដងហើយ។ តើមានកិច្ចប្រជុំផ្សេងទៀតទេ មុននឹងមានការចាប់ខ្លួនជនជាតិចាមទាំងនោះ?

**ឆ៖** អត់ទេ វាហៅតែប្រជាពលរដ្ឋទៅតាមសហករណ៍ទាំងអស់គ្នា ទៅប្រជុំតែម្ដងហ្នឹងរួចអត់មានប្រជុំអីទៀត លោក។ គិតតែធ្វើការងារ អត់មានគិតបានអីទៅប្រជុំទៀតទេ។

[១០:១៩:៤៥]

**ស៖** និយាយអំពីកិច្ចប្រជុំនោះ តើក្រៅពីប្រជាពលរដ្ឋមានថ្នាក់ដឹកនាំណាផ្សេងចូលទេ ក្រៅពីកាន ហ្នឹងទៅទៀត? មានខាងឈ្លប មានខាងកងដាវវែងអីចូលរួមទេ?

**ឆ៖** ការប្រជុំនោះ មិនទាន់ឃើញមានទេលោក មានតែប្រជាពលរដ្ឋទេ នាំគ្នាទៅប្រជុំ ហៅទៅប្រជុំហ្នឹង។ បាទ ក្រោយមកទៀត បានឃើញពួកអាដាវវែងគេបង្កើតអីហ្នឹង ឆ្វេចឆ្វាច មិនបានចូលជិតគេផង។

**ស៖** លោកចូលរួមប្រជុំកាលនោះ ក្នុងនាមលោកជាប្រជាពលរដ្ឋ ឬក៏ជាឈ្លបឃុំ?

**ឆ៖** ខ្ញុំជាប្រជាពលរដ្ឋគេឲ្យមកនៅតាមសហករណ៍ហើយ។

**ស៖** ពាក់ព័ន្ធនឹងការចាប់ខ្លួនដែលលោកបានឃើញនៅពេលនោះ តើគេធ្វើឡើងនៅពេលថ្មើរណា?

**ឆ៖** គេចាប់នៅពេលល្ងាចលោក ព្រោះខ្ញុំមកហូបបបរឡើងពីធ្វើការមក ហូបបបរ ឃើញគេបណ្ដើរមក។

**ស៖** លោកអាចមាន អាចដឹងពីម៉ោងប្រហាក់ប្រហែលទេ ល្ងាចហ្នឹងម៉ោងប្រហែលប៉ុន្មានដែរ?

**ឆ៖** ល្ងាចហ្នឹងល្បាក់ម៉ោងប្រាំអីជាងហើយលោក ព្រោះខ្ញុំឡើងមកហូបបបរវិញ ន្ធលនឹងទៅ

ធ្វើការវិញ។

**សៈ** ចុះក្នុងការចាប់ខ្លួនហើយបណ្ដើរទៅហ្នឹង លោកបានឃើញមានសកម្មភាពអីខ្លះ មានជាការចាប់ចង ឬក៏វាយដំ ឬក៏ធ្វើទារុណកម្មអីទេ?

**ផៈ** បាទ អត់បានឃើញទេលោក ព្រោះមើលតែពីចម្ងាយ អត់ប៊ានចូលជិតគេផង។ ការដែលចាប់នឹងទៀតក៏យើងនៅហ្នឹងសហករណ៍ឯនេះ ខ្ញុំអត់ដឹងផង ខ្ញុំបានឃើញយ៉ាងម៉េចៗ សកម្មភាពវាយ៉ាងម៉េចផង ឃើញតែបណ្ដើរមក យើងនៅឆ្ងាយអត់ប៊ានចូលជិតគេទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងជាតិ។ អរគុណសាក្សី។ បាទ ឥឡូវនេះ ដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ហើយចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងដប់មួយ ខ្វះម្ភៃនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:២២នាទី ដល់ម៉ោង ១០:៤០នាទី)*

[១០:៤០:៤៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ស្រ៊ា រតនៈ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ស្រ៊ា រតនៈ៖**

**ស៖** បន្តពីសំណួរដែលខ្ញុំបានលើកឡើងមុនម៉ោងសម្រាកនេះ តើលោកដឹងថាគេចាប់មនុស្សទាំងនោះយកទៅណាទេ?

**លោក សំរិត មុយ៖**

**ឆ៖** គេចាប់យកទៅបញ្ចូលក្នុងវត្តអូរត្រកួនបាទ។

**ស៖** និយាយអំពីវត្តអូរត្រកួននេះ តើវត្តអូរត្រកួនហ្នឹងជាស្អីដែរ បានគេយកមនុស្សទៅហ្នឹង?

**ឆ៖** ជំនាន់និរតីចូលមក គេយកវត្តអូរត្រកួនធ្វើកន្លែងសន្តិសុខលោក។

[១០:៤២:១៤]

**ស៖** វត្តហ្នឹងមានទីតាំងស្ថិតនៅកន្លែងណាដែរ? បានន័យថានៅភូមិណា? ឃុំណា? ស្រុកណា?

**ឆ៖** វត្តហ្នឹងនៅក្នុងភូមិសំបួរមាស “ក” តែម្តង ឃុំពាមជីកង ស្រុកកងមាស។

**ស៖** តើវត្តហ្នឹងមានចម្ងាយប្រហែលប៉ុន្មានគីឡូដែរពីភូមិសាច់សូទៅ?

**ឆ៖** ពីភូមិសាច់សូមកវត្តអូរត្រកួនហ្នឹង ១គីឡូជាងបន្តិចទេ។

**ស៖** លោកថាវត្តនេះត្រូវបានគេយកទៅប្រើប្រាស់ជាមន្ទីរសន្តិសុខនៅពេលនិរតីចូលឆ្នាំណាដែរ?

**ឆ៖** ចុងឆ្នាំ៧៦ ចូល៧៧ ហ្នឹងតែម្តងលោក។

**ស៖** តើមន្ទីរសន្តិសុខនោះគ្របបណ្តប់លើភូមិសាស្ត្រភូមិឃុំស្រុកណាខ្លះ? ខ្ញុំចង់សំដៅ -- ចង់សួរថា តើមន្ទីរសន្តិសុខនេះ ប្រើប្រាស់សម្រាប់មនុស្សដែលគេបញ្ជូនមកពីណាខ្លះ?

**ឆ៖** ខ្ញុំអត់ដឹងទេត្រង់ហ្នឹងលោក ព្រោះឃើញតែបញ្ជូនមក តែមិនដឹងបញ្ជូនមកពីណាខ្លះទេ។ ព្រោះអត់ដឹង យើងនៅសហករណ៍។

**ស៖** គេបញ្ជូនមនុស្សទាំងនោះទៅវត្តអូរត្រកួនហ្នឹង គេបញ្ជូនយកធ្វើអី?

**ឆ៖** តាមខ្ញុំដឹងពេលនោះ គឺគេយកទៅសម្លាប់តែម្តងលោក។

**ស៖** ម៉េចបានលោកឆ្លើយថា គេយកទៅសម្លាប់នៅទីនោះ? លោកមានអ្វីបញ្ជាក់ទេ?

**ឆ៖** បាទ អ្នកដែលចូលទាំងប៉ុន្មានគេយកទៅអត់មានវិលវិញទេលោក ទៅបាត់ៗតែម្តង គ្មានឃើញវិលមកវិញទេ ខ្ញុំគ្រាន់ដឹងប៉ុណ្ណឹង។

**ស៖** លោករស់នៅចម្ងាយប៉ុនណាពីៗវត្តនេះ ពីវត្តអូរត្រកួននេះ?

**ឆ៖** បាទ ពីផ្ទះខ្ញុំទៅវត្តអូរត្រកួនន៎ុង ប្រហែលជា ២០០ម៉ែត្រជាង។

**សៈ** តើលោកដឹងព្រឹត្តិការណ៍ អាចបានដឹងពីព្រឹត្តិការណ៍នៅក្នុងវត្តដែលបានកើតឡើងនៅក្នុងវត្តអូរត្រកួននេះទេ ដែលលោកអម្បាញ់មិញលើកឡើងថា មនុស្សទាំងអស់ត្រូវបានគេសម្លាប់ហ្នឹង?

[១០:៤៦:៣៥]

**ឆៈ** ព្រោះខ្ញុំបានដឹងពេលណាដែលវាត្រូវធ្វើការសម្លាប់ វាចូលទៅហ្នឹងខ្ញុំឮចាក់មីក្រូយប់ ខ្ញុំមកពីធ្វើការវិញ តែចាក់មីក្រូពេលណាគឺមនុស្សគ្មានបានឃើញមកវិញទេ។ ខ្ញុំអ៊ីចឹងបាន ខ្ញុំថាមុខជាយកទៅសម្លាប់ចោលអត់មានទុកទេ។

**សៈ** សំឡេងមីក្រូលោកឮញឹកញាប់ទេ?

**ឆៈ** ក្រោយពីខ្ញុំមកពីធ្វើការយប់ជាន់ទឹកជាន់អីមក ជួនណាបីបួនប្រាំថ្ងៃ មួយអាទិត្យអីឮម្ដងអ៊ីចឹង។ វាចាក់ ត្រឹមចាក់មីក្រូ ឮ មុខតែវាសម្លាប់ទៀតហើយ។

**សៈ** ជាទូទៅលោកឮស្គរសំឡេងមីក្រូនេះពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ?

**ឆៈ** វាចាក់ច្រើនម៉ោងដប់ ម៉ោងអីដែលខ្ញុំមកពីធ្វើការហ្នឹង ដប់យប់លោក។

**សៈ** បានន័យថាមីក្រូហ្នឹងចាក់ចាប់ផ្ដើមពីម៉ោងដប់តទៅ អ៊ីចឹងមែនទេបាទ?

**ឆៈ** បាទ លោកពិតមែន។

**សៈ** ដល់ម៉ោងប៉ុន្មានដែរ?

**ឆៈ** បាទ ពេលហ្នឹង វាចាក់ប្រហែលជាមួយម៉ោងពីរម៉ោងបាត់ឮសំឡេងមីក្រូនុំងហើយ។

**សៈ** ចុះក្រៅពីសំឡេងមីក្រូហ្នឹង លោកមានឮសំឡេងអីផ្សេងទៀតទេ?

[១០:៤៨:៤២]

**ឆៈ** ជួនណាខ្ញុំនៅផ្ទះហ្នឹង ឮសំឡេងស្រែកឲ្យជួយលោក ឮ។

**សៈ** ជាសំឡេងរបៀបម៉េចដែរលោកអាចបញ្ជាក់ឲ្យបានច្បាស់ជាងនេះបានទេ? ជាសំឡេងមនុស្សស្រី ជាសំឡេងមនុស្សប្រុស ហើយការស្រែកឲ្យជួយនោះ ដង្ហើយឲ្យជួយយ៉ាងដូចម្ដេចដែរលោក? សូមលោកជួយបញ្ជាក់ឲ្យច្បាស់ជាងនេះបន្តិចមើល៍?

**ឆៈ** ជួនណាឮសំឡេងស្រែកឲ្យ "ជួយផង" គ្រាន់តែពាក្យថា "ជួយផង" ប៉ុន្តែមិនដឹងស្រីមិនដឹងប្រុសទេលោក ព្រោះមិនបាននេះដែរ ព្រោះផ្ទះខ្ញុំនៅឆ្ងាយពីទីវត្តនោះដែរ។

**សៈ** សំឡេងមនុស្សដែលស្រែកដង្ហើយហ្នឹងលោកឮដំណាលគ្នានឹងការចាក់មីក្រូ ឬក៏ឮក្នុងពេលផ្សេងគ្នា?

**ឆ៖** ឮពេលចាក់មីក្រូហ្នឹងលោក ពេលណាឮចាក់មីក្រូ ឮសំឡេងស្រែកឲ្យ ជួយផង។

**ស៖** ចុះចំពោះអ្នកដែលត្រូវចាប់ខ្លួនពីភូមិសាច់សូមកហ្នឹង ម៉េចបានលោកសម្គាល់បានថា គេនាំយកទៅវត្តអូរត្រកួន?

**ឆ៖** ព្រោះខ្ញុំ រោងបាយខ្ញុំនៅចំទ្វារវត្តចូលទៅក្នុងវត្តហ្នឹងតែម្ដងទាន។ នៅក្រៅហ្នឹង ផ្ទះបាយខ្ញុំហ្នឹង ហើយទ្វារវត្ត ហើយចូលទៅវត្តអូរក្រកួន ប៉ុននាំតាមទ្វារវត្តហ្នឹងចូលទៅ។

**ស៖** តើនៅថ្ងៃដែលលោកឃើញក្រុមអ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះនាំ ត្រូវបាននាំបញ្ចូលទៅក្នុងវត្តហ្នឹង លោកមានឮសូរសំឡេងចាក់មីក្រូអ៊ីចឹងដែរទេ?

**ឆ៖** បាទ គេចាប់ទៅថ្ងៃហ្នឹង យប់ហ្នឹងវាចាក់មីក្រូហើយលោក។

**ស៖** ប៉ុន្តែកាលនោះ លោកឮទេ នៅពេល -- ក្រោយពេលដែលឃើញគេនាំមនុស្សទាំងនោះ មនុស្សដែលត្រូវចាប់ខ្លួនពីភូមិសាច់សូហ្នឹង យកទៅចូលក្នុងវត្ត តើយប់នោះលោកបានឮសូរសំឡេងចាក់មីក្រូទេ?

**ឆ៖** បាទខ្ញុំជម្រាបថា ថ្ងៃដែលឲ្យតែវាចាប់ចូលហ្នឹង គឺវាចាក់មីក្រូហ្នឹងតែម្ដងលោក។ គេចាប់ពីនេះហ្នឹងទៅ គឺយប់ហ្នឹងគឺវាចាប់មីក្រូហ្នឹងតែម្ដង។

[១០:៥១:៣៩]

**ស៖** ខ្ញុំមុននេះខ្ញុំសួរសំណួរទូទៅពាក់ព័ន្ធនឹងមន្ទីរសន្តិសុខនេះ ប៉ុន្តែនេះខ្ញុំសួរជាក់លាក់ពាក់ព័ន្ធនឹងអ្នកដែលនាំមកពីអំពីភូមិសាច់សូ គឺថ្ងៃដែលគេនាំមក ប្រជាជនមកពីភូមិសាច់សូហ្នឹង។ តើការចាក់មីក្រូនេះមានរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំបានជម្រាបហើយ ចាក់ប្រហែលជាមួយម៉ោង ទៅ ពីរម៉ោងទេលោក។

**ស៖** លោកធ្លាប់ចូលទៅក្នុងបរិវេណវត្តហ្នឹងទេ?

**ឆ៖** មិនប៊ានជិតទេលោក កាលនោះអត់ប៊ានជិតទេ មានពីណាមួយប៊ានទៅជិតទៅក្បែរទេ។

**ស៖** មានការហាមប្រាម ឬក៏លោកមិនប៊ានទៅខ្លួនឯងកាលនោះ?

**ឆ៖** មិនប៊ានតែម្ដងលោក ព្រោះទោះយើងជាកសិករយើងនៅធ្វើនេះនុ៎ង អត់ប៊ានទៅចូលជិតកន្លែងគេទេ កន្លែងនុ៎ង អត់ប៊ានពីណាចូលជិតទេ ទាំងគេទាំងខ្ញុំ។

**ស៖** ចុះវត្តអូរត្រកួននេះដំណើរការ ចង់សំដៅថា គេប្រើប្រាស់ជាមន្ទីរសន្តិសុខនេះរហូតដល់ពេលណាបានឈប់?

**ឆ៖** ម៉ាដាច់យើង៧៩ហ្នឹងតែម្តងលោក។

**ស៖** លោកស្គាល់ប្រធានមន្ទីរសន្តិសុខហ្នឹងឈ្មោះអីទេ?

**ឆ៖** កាលនុ៎ងមិនដឹងទេ ប៉ុនខ្ញុំឮគេហៅថាឈ្មោះ អាហ៊ាន១ នៅនិរតី។

**ស៖** ប្រធានសន្តិសុខហ្នឹងតែម្នាក់ហ្នឹងតាំងពីដើម តាំងពីចាប់កកើតមក រហូតទៅដល់បញ្ចប់តែម្តង ឬក៏គាត់ត្រូវបានជំនួសដោយអ្នកណា ឬក៏គាត់ជំនួសអ្នកណា?

**ឆ៖** វាមកកើតហ្នឹង វាមកឈរហ្នឹងតែម្តងលោក ខាងនិរតីមករៀបចំនេះហ្នឹង វាអាហ៊ាន វាមកកាន់កាប់ទល់នឹង៧៩ហ្នឹង។

**លោក ស្រ៊ា រតនៈ៖**

សូមអរគុណលោកប្រធាន។ សូមការអនុញ្ញាតប្រគល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ។

[១០:៥៤:៤២]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបាទ!

**លោក វីល្លៀម ស្មីត៖**

អរុណសួស្តីលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម មេធាវីការពារក្តី សាធារណជន។ ជម្រាបសួលោកសាក្សី។

លោកប្រធាន ខ្ញុំចង់បង្ហាញផែនទីមួយនៃទីកន្លែងដែលគាត់ធ្លាប់រស់នៅ។ សូមបង្ហាញនៅលើអេក្រង់ គឺឯកសារ E3/9145។ ផែនទីនេះគឺធ្វើឡើងនៅក្នុងឆ្នាំ១៩៨៣ នៅក្រាំងមាស។ នៅគឺជាសម្រង់ចេញពីផែនទីនេះ។ ផែនទីនេះក៏វាធំដែរ ដូច្នេះងាយស្រួលឲ្យសាក្សីពិនិត្យមើល។ ហើយមានការកែប្រែខ្លះៗនៅជាឈ្មោះជាភាសាខ្មែរ ហើយក៏មាន *បាយឡាយ* នៅចំទីកន្លែងនៅលើផែនទីនេះផងដែរ។ ដូច្នេះយើងខ្ញុំសូមការអនុញ្ញាតឲ្យមន្ត្រីតុលាការផ្តល់នូវផែនទីជាក្រដាសនេះទៅសាក្សីមើលផងដែរ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំក៏សុំការអនុញ្ញាតបង្ហាញនូវផែនទីនេះនៅលើអេក្រង់កុំព្យូទ័រផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

[១០:៥៦:៥៨]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** បាទ ឥឡូវនេះមាននៅលើអេក្រង់ហើយ។ លោកសាក្សីបើពិនិត្យទៅមើលផែននេះ ជាផែនទីនៃតំបន់ឃុំពាមជីកង ហើយផែនទីនេះបញ្ជាក់ពីឈ្មោះភូមិដែលលោករស់ គឺសំបួរមាស “ក”។ ហើយក៏បង្ហាញអំពីសាច់ស្វ ភូមិដែលលោករស់នៅដែរ ក៏ដូចជាបង្ហាញពីភូមិនានានៅជុំវិញភូមិរបស់លោកផងដែរ។ បើលោកពិនិត្យមើលផែនទី តើការកំណត់ភូមិនេះ ដែលលោកពិនិត្យមើលទៅនេះ តើត្រឹមត្រូវដែរទេ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ ត្រឹមត្រូវលោក។

**ស៖** ហើយបើសិនណាយើងពិនិត្យមើលផែនទីនេះ សុំបញ្ជាំងឡើងវិញ។ នៅដំណាក់ស្វាយពិបាកអានបន្តិចជាភាសាអង់គ្លេស ប៉ុន្តែតើពីភូមិដំណាក់ស្វាយទៅ -- តើពីដំណាក់ស្វាយទៅសាច់ស្វ មានចម្ងាយប៉ុន្មានលោក?

**ឆ៖** បាទ ដំណាក់ស្វាយមកសាច់ស្វ ប្រហែល១គីឡូជាងបន្តិច លោក។

**ស៖** ហើយលោកបានឆ្លើយថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដំបូងឡើយលោករស់នៅភូមិសំបួរមាស “ក” ហើយក្រោយមកលោកក៏ទៅរស់នៅសាច់ស្វ មួយរយៈ។ តើត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវលោក។

**ឆ៖** ហើយនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ ក្រោយពេលលោករស់នៅសាច់ស្វ តើលោកស្នាក់នៅទីនោះរហូតទៅដល់ឆ្នាំ១៩៧៩ ឬក៏លោកត្រឡប់មករស់នៅភូមិសំបួរមាស “ក” វិញ?

**ឆ៖** បាទ ចុងឆ្នាំ ៧៦, ៧៧ គេឲ្យខ្ញុំមកនៅសំបួរមាស “ក” វិញ នៅក្នុងសហករណ៍។

[១១:០០:០០]

**ស៖** សូមអរគុណ ហើយលោកស្នាក់នៅសំបួរមាស “ក” នេះរហូតដល់របបខ្មែរក្រហមដួលរំលំឆ្នាំ១៩៧៩។ អ៊ីចឹងឬក៏អត់ទេ?

**ឆ៖** បាទ អ៊ីចឹងមែនលោក។

**សៈ** ដូច្នេះ នៅពេលខ្មែរក្រហមចូលមកដល់តំបន់របស់លោកជាលើកដំបូង មុនរបបកម្ពុជាប្រជាធិបតេយ្យរហូតដល់ពេលខ្មែរក្រហមចាញ់ គឺថានៅឆ្នាំ១៩៧៩ គឺទី១ លោកនៅរស់នៅសាច់ស្វ និងភូមិទី២នោះគឺថា លោករស់នៅសំបួរមាស "ក"។ តែពីរភូមិហ្នឹងទេ ក្នុងមួយរយៈកាលនោះ?

**ឆៈ** បាទ។

**សៈ** ហើយលោកក៏បានឆ្លើយទៅនឹងសំណួរនេះផងដែរ។ តើសាច់ស្វ និងសំបួរមាស "ក" ភូមិទាំងពីរនេះ នៅដាច់ពីគ្នាដោយមានដី នៅដាច់ពីគ្នា ឬក៏ភូមិនេះវាមានព្រំប្រទល់ជាប់គ្នាតែម្តងភូមិទាំងពីរនេះ?

**ឆៈ** បាទ ជាប់គ្នាលោក ជាប់គ្នា។

**សៈ** ហើយបើយើងមើលភូមិសំបួរមាស "ខ" តើសំបួរមាស "ក" មានចម្ងាយប៉ុន្មានពីសំបួរមាស "ខ"?

**ឆៈ** មិនឆ្ងាយពីគ្នាទេ ភូមិអស់ហ្នឹងជាប់គ្នារហូតតែម្តង ជាប់ៗគ្នាបន្តទៅ "ក" រួច "ខ" ហ្នឹងតែម្តង។

**សៈ** ហើយយើងខ្ញុំសូមឲ្យបង្ហាញផែនទីនៅលើអេក្រង់កុំព្យូទ័រម្តងទៀត។ អ៊ីចឹង ពីចំណុចកណ្តាលនៃភូមិសំបួរមាស "ខ" ទៅចំណុចកណ្តាលនៃសំបួរមាស "ក" តើមានចម្ងាយប៉ុន្មានពីគ្នា? ទោះណាជាភូមិពីរនេះមានព្រំប្រទល់ជាប់គ្នាក្តី តែខ្ញុំសួរចំណុចកណ្តាលនៃភូមិសំបួរមាស "ខ" ទៅដល់ចំណុចកណ្តាលភូមិនៃភូមិសំបួរមាស "ក"។ ចម្ងាយប៉ុន្មានពីគ្នា?

**ឆៈ** បាទ "ក" ទៅ "ខ" ហ្នឹង បើនិយាយពីគិតព្រំប្រទល់ជាប់គ្នាហ្នឹង ប្រហែលជាចម្ងាយមិនបាន៥០០ម៉ែត្រ ព្រោះជាប់គ្នាតែម្តង ព្រំប្រទល់ជាប់គ្នា "ក" និង "ខ" ជាប់គ្នាតែម្តង។

[១១:០៣:២០]

**សៈ** សូមអរគុណ។ លោកក៏បានឃើញព្រំប្រទល់ឃុំអង្គរបានដែរ និងព្រំប្រទល់ឃុំ -- ពីព្រំប្រទល់ឃុំពាមជីកង មកព្រំប្រទល់ឃុំអង្គរបាននេះ មានចម្ងាយប៉ុន្មាន?

**ឆៈ** តាមខ្ញុំ មិននេះដែលលោក ប៉ុនថាបើពីពាមជីកងទៅអង្គរបាន វាព្រំប្រទល់ជាប់គ្នាប្រហែលជា ១គីឡូកន្លះទេចេញព្រំឃុំពាមជីកងទៅឃុំអង្គរបាន។ អានេះ បើគិតព្រំប្រទល់ជាប់គ្នា។

**សៈ** សូមអរគុណ។ វាមិនច្បាស់ប៉ុន្មានទេ បើមើលផែនទីនេះទៅ។ ប៉ុន្តែភូមិសំបួរមាស សាច់ស្វ គឺថាភូមិទាំងពីរនេះគឺនៅតាមបណ្តោយទន្លេមេគង្គ យើងឃើញទន្លេមេគង្គ គឺថានៅក្បែរភូមិ

ហ្នឹង តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវលោក ដងទន្លេទាំងអស់។

**ស៖** បាទ សូមអរគុណ។ បើយើងពិនិត្យមើលផែនទីម្តងទៀត មើលសំបួរមាស “ក” គឺភូមិរបស់លោក លោកបានឆ្លើយថា លោកបាននិយាយអំពីវត្តអូរត្រកួន ថាវត្តអូរត្រកួនស្ថិតនៅក្នុងភូមិនេះ។ តើត្រឹមត្រូវទេ?

**ឆ៖** ត្រឹមត្រូវហើយលោក។

**ស៖** ហើយបើយើងមើលភូមិដំណាក់ស្នាយ តើភូមិដំណាក់ស្នាយស្ថិតចំណុះឲ្យៗឃុំពាមជីកងឬ?

**ឆ៖** បាទ នៅក្នុងឃុំពាមជីកង។

**ស៖** ហើយបើយើងមើលទៅភូមិរកាគយ គឺវានៅខាងកើតភូមិសាច់ស្ង គឺតើវាស្ថិតនៅក្នុងឃុំខុសគ្នា ឬក៏អត់លោក?

**ឆ៖** បាទ ខុសគ្នាលោក។

[១១:០៦:២៣]

**ស៖** ដូច្នេះ នៅពេលលោកធ្វើការជាឈ្លបឃុំ តើវាត្រឹមត្រូវដែរឬទេថា លោកធ្វើការទាំងភូមិសំបួរមាស “ខ” ផង និងភូមិពាមជីកងផង? តើនេះ ទីកន្លែងនេះ ជាទីកន្លែងដែលលោកបំពេញតួនាទីលោកជាកងឈ្លបហ្នឹងឬ?

**ឆ៖** បាទ។

**ស៖** លោកមានម៉ូតូទេកាលនុ៎ង មានម៉ូតូជិះពីភូមិមួយទៅភូមិមួយដែរទេ នៅពេលដែលលោកធ្វើជាកងឈ្លបហ្នឹង?

**ឆ៖** មានតែដើរនឹងជើងទេលោក កាលនុ៎ងគ្មានទេ តែកង់គ្មានផង។

**ស៖** ដូច្នេះ តើត្រឹមត្រូវដែរទេថាភារកិច្ចជាឈ្លប គឺលោកធ្វើដំណើរចម្ងាយប្រហែលជាបួនគីឡូម៉ែត្រ បាទសូមទោសៗ គឺថាប្រហែលជា១គីឡូម៉ែត្រពីភូមិអង្គរបានទៅពាមជីកង។ តើព្រំប្រទល់ពីអង្គរបានទៅពាមជីកង មានចម្ងាយប្រហែលប៉ុន្មានដែរ លោកប្រហែលជាបានឆ្លើយម្តងហើយ ប៉ុន្តែសុំជួយឆ្លើយម្តងទៀត។

**ឆ៖** បើនិយាយពីព្រំប្រទល់ពាមជីកងនេះ ខ្ញុំគ្រាន់តែដឹងព្រំប្រទល់ហ្នឹង វាប្រហែលជា១,៥គីឡូ

លោក។

**ស៖** សូមអរគុណ។ ហើយលោកបានឆ្លើយថា នៅពេលលោករស់នៅភូមិសំបួរមាស “ក” វត្ត ៗនុំង គឺថាមានចម្ងាយប្រហែលជា២០០ម៉ែត្រពីផ្ទះរបស់លោក លោកឆ្លើយថាអ៊ីចឹង។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវលោក។

**ស៖** សូមអរគុណ។ នៅពេលដែលយើងកំពុងតែពិនិត្យមើលផែនទីជាមួយគ្នានេះ សូមលោកជម្រាបជូនតុលាការអំពីស្តាត១ពាម បាទជួយជម្រាបលម្អិតបន្តិចមើល តើវាជាអ្វីដែរ គេហៅថា “ស្តាតពាម” ហ្នឹង?

**ឆ៖** ស្តាតពាម កន្លែងពាមជីកង ស្តាតពាមវានៅជាប់ឆ្លងពីព្រែកស្ពានពាមជីកងទៅចូលដល់ឃុំរកាគយ។ ស្តាតហ្នឹង តាំងស្តាតចាស់ពីដើមមកសម្រាប់នេះហ្នឹង កន្លែងហ្នឹង ស្តាតពីបរមបុរាណមក។

**ស៖** តើវាជាទីលានបាល់ទាត់ ឬក៏វាជាអ្វីដែរ និយាយពីស្តាតពាមហ្នឹង?

**ឆ៖** ទីលានបាល់ទាត់តាំងពីសង្គមមកលោក តាំងពីសង្គមចាស់មករហូតទាល់ឥឡូវហ្នឹង។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើពីស្តាតទៅដល់ភូមិសំបួរមាស “ក” មានចម្ងាយប៉ុន្មាន?

**ឆ៖** បាទ ពីស្តាតមកភូមិសំបួរមាស“ក” ១,៥គីឡូលោក ពីស្តាតហ្នឹងមកកន្លែងភូមិខ្ញុំនៅ។

[១១:១០:៥០]

**ស៖** បាទ សូមអរគុណ។ សូមបញ្ចប់ត្រឹមផែនទីនេះចុះ ហើយសូមអរគុណនៅក្នុងការជួយបញ្ជាក់បង្ហាញអំពីទីតាំងភូមិសាស្ត្រក្នុងតំបន់របស់លោក។ ខ្ញុំសួរលោកមួយចំនួនតូចអំពីកិច្ចប្រជុំដែលលោកបានចូលរួមនៅដំណាក់ស្នាយ។ លោកបានឆ្លើយថា លោកបានចូលរួមនៅក្នុងអង្គប្រជុំនោះ ហើយអ្នកភូមិត្រូវបានគេឲ្យទៅចូលរួមប្រជុំ ហើយក៏មានលេខាស្រុក ក៏មានវត្តមាននៅក្នុងអង្គប្រជុំនេះដែរ។ ដែលនៅក្នុងអង្គប្រជុំនេះគាត់បានឲ្យ សុំឲ្យប្រជាជនគោរពអង្គការ ហើយនិងធ្វើការឲ្យៗបានខ្លាំង។ លោកចាំទេអំពីអង្គប្រជុំមួយនេះ?

**ឆ៖** បាទ ចាំៗលោក ចាំ។

**ស៖** ហើយលោកបានឆ្លើយថា កាន ជាអ្នកដឹកនាំកិច្ចប្រជុំនេះ។ ហើយ កាន នេះគឺថាមកពីភូមិភាគនិរតី។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រឹមត្រូវលោក។

**ស៖** ប៉ុន្តែក្រោយមក កាន ហ្នឹងគឺថាគាត់ធ្វើជាលេខាស្រុកកងមាស ត្រឹមត្រូវដែរឬអត់លោក?

**ឆ៖** បាទ ត្រឹមត្រូវលោក។

**ស៖** តើលោកនៅចាំថា លោកបានទៅចូលរួមក្នុងអង្គប្រជុំមួយទៀត ប្រហែលជាកិច្ចប្រជុំ -- គឺកិច្ចប្រជុំមួយទៀតនៅស្ពាតពាម នៅដើមឆ្នាំ១៩៧៧ លោកចាំទេ?

**ឆ៖** បាទ អត់បានចាំទេ ១៩៧៧ ហ្នឹងខ្ញុំមិនដែលបានទៅប្រជុំផង។

**ស៖** នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកបានចូលរួមប្រជុំជាមួយលេខាតំបន់ឈ្មោះៗ អាន ដែរទេ? ហើយនិងលេខាស្រុកៗឈ្មោះ កាន នេះ ទាំងពីរនាក់នេះលោកធ្លាប់បានចូលរួមប្រជុំទេ?

**ឆ៖** បាទ មិនដែលបានចូលរួមប្រជុំទេ ព្រោះខ្ញុំមកនៅសហករណ៍គ្មានតួនាទីប្រជុំជាមួយពួកវានុ៎ងទេ។

[១១:១៣:៥៥]

**ស៖** តើលោកធ្លាប់ឮអំពីកិច្ចប្រជុំនៅស្ពាតពាមពីអ្នកដទៃទេ ធ្លាប់ឮពីអ្នកដទៃទេ?

**ឆ៖** មិនបានទេ គិតតែពីធ្វើការលោកកាលនោះ ខ្ញុំមិនដែលបានទេ ព្រោះយើងអត់មានបានទៅទំនាក់ទំនងពីភូមិមួយទៅភូមិមួយ ដឹងតែធ្វើការទាល់ៗល្ងាចតែម្តង យប់ទាល់តែម៉ោងដប់យប់។ អត់ដែលបានឲ្យ រឿងទៅជួបគ្នាឯណា ទាក់ទងគ្នាណា អត់ដែលបានជំនាន់ហ្នឹងលោក។

**ស៖** សូមអរគុណ។ ខ្ញុំសូមអានឲ្យលោកស្តាប់នូវចម្លើយរបស់លោកឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត។ ERN ជាអង់គ្លេស 00235508, ខ្មែរ 00235016, បារាំង 00283948 គឺឯកសារ E3/9346។ “តើគេមានពន្យល់ប្រាប់លោកទេ នៅពេលចាប់ខ្លួនមនុស្ស? លោកឆ្លើយថា៖ អត់ទេ ប៉ុន្តែនៅដើមឆ្នាំ១៩៧៧ គេមានបើកអង្គប្រជុំនៅស្ពាត គឺកីឡដ្ឋានពាម។ ពេលនោះអ្នកភូមិគ្រប់រូបត្រូវតែចូលរួម។ អាន ជាគណៈតំបន់ និង កាន ជាគណៈស្រុកបានបើកការប្រជុំ ហើយបានពន្យល់ប្រាប់យើងថាឲ្យធ្វើឲ្យការងារឲ្យអស់ពីកម្លាំងសម្រាប់អង្គការ រួចហើយនិយាយថា មានខ្មាំងនៅក្នុងចំណោមប្រជាជន។ បន្ទាប់ពីការប្រជុំនេះមក ការចាប់ចងនោះក៏មានសន្ទុះឡើងថែមទៀត ទាំងថ្ងៃទាំងយប់។” នេះគឺជាចម្លើយរបស់លោក ដែលលោកបានឆ្លើយជូនមន្ត្រីស៊ើបអង្កេតនៃសាលាក្តីខ្មែរក្រហម។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ អំពីការប្រជុំនៅកីឡដ្ឋានពាម ដែលមានវត្តមានរបស់គណៈតំបន់ឈ្មោះ អាន នេះ?

[១១:១៦:២០]

**ឆ៖** កាលហ្នឹងខ្ញុំចូល បានចូលរួមប្រជុំទាំងប្រជាពលរដ្ឋទាំងអស់ ទាំងស្រីទាំងប្រុសនៅហ្នឹង បានចូល មិនដឹងថា អាកាន នេះវាប្រធាននេះហ្នឹង ហៅប្រធានកងឲ្យទៅប្រជុំទាំងអស់គ្នាបានស្ដាប់ ប៉ុន្តែកាលនោះ ខ្ញុំដូចជាភ្លេចភ្លាំងដែរ រឿងអាអាន ប្រធានតំបន់ ព្រោះខ្ញុំមិនជាចាំទេ អង្គាល់នោះវា ម្នាក់ៗសុទ្ធតែខ្លាចដែរ។

**ស៖** សូមអរគុណ។ ហើយលោកបានឆ្លើយនេះគឺនៅក្នុងឆ្នាំ២០០៨។ ត្រឹមត្រូវទេ?

**ឆ៖** បាទ ពិតមែនហើយ។

**ស៖** បាទ ខ្ញុំសូមសួរលោកអំពីកិច្ចប្រជុំនេះ។ នៅកិច្ចប្រជុំដែលលោកបានចូលរួម គឺថាគេបាន និយាយថាមានខ្មាំងនៅក្នុងចំណោមប្រជាជន។ លោកចាំទេថា លោកបានចូលរួមនៅក្នុងកិច្ចប្រជុំមួយ ជាមួយ កាន ដែលនៅក្នុងកិច្ចប្រជុំនេះ គេនិយាយថាមានខ្មាំងនៅក្នុងចំណោមប្រជាជន?

**ឆ៖** បាទ មានលោក។

[១១:១៨:០៦]

**ស៖** តើ កាន មានបាននិយាយថា ខ្មាំងហ្នឹងជាអ្នកណាដែរទេ ខ្មាំងជាអ្វីដែរទេ?

**ឆ៖** អត់និយាយថាម៉េចលោក គ្រាន់តែថាខ្មាំងហ្នឹង គ្រាន់តែថាខ្មាំងហ្នឹងក្រោយមកទៀត ចេះតែចាប់ មិនដឹងជាខ្មាំងហ្នឹងខ្មាំងអីទេ ព្រោះអត់ដឹងដែរ។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងទីកន្លែងរបស់លោក តើលោកធ្លាប់បានឃើញ លេខាតំបន់ឈ្មោះ អាន នេះទេ?

**ឆ៖** បាទ តាំងពីប្រជុំនេះម្ដង អត់ឃើញទេលោក ឃើញតែ អាអាន ហ្នឹងតែម្ដង -- អាកាន ប្រធានស្រុកហ្នឹង ញឹកញាប់ហ្នឹង។

**ស៖** ដើម្បីសួរបញ្ជាក់ឲ្យបានច្បាស់ មុននេះបន្តិចគឺថាលោកមិនច្បាស់ទេ មិនដឹងថា អាន ហ្នឹង មានវត្តមានក្នុងប្រជុំឬក៏អត់ទេ។ ប៉ុន្តែលោកថាក្រោយកិច្ចប្រជុំនេះ គឺថាលោកលែងបានជួប អាន ទៀត ហើយ។ តើលោកនៅចាំថា លោកធ្លាប់បានជួប អាន នៅក្នុងកិច្ចប្រជុំនោះទេ ព្រោះលោកថាធ្លាប់បាន ជួប?

[១១:១៩:៤១]

**ឆ៖** ខ្ញុំគ្នាច្រើនណាស់លោក ខ្ញុំនៅក្រោយ អត់ចាំវានេះទេ គ្រាន់តែថាកិច្ចប្រជុំនោះដឹងថា ប្រធានស្រុកហ្នឹង អាកានហ្នឹង វាឡើងបើកៗអីហ្នឹង ខ្ញុំនៅចាំតែប៉ុណ្ណឹងលោក។ ហើយអា អាន ហ្នឹងវា --

ព្រោះច្រើនណាស់ប្រជាពលរដ្ឋទៅ ហើយម្យ៉ាងទៀតមិនបានជាគិតចាប់អារម្មណ៍ប៉ុន្មានទេ ម្នាក់ៗគិតតែខ្លាចដែរហ្នឹង។

**ស៖** តើលេខាស្រុកឈ្មោះ កាន នេះមកពីណាដែរ?

**ឆ៖** សូមបញ្ជាក់លោក ស្ដាប់មិនសូវបាន។

**ស៖** តើលេខាស្រុកឈ្មោះ កាន នេះមកពីស្រុកកងមាសហ្នឹង ឬក៏មកពីកន្លែងណាផ្សេង?

**ឆ៖** បាទ គេថាមកពីនិរតីមកលោក សុទ្ធតែពួកនិរតី មិនដឹងថានៅខាងស្រុកណាផង និរតី។ អត់ដែលស្គាល់ផងកាលនោះ។

**ស៖** លោកឆ្លើយថាកិច្ចប្រជុំនេះ ធ្វើឡើងនៅដើមឆ្នាំ១៩៧៧ តើ កាន នេះបានឡើងធ្វើជាលេខាស្រុកហ្នឹង ចាប់ពីពេលណាដែរ?

**ឆ៖** មិនដឹងពេលណា លោក ប៉ុន៧៧មក ឃើញតាំងពីដើមឆ្នាំ៧៧ ចុង៧៦នោះ ឃើញមកវាលេខាមករហូតហ្នុង ចៅហ្វាយស្រុករហូតហ្នុង ព្រោះអត់ដឹងគេចាត់ពីពេលណាផង។ ខ្ញុំអត់ដឹងផង។

**ស៖** នៅពេលដែលលោកថា ពួកគេទាំងអស់មកពីនិរតី គឺលោកចង់សំដៅថា ពួកគេនេះគឺជាកម្មាភិបាលមកពីភូមិភាគនិរតីមែនទេ?

**ឆ៖** បាទ លោក។

**ស៖** ហើយនៅពេលកម្មាភិបាលទាំងនោះមកស្រុកកងមាស តើគេមកកាន់កាប់តួនាទី សិទ្ធិអំណាចស្រុកឬក៏យ៉ាងណា?

**ឆ៖** បាទ កាន់តួនាទីនៅស្រុកហ្នុងបាទ។

[១១:២២:៣៤]

**ស៖** ហើយតើមានអ្វីកើតឡើងចំពោះប្រជាជនដែលស្ថិតនៅតួនាទីអំណាចដែរ ដូចជា លេខាស្រុក លេខាកងមាស? ហើយនិងអ្នកដទៃទៀតដែលមានសិទ្ធិអំណាចដែរនោះ តើមានអ្វីកើតឡើងចំពោះអ្នកដែលមានសិទ្ធិនិងតួនាទីទាំងនោះ នៅពេលដែលកម្មាភិបាលនិរតីមកដល់?

**ឆ៖** បាទ ត្រង់ហ្នឹងខ្ញុំអត់សូវដឹងដែរ ប៉ុនលោគ្រាន់ថាគេចាប់ពួកអ្នកចាស់ៗមុនយកទៅសម្លាប់អស់ទៅលោក។

**ស៖** ចុះលោកដឹងដោយរបៀបណា?

**ឆ៖** ពួកបាត់អស់ទៅលោក។ កាលនេះទៅ នៅពួកចាស់ ដល់នេះទៅបាត់អស់រលីងៗ ព្រោះ

ជំនាន់ហ្នឹងតែបាត់មុខតែគេសម្លាប់ចោល គេអត់មានទុកទេ ដល់សព្វថ្ងៃអត់មានឃើញវិលមកវិញទេ។

**ស៖** បាទ សុំត្រឡប់ទៅនិយាយពីទីកន្លែងដែលលោកធ្លាប់រស់នៅ។ ទី១ លោកធ្លាប់រស់នៅសាច់ស្វ ហើយលោកក៏ធ្លាប់រស់នៅភូមិសំបួរមាស“ក”។ តើលោកធ្លាប់បានរស់នៅភូមិសាច់ស្វអស់រយៈពេលប៉ុន្មាន? ហ្នឹងខ្ញុំគិតតែអំពីចន្លោះពេលពីឆ្នាំ១៩៧៥ ដល់ ៧៩។ តើលោកចំណាយពេលរស់នៅភូមិសាច់ស្វនេះអស់រយៈពេលប៉ុន្មាន?

**ឆ៖** បាទ ខ្ញុំមករស់នៅក្នុងភូមិសាច់ស្វ បើនិយាយពីនេះហ្នឹង កាលពីឆ្នាំ១៩៧៦ ក៏ខ្ញុំមិនបាននៅជាប់ ព្រោះខ្ញុំត្រូវទៅការដ្ឋានធ្វើភ្លឺស្រែ ភ្លឺអីគ្រប់កន្លែងដែរ។ អ៊ីចឹងខ្ញុំល្បាក់ប្រហែលជាពាក់កណ្ដាលឆ្នាំ៧៦ ហ្នឹង បានគេឲ្យខ្ញុំទៅឈរនៅជាមួយ ធ្វើការនៅសាច់ស្វហ្នឹងជាឈ្លប គ្រាន់តែយាមកាមអី ព្រឹកឡើងធ្វើការជាមួយគេ ដូចតែគេដូចឯងទៅ តែប៉ុណ្ណឹង។

**ស៖** ប៉ុន្តែកន្លែងដែលលោករស់នៅជាប្រចាំ ឬក៏ភាគច្រើន តើជាភូមិសំបួរមាស “ក” ឬក៏សាច់ស្វ ដែលលោកចំណាយពេលក្នុងការរស់នៅច្រើនជាងគេ?

**ឆ៖** ច្រើនជាងគេនៅសំបួរមាស “ក” លោក។

[១១:២៥:៥៨]

**ស៖** ដូច្នេះ តើលោករស់នៅភូមិសាច់ស្វ មួយខែ ពីរខែ បីខែ ឬក៏ មួយឆ្នាំ រយៈពេលប៉ុន្មាន នេះនិយាយតែអំពីក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។

**ឆ៖** ជួនណា ខ្ញុំទៅសាច់ស្វអ៊ីចឹងទៅ កន្លះខែទៅ ខ្ញុំមកសម្រាកផ្ទះមួយយប់ពីរមក មកភូមិករខ្ញុំមក។ ទៅៗអ៊ីចឹងទៅ ចួនណា ខ្ញុំមកផ្ទះវិញមក។

**ស៖** លោកបានឆ្លើយថា ក្រោយពីកិច្ចប្រជុំជាមួយលេខាស្រុកឈ្មោះ កាន រួចមក -- នៅក្នុងចម្លើយរបស់លោក លោកថាការចាប់ខ្លួនហ្នឹង គឺថាមានការកើនឡើងទាំងយប់ទាំងថ្ងៃ។ តើលោកអាចជម្រាបជូនតុលាការបានទេ ការចាប់ខ្លួនហ្នឹងកើតឡើងនៅទីណា គេចាប់ខ្លួននៅកន្លែងណា ដែលលោកថាការចាប់ខ្លួននេះ គឺថាកើនឡើងទាំងយប់ទាំងថ្ងៃក្នុងឆ្នាំ១៩៧៧ នោះ?

**ឆ៖** បាទ លោក ខ្ញុំជម្រាបលោកថា ពេលដែលខ្ញុំមកពីធ្វើការ ពេលហូបបបរម្ដងៗ ឃើញគេដឹកជញ្ជូនមកទាំងក្មេង ទាំងចាស់ ប៉ុន្តែមិនដឹងមកពីកន្លែងណាខ្លះ ព្រោះខ្ញុំអត់បានដឹងទេលោក គ្រាន់តែដឹងថាពិបាកណាស់ វេទនាណាស់ ដែលគេអូសមកទាំងតូចទាំងតាចតាមផ្លូវ គ្រាន់តែឃើញពីចម្ងាយតាមផ្លូវហ្នឹងទាន។ ប៉ុន្តែមិនដឹងយកពីភូមិណា ឃុំណា មកព្រោះខ្ញុំអត់បានដឹងទេ។

[១១:២៧:៤៨]

**ស៖** ឥឡូវនេះ ខ្ញុំមិននិយាយពីថ្ងៃ ឬក៏ថាពេលវេលា ដែលលោកបានឃើញគេចាប់ចាមនៅភូមិសាច់សូទេ ខ្ញុំមិននិយាយកន្លែងនោះ ខ្ញុំនិយាយជារួមតែម្តង។ ដោយសារតែលោកបានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតថា ការចាប់ខ្លួននេះវាកើនឡើងទាំងយប់ទាំងថ្ងៃ។ តើហេតុម៉េចបានលោកដឹងថាការចាប់ខ្លួនទាំងយប់ទាំងថ្ងៃ? តើនេះ ដោយសារតែលោករស់នៅទល់មុខនឹងវត្ត ហើយលោកឃើញគេយកមនុស្សមកទាំងយប់ទាំងថ្ងៃក្រោយឆ្នាំ១៩៧៧ ឬក៏យ៉ាងណា? សូមលោកពន្យល់ជូនតុលាការមើល ថាធ្វើម៉េចបានលោកដឹងថាការចាប់ខ្លួនហ្នឹងវាកើនទាំងយប់ទាំងថ្ងៃ?

**ឆ៖** បាទ តុលាការជាទីគោរព! ខ្ញុំ បានជាខ្ញុំឃើញ ព្រោះមិនសូវមានពេលទំនេរទេ ថ្ងៃធ្វើការទាល់ៗល្ងាច ហូបបបរល្ងាចរួច គេចេញទៅជាន់ទឹកទៀតហើយ។ ក្រោយមកពីជាន់ទឹកមក ឃើញតែគេដឹកជញ្ជូន គ្រាន់តែឃើញគេពីចម្ងាយៗ តែឲ្យថាចេញពីស្រុកភូមិណា គឺអត់បានដឹង ដូចខ្ញុំបានជម្រាបរួចមកហើយ។

**ស៖** ប៉ុន្តែខ្ញុំមិននិយាយអំពីថ្ងៃមួយ ដែលលោកបានឃើញគេចាប់ជនជាតិចាមយកទៅដាក់នៅក្នុងវត្តនោះទេ ខ្ញុំនិយាយអំពីចម្លើយរបស់លោកថា ក្រោយពីកិច្ចប្រជុំនៅដើមឆ្នាំ១៩៧៧ ជាមួយនឹង កានរួចមក លោកឆ្លើយថា ការចាប់ខ្លួនគឺមានការកើនឡើងទាំងយប់ទាំងថ្ងៃ។ អ៊ីចឹងបានខ្ញុំសួរថាធ្វើម៉េចបានជាលោកដឹងថាការកើនឡើង -- ការចាប់ខ្លួនកើនឡើងទាំងយប់ទាំងថ្ងៃ? ដោយសារតែលោករស់នៅទល់មុខនឹងវត្ត លោកឃើញទាំងយប់ ឃើញទាំងថ្ងៃដែរឬក៏យ៉ាងណា? ឬក៏មានមធ្យោបាយណាមួយមានប្រភពព័ត៌មានណាមួយដែលនាំឲ្យលោកដឹងថាការចាប់ខ្លួនវាកើនឡើងបែបនេះ?

**ឆ៖** បាទ ការដែលឃើញនេះ គ្មានប្រភពណាទេ ព្រោះឃើញផ្ទាល់ភ្នែកតែម្តងលោក មិនតែថាខ្ញុំទេ ប្រជាពលរដ្ឋទូទៅទាំងអស់។ ពេលថ្ងៃហូបបបរទៅឃើញបណ្តើរមកហើយ ប៉ុន្តែដូចខ្ញុំជម្រាបថាមិនដឹងគេដឹកពីណាមកទេ មានក្មេងតូចតាច មានទាំងពោះធំ រយីងរយោងមកហ្នឹង រួចចូលទៅ ដូចពេលដែលខ្ញុំបានជម្រាបពីខាងដើម ឲ្យតែចូលដល់វត្តព្រឹបយប់ហ្នឹងចាក់មីក្រូអស់ហើយ បាត់អត់ឃើញមានចេញមកវិញទេ។ អ៊ីចឹងមិនដឹងមកពីស្រុកណាឃុំណាទេ ខ្ញុំជម្រាបលោកប៉ុណ្ណឹង។

[១១:៣០:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ ហើយអរគុណសាក្សី។ បាទ ឥឡូវនេះដល់ពេល

សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះសូមអញ្ជើញចូលវិញដោយបន្តកិច្ចដំណើរការសវនាការ ហើយនៅរសៀលនេះ សូមជម្រាបថា សហព្រះរាជអាជ្ញារងជាតិ និងអន្តរជាតិរួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេល៤០នាទីទៀត ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់សម្រាកខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣១ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:០១]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វីល្លៀម ស្មីត៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ព្រឹកមិញនេះ យើងបាននិយាយគ្នាអំពីការបង្កើតក្រុមដាវវែង ដែលប្រតិបត្តិការនៅក្នុងតំបន់របស់លោក។ ហើយលោកបានឆ្លើយថា ក្រុមនេះបានបង្កើតឡើងក្រោយពេលពួកនិរតីបានមកដល់ស្រុកកងមាស។ ក្រុមនេះ គឺថាមានស្លាយដាវ ហើយលោកមិនហ៊ានចូលជិតពួកគេទេ។ ហើយនៅក្នុងចម្លើយរបស់លោកផងដែរ ក៏លោកបានឆ្លើយថា លោកខ្លាចពួកគេដែរ។ តើក្រុមដាវវែងមានគ្នាប៉ុន្មាននាក់?

**លោក សំរិត មុយ៖**

**ឆ៖** បាទ លោកសួរខ្ញុំថា ក្រុមដាវវែងមានគ្នាប៉ុន្មាននាក់ ខ្ញុំមិនដែលបានពិនិត្យទេលោក ព្រោះមិនដែលបានរាប់ទេ ព្រោះដូចខ្ញុំបានជម្រាបថា ខ្ញុំអត់ហ៊ានចូលជិតគេ មិនដែលហ៊ានមើលគេផង គ្រាន់តែដឹងថាដាវវែង ប៉ុន្តែមិនដឹងមានប៉ុន្មាននាក់គ្នាគេនោះ ឃើញតែដើរ។

**ស៖** សូមលោកផ្តល់ជាតួលេខត្រួសៗមើល៍អាច ១០, ៥០, ១០០នាក់ ឬក៏ថាលោកមិនដឹងសោះ?

**ឆ៖** បាទ ខ្ញុំមិនដែលដឹងចំនួនទេអស់លោក ព្រោះដូចខ្ញុំបានជម្រាបថា មិនដែលចូលជិតគេផង មិនដឹងគ្នាគេមានប៉ុន្មាន គ្រាន់តែឃើញដើរអ៊ីចឹងទៅ។ ជួនណាឃើញពីរបីនាក់អ៊ីចឹងទៅ រួចឲ្យខ្ញុំរាប់ចំនួន ខ្ញុំអត់ដែលបានដឹងចំនួនប៉ុន្មានផង។

[១៣:៣៣:២៣]

**ស៖** តើក្រុមដាវវែងនេះត្រូវបានបង្កើតឡើង ដើម្បីឲ្យតែធ្វើការនៅក្នុងឃុំរបស់លោក ឃុំពាម-ជីកង ឬក៏ថាត្រូវបានបង្កើតឡើងឲ្យបំពេញការងារនៅទូទាំងស្រុកកងមាសតែម្តង?

**ឆ៖** ត្រង់ហ្នឹងខ្ញុំសូមជម្រាបអស់លោកថា ខ្ញុំមិនបានដឹងទេ ព្រោះរឿងថារៀបចំទូទៅក៏មិនដឹងអីក៏មិនដឹងដែរ ប៉ុន្តែគ្រាន់ឃើញវានៅពួកសន្តិសុខហ្នឹង វាឃើញតែលីដាវលីអីហ្នឹង វាបង្កើតនៅនឹងតែម្តង រួចដឹងជាទៅភូមិណាៗ ខ្ញុំអត់បានដឹងទេ។

**ស៖** លោកបានឆ្លើយថា លោកហូបអាហាររបស់លោកហ្នឹងនៅក្នុងសហករណ៍។ ក្នុងអំឡុងពេលក្រោយពីកម្មាភិបាលនិរតីមកដល់ឆ្នាំ៧៧។ តើលោកហូបបាយនៅក្នុងសហករណ៍នោះកន្លែងហូបបាយរួមនោះពេញទូទាំងអំឡុងពេលពីរឆ្នាំនោះឬ?

**ឆ៖** បាទ មិនដែលបានបាយហូបទេ ពីរឆ្នាំពេញ បបរមួយខ្ទះប្រហែលជាយ៉ាងច្រើន១គីឡូចុះអង្ករមើល៍ទៅ មិនដែលបានហូបបាយទេ ធ្វើការពិបាកចង់ងាប់ចង់រស់ មកបបររាវកក្លកសុទ្ធតែទឹក

អត់មានបាយហូបទេ។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែនៅក្នុងចម្លើយរបស់លោកនោះ លោកបានឆ្លើយថា លោកបានឃើញក្រុមប្រជាជនចាមមួយហ្វូងធំ ត្រូវបានគេនាំខ្លួនយកទៅកាន់វត្តអូរត្រកួន នៅពេលដែលលោកកំពុងតែអង្គុយហូបអាហារនៅរោងបាយរួម។ តើលោក -- គឺលោកហូបបាយនៅកន្លែងហ្នឹងរាល់ពេលពីរឆ្នាំហ្នឹងតែម្តង ឬយ៉ាងម៉េច?

**ឆ៖** បាទ កន្លែងផ្ទះហ្នឹងហូបរាល់ពីរឆ្នាំហ្នឹងពេញតែម្តង អត់មានទៅណាទៀត ឲ្យហូបឯណាទេ តែហូបក្រៅ គេយកទៅសម្លាប់ហើយ។

**ស៖** ហើយតើរោងបាយរួមនេះ សម្រាប់ប្រជាជននៅភូមិសំបួរ "ក" តែមួយឬ?

**ឆ៖** បាទ សម្រាប់តែសំបួរមាស "ក"។ ភូមិគេផ្សេង គេកន្លែងគេផ្សេង។ ខ្ញុំកន្លែងផ្ទះបាយសហករណ៍ខ្ញុំគឺសម្រាប់តែសហករណ៍ហ្នឹងតែម្តង។

[១៣:៣៦:៣០]

**ស៖** ហើយថាតើក្រុមដាវវែងនេះ គេហូបនៅរោងបាយរួមហ្នឹងដែរឬក៏អត់ទេ?

**ឆ៖** កន្លែងគេមិនដឹងហូបឯណាផង ខ្ញុំហូបតែក្រុមសហករណ៍ហ្នឹងទេ ពួកនេះហ្នឹងអត់ដែលមកហូបជាមួយផង។

**ស៖** ក្នុងចម្លើយរបស់លោក លោកបានឆ្លើយថា ក្រុមដាវវែងត្រូវបានបង្កើតឡើងចម្រុះគ្នាជាមួយនឹងកម្មាភិបាលពីនិរតី ហើយនិងប្រជាជននៅមូលដ្ឋាននោះខ្លះដែរ។ តើលោកស្គាល់ប្រជាជនមូលដ្ឋានដែលធ្វើការជាមួយក្រុមដាវវែងនោះដែរទេ?

**ឆ៖** បាទ ដែលក្រុមធ្វើការជាមួយពួកដាវវែងហ្នឹង កន្លងមកផុតមកទៀតមក គេសម្លាប់អស់ខ្លះហើយលោក។ ព្រោះជាពលរដ្ឋគេខឹង គេសម្លាប់ក្រោយ នៅសាច់ស្វ សាច់អីហ្នឹង ដែលវាចាប់បងប្អូនអ៊ីស្លាមមកហ្នឹង គេសម្លាប់ទៀតហើយ បាត់ទៅទៀតហើយ ក្រោយមកគេសម្លាប់។

**ស៖** តើ តៃ គឹមប៉ាន់ នេះធ្វើការជាមួយលោកដែរអត់ទេ?

**ឆ៖** អត់ដែលជួបគ្នាផងលោក គ្រាន់តែថានៅក្នុងភូមិជាមួយ ប៉ុន្តែមិនដែលបានអីរួមការងារជាមួយទេ គ្រាន់តែថានៅសហករណ៍ជាមួយគ្នា អត់ធ្លាប់ឃើញផង។

[១៣:៣៨:២៦]

**ស៖** ប្រហែលជាខ្ញុំអានឈ្មោះគាត់មិនច្បាស់។ តាយ គឹមប៉ាន់ តើគាត់ធ្វើការជាមួយនឹងលោក

ឬក៏អត់ទេ?

**ផ៖** មិនដែលទេលោក អត់ដែលធ្វើការជាមួយគ្នាទេ។

**ស៖** ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលហ្នឹង លោកស្គាល់គាត់ដែរ?

**ផ៖** បាទ ស្គាល់នៅឆ្នាំ៧៧ ព្រោះមកនៅសហករណ៍ ធ្វើការនេះហ្នឹងទាំងអស់គ្នា។

**ស៖** តើគាត់នៅក្នុងក្រុមដាវវែងដែរឬទេ?

**ផ៖** តាយ គឹមហ៊ាន់ ហ្នឹងខ្ញុំមិនដែលឃើញទេក្នុងដាវវែង ដូចខ្ញុំបានជម្រាបរួចមកហើយថា ខ្ញុំមិនសូវបានពិនិត្យទេ រឿងក្រុមដាវវែង ព្រោះខ្ញុំខ្លាច ព្រោះខ្ញុំគិតតែពីការងារខ្ញុំទាល់ៗល្ងាច យប់ខ្ញុំមិនទាន់ តែម៉ោងដប់ម៉ោងអឺចឹង ខ្ញុំមិនដែលបាននេះទេ ប៉ុនដូចមិនដែលឃើញមុខម៉េចទេ ព្រោះ--

[១៣:៣៩:៥៥]

**ស៖** សូមអរគុណ។ ខ្ញុំចង់អានផ្នែកមួយនៃចម្លើយរបស់សាក្សីផ្សេងម្នាក់ គឺឯកសារ E319/19.3.93, ERN នៅត្រង់ម៉ោង ០១:០៣:៥៨ គឺៗនៅ ខ្ញុំសុំផ្តល់ -- មិនបានផ្តល់ជាភាសាបារាំង ភាសាខ្មែរទេ។

**ប្រធានអង្គជំនុំ៖**

សាក្សី កុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញសហមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ចំពោះការប្រើប្រាស់ឯកសារនេះ ព្រោះថាឯកសារនេះមិនបានដាក់ចូលនៅក្នុងសំណុំរឿងជាភស្តុតាងទេ។ ឯកសារនេះ ជាកម្មវត្ថុនៃការស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះ ដូច្នេះខ្ញុំសូមជំទាស់ទាំងស្រុងទៅនឹងការប្រើប្រាស់ឯកសារនេះ ពីព្រោះថាមិនទាន់បានដាក់ឲ្យពិភាក្សាដេញដោលនៅឡើយទេ លោកប្រធាន។

[១៣:៤១:២០]

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន បាទ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាពិចារណាទៅលើឯកសារនេះ ថាតើត្រូវសម្រេចទទួលយក ឬក៏យ៉ាងណានោះ។ ឯកសារនេះមាននៅក្នុងសំណុំរឿងហើយ ហើយបុគ្គលនេះ ដែលលោកឈ្មោះនៅក្នុងឯកសារនេះ មានភស្តុតាងពាក់ព័ន្ធដែលអាចយកមកចោទសួរចំពោះសាក្សីរូបនេះបាន ជាពិសេសក្រុមដាវវែងដែលប្រតិបត្តិការនៅវត្តនោះតែម្តង។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ

ដើម្បីយកឯកសារនេះ មកសួរសាក្សីរូបនេះ ត្រង់ថាតើអង្គជំនុំជម្រះនឹងសម្រេចទទួលយកឯកសារនេះជាក្រោយ ឬយ៉ាងណានោះ គឺថាជាការឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ប៉ុន្តែខ្ញុំសូមសួរសាក្សីនេះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំអត់ទាន់មានពេលដើម្បីផ្ទៀងផ្ទាត់ថាឯកសារអីទេ ឯកសារហ្នឹង។ អ៊ីចឹងខ្ញុំចង់ដឹងថា ឯកសារហ្នឹង ជាកំណត់ហេតុស្តាប់ចម្លើយដែលអង្គជំនុំជម្រះគ្រោងនឹងកោះហៅ ឬក៏យ៉ាងម៉េចដែលត្រូវជំទាស់ហ្នឹង?

[១៣:៤២:៤៩]

**លោក វីណ្តៀម ស្មីត៖**

លោកចៅក្រម សាក្សីរូបនេះ គឺថាមាននៅក្នុងបញ្ជីសាក្សីរួចហើយ អ៊ីចឹងឯងទើបយើងខ្ញុំនឹងស្នើសុំឲ្យពិចារណាចំពោះឯកសារមួយនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

នៅពេលដែលលោកថាឯកសារនៅក្នុងសំណុំរឿងនោះ លោកមានន័យថា មិនត្រឹមតែភាគីទទួលបានទេ គឺមានន័យថាអង្គជំនុំជម្រះបានសម្រេចលើការទទួលយកហើយ ឬក៏យ៉ាងម៉េចលោកសហព្រះរាជអាជ្ញា?

**លោក វីណ្តៀម ស្មីត៖**

ឯកសារនេះ គឺថាភាគីបានទទួលរកហើយ វាអាស្រ័យទៅលើអង្គជំនុំជម្រះ ថាតើត្រូវពិចារណាដោយសារវាមាននៅក្នុងឯកសារដ៏ច្រើននេះ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ថាមិនទាន់បានដាក់នៅចំពោះអង្គជំនុំជម្រះនៅឡើយ តែខ្ញុំជឿជាក់ថាបានដាក់ ហើយនិងបានបង្ហាញជូនភាគីហើយ ប៉ុន្តែខ្លួនខ្ញុំផ្ទាល់ក៏មិនជាទាន់ច្បាស់ដែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីឲ្យច្បាស់ទាំងអស់គ្នា តើយើងយល់ថា លោកស្រីជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះដោយសារតែអង្គជំនុំជម្រះមិនបានទទួលយក ហើយនិងដោយសារតែឯកសារហ្នឹងគឺស្ថិតនៅក្នុងសេចក្តីជំទាស់ដែលមាននៅក្នុងសារណារបស់លោកស្រីមុនហ្នឹង ពាក់ព័ន្ធទៅនឹងកាតព្វកិច្ចរបស់សហព្រះរាជ

អាជ្ញាក្នុងការដាក់បង្ហាញឯកសារ ឬក៏យ៉ាងណា?

**កញ្ញា អង់តា ហ្គីសសេះ**

លោកចៅក្រម គឺអ៊ីចឹងហើយ យើងជំទាស់។ គឺយើងជំទាស់ដោយហេតុផលបីឯណោះ។ សហព្រះរាជអាជ្ញាកំពុងតែនិយាយថា ចាប់ពីពេលដែលឯកសារត្រូវបានផ្ដល់ជូនទៅឲ្យភាគីតាមដុំឯកសាររួចទៅហើយ ទោះបីជាគាត់មិនទាន់បានធ្វើសំណើសុំដាក់ចំពោះមុខអង្គជំនុំជម្រះក៏ដោយ ហើយទោះបីជាឯកសារហ្នឹង មិនមាននៅក្នុងបញ្ជីរបស់ភាគីមុនក៏ដោយ ក៏គាត់អាចប្រើប្រាស់បានដែរ។ អត់ មិនអាចអ៊ីចឹងទេ ឯកសារហ្នឹងមិនស្ថិតនៅក្នុងចំណោមឯកសារដែលអង្គជំនុំជម្រះគ្រោងទទួលយកទេ។ ឯកសារនេះមិនស្ថិតនៅក្នុងស្នើយោងតាមវិធាន៨៧(៤) ដែលត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះនោះទេ។ ឯកសារនេះគឺស្ថិតនៅក្នុងចំណោមឯកសារដែលអង្គជំនុំជម្រះបានបញ្ជាក់កាលពីសវនាការមុនៗហើយថា ខ្លួននឹងមិនចាត់ទុកថាដាក់ចូលក្នុងសំណុំរឿងទេ។ ខ្លួនគ្រាន់តែចាត់ទុកថាជាការផ្ដល់ជូនភាគីតែប៉ុណ្ណោះ។ អ៊ីចឹងមិនទាន់អាចទុកជាភស្តុតាងដើម្បីយកមកសួរដេញដោលនៅក្នុងសំណុំរឿង ០០២/០២ នេះទេ។ អ៊ីចឹង អង្គជំនុំជម្រះមិនទាន់ចេញសេចក្ដីសម្រេចនៅឡើយទេ ពាក់ព័ន្ធនឹងសំណើរបស់យើង ហើយនិងសំណើដែលពាក់ព័ន្ធនឹងវិធាន៨៧(៤) ដែលសហព្រះរាជអាជ្ញាមិនទាន់បានធ្វើនោះ។ អ៊ីចឹងខ្ញុំសុំឲ្យអង្គជំនុំជម្រះកុំអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាប្រើប្រាស់ឯកសារនេះឲ្យសោះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរលឿនទេ។ ខ្ញុំយល់ស្របអ្វីដែលលោកស្រីលើកឡើង។ នៅចំណោមឯកសារ៨៤ដែលបានស្នើ គឺថាមានករណីលើកលែងមួយចំនួន។ គឺថាករណីលើកលែងនេះ គឺថាក៏មានធ្វើឡើងចំពោះករណីសំណើសុំរបស់មេធាវីការពារក្ដីដែរ។ ការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងករណីដែលភាគីដទៃមិនបានជំទាស់ គឺថាមិនជាបញ្ហាអ្វីទេ។ ដូចដែលខ្ញុំបានលើកឡើងហើយគឺថា ក្នុងករណីលើកលែងខ្លះ គឺយើងអនុញ្ញាតឲ្យមានរបៀបបែបនេះឯង។ តើវាមានការជំទាស់ទៅលើខ្លឹមសារនៃឯកសារនេះយ៉ាងម៉េចដែរ បានជាមេធាវីការពារក្ដីជំទាស់នោះ?

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំស្ដាប់មិនសូវយល់អំពីសំណួររបស់លោកស្រីចៅក្រម។ លោកស្រីចៅក្រមសួរខ្ញុំយ៉ាងម៉េចថា ខ្ញុំជំទាស់ដោយផ្អែកលើមូលដ្ឋានអ្វី ឬក៏យ៉ាងម៉េច? ខ្ញុំសូមសារភាពថា ភាសាបារាំងមិញខ្ញុំស្ដាប់អត់សូវយល់ទេ។

[១៣:៤៧:០៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ្វីដែលអង្គជំនុំជម្រះចង់ដឹងនោះគឺថាតើលោកស្រីមានទឡ្ហីករណ៍ផ្លូវច្បាប់អ្វីខ្លះ ដើម្បីគាំទ្រដល់ការជំទាស់ទៅនឹងការប្រើប្រាស់ឯកសារដល់សហព្រះរាជអាជ្ញា ឬក៏ជំទាស់ទៅនឹងការដាក់ឯកសារនេះក្នុងការពិភាក្សារដេញដោលនោះ? ខ្ញុំជឿថាទឡ្ហីករណ៍របស់លោកស្រីហ្នឹង គឺលោកស្រីយោងទៅសំណើរបស់លោកស្រីលើកមុនដែលបានដាក់រួមមកហើយ។ អ៊ីចឹងមែនទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ពិតណាស់លោកចៅក្រម។ ខ្ញុំត្រឡប់មកនិយាយអំពីអម្បាញ់មិញនេះគឺថា យើងៗជំទាស់ទៅនឹងការប្រើប្រាស់ឯកសារនេះ។ ហើយបើយើងនិយាយអំពីករណីលើកលែងនោះ គឺថាដូចជាអត់មានអីលើកលែងទេ គឺយើងជំទាស់តែម្ដងទៅនឹងការប្រើប្រាស់ឯកសារហ្នឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សំណួររបស់ខ្ញុំ គឺទៅលើមូលដ្ឋានសំណើសុំជាលាយលក្ខណ៍អក្សររបស់ក្រុមលោកស្រី។

**លោក វីណ្ដៀម ស្មីត៖**

លោកស្រីចៅក្រម ខ្ញុំសុំឆ្លើយតបសង្ខេប គឺថានេះអនុវត្តទៅតាមសេចក្ដីសម្រេចដោយអនុលោមតាមវិធាន ៨៤។ ដូច្នេះ ខ្ញុំអាចនឹងស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ បើយោងទៅតាមសេចក្ដីសម្រេចអនុលោមតាមមាត្រ៨៤ គឺថាដោយសារតែឯកសារហ្នឹងវាពាក់ព័ន្ធនឹងអ្នកធ្វើការនៅមន្ទីរសន្តិសុខនោះ។ ហើយគាត់មានប្រធានបទដែលប្រធានបទគឺថាវា -- គាត់បំពេញការងារទាក់ទងជាមួយនឹងសាក្សីរូបនេះដែរ។ ដូច្នេះការដែល -- ដូច្នេះយើងខ្ញុំស្នើសុំឲ្យពិចារណាទៅតាមចំណាត់ការនីតិវិធី។

**លោក វ៉ិចទ័រ កូប៉េ៖**

អនុញ្ញាតឲ្យខ្ញុំសួរទៅតំណាងសហព្រះរាជអាជ្ញាថា ហេតុអ្វីបានជាយើងមានការជំទាស់មកលើខ្ញុំចំពោះឯកសារដែលប្រើប្រាស់សម្រង់ចេញពីរបាយការណ៍របស់ *ឃ្យូមេនរ៉ៃត៍វ៉ច្ឆ* ដែលមាននៅក្នុងសំណុំរឿងរួចស្រេចទៅហើយផង។ យើងយល់ហើយគឺថា វិធាន -- សេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងវិធាន៨៧(៤) នេះគឺជារឿងមួយផ្សេង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំសូមអន្តរាគមន៍ ប្រហែលជាលោកមិនតាមដានឲ្យបានច្បាស់ទេ។ អង្គជំនុំជម្រះប្រកាសមិន

ទទួលយករបាយការណ៍របស់*យូមេនរ៉ៃត៍វ៉ច្ឆ* ហើយ គឺមិនទទួលទេ។ អ៊ីចឹងអត់មាននៅក្នុងសំណុំរឿងទេ ឯកសារមួយហ្នឹងនោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ឯកសារអម្បាញ់ហ្នឹងក៏អ៊ីចឹងដែរ អត់មាននៅក្នុងសំណុំរឿងទេ លោកចៅក្រម។ សហព្រះរាជអាជ្ញាចង់ប្រើឯកសារហ្នឹងៗ – ឯកសារហ្នឹងមានលក្ខណៈដូចឯកសាររបាយការណ៍នោះអ៊ីចឹង គឺអង្គជំនុំជម្រះចាត់ទុកថាគ្រាន់តែផ្ញើជូនទៅភាគីទេ ក៏ប៉ុន្តែអង្គជំនុំជម្រះមិនទាន់បានសម្រេចថាតើទទួល ឬមិនទទួលទេ។ អ៊ីចឹងអត់មានការសម្រេចទទួលយកទេ នៅពេលនេះ។ ខ្ញុំមិនដឹងថាតើមានបញ្ហាបកប្រែ ឬក៏យ៉ាងណា ក៏ប៉ុន្តែខ្ញុំស្តាប់ឮសហព្រះរាជអាជ្ញានិយាយថា យើងមិនត្រូវធ្វើមិនដឹងមិនឮចំពោះនីតិវិធីទេ ព្រោះថាឯកសារនេះឯកសារសំខាន់ គួរតែលើកលែងខ្លះ។ ចំពោះការកាត់ក្តីនៅក្នុងតុលាការព្រហ្មទណ្ឌ ខ្ញុំគិតថា យើងមានការស៊ើបអង្កេតច្បាស់លាស់ ដែលសហព្រះរាជអាជ្ញាគាត់មានវត្តមានដែរ នៅពេលស៊ើបអង្កេត។ អ៊ីចឹងគាត់មានសិទ្ធិក្នុងការស្តាប់សាក្សីជាមុនតាមគាត់ចង់ ហើយដល់ពេលមកដល់ឥឡូវគាត់ថា ឲ្យសុំលើកលែងករណីនៃនីតិវិធីខ្លះហ្នឹង ដើម្បីសួរសាក្សី។ អ៊ីចឹង ខ្ញុំគិតថា មេធាវីការពារក្តី គឺមានសិទ្ធិក្នុងការតវ៉ា។ ពីព្រោះថា លោកកាលពីស៊ើបអង្កេតនោះ គឺមានលោកមានសិទ្ធិធ្វើបែបនេះហើយ ហើយអ៊ីចឹងយើងអាចចេះតែធ្វើតាមការ ដូចដែលលោកចង់ ដូចដែលចង់លើកលែងទាមទារឲ្យមានការលើកលែងអ៊ីចឹងទេ។ ហើយការដែលយើងឯកសារមកសួរហ្នឹង គឺយកមកពីសំណុំរឿងផ្សេងទៀត ដែលកំពុងតែស៊ើបអង្កេតនោះ។ អ៊ីចឹង ខ្ញុំសូមឲ្យអង្គជំនុំជម្រះ គឺបដិសេធចោលនូវសំណើរបស់សហព្រះរាជអាជ្ញាក្នុងការសុំប្រើប្រាស់ឯកសារមួយនេះ។

[១៣:៥១:២៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥២:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះទទួលយកសំណើ --អ៎! សេចក្តីជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះការដាក់យកឯកសារ E3/319/19.3.93 របស់សហព្រះរាជអាជ្ញារងអន្តរជាតិមកសួរដេញដោលសាក្សី -- ធ្វើជាមូលដ្ឋានសួរដេញដោលសាក្សីរូបនេះ ដោយមូលហេតុ គឺខាងសហព្រះរាជអាជ្ញាមិនបានធ្វើសំណើសុំមកអង្គជំនុំជម្រះ ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមវិធាន៨៧(៣) និង៨៧(៤)

នោះទេ ហើយឯកសារនេះត្រូវដាក់បង្ហាញជូនភាគីដោយសហព្រះរាជអាជ្ញាតាំងពីពេលយូរមកហើយ។ ហើយបញ្ហាទី២ គឺឯកសារនេះ នៅក្នុងប្រភេទឯកសារដែលសហមេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីជំទាស់ ហើយអង្គជំនុំជម្រះមិនបានសម្រេចលើ -- មិនទាន់សម្រេចលើសេចក្តីជំទាស់របស់សហមេធាវីការពារក្តីរបស់ ខៀវ សំផន លើបញ្ហានេះនៅឡើយទេ។

សូមអញ្ជាក់ថា ឱ្យបានច្បាស់លាស់រវាងបង្ហាញថា ឯកសារនៅក្នុងសំណុំរឿង និងអង្គជំនុំជម្រះទទួលយកឯកសារជាឯកសារភស្តុតាង។ មានន័យថា កាលពីពេលនោះទើបភាគអាចដកយកឯកសារនុំងមកពិភាក្សាដេញដោលបាន លើកលែងតែករណីមួយចំនួនដែលយើងបានធ្វើកន្លងមកនេះ គឺមានបញ្ហាដូចថា វាដាក់នៅលើ អ៊ីនធឺហ្វេស នៅក្នុងអំឡុងពេលមួយសមស្រប ដែលភាគីពាក់ព័ន្ធផ្សេងទៀតមិនបានតជំទាស់តវ៉ា អានុំងបើវាជារឿងករណីតិចតួចប៉ុណ្ណោះ។ ហើយបញ្ហានេះ គឺផ្តើមចេញពីសហព្រះរាជអាជ្ញាខ្លួនឯង ដែលជាអ្នកបានបង្ហាញច្បាស់លាស់លើបញ្ហានេះ បែងចែករវាងការបង្ហាញឯកសារពីសំណុំរឿងផ្សេងៗ និងនីតិវិធីនៃការពិនិត្យឯកសារដែលមានប្រយោជន៍ ហើយស្នើសុំតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង មកដល់បានដំណាក់កាលអង្គជំនុំជម្រះពិនិត្យសម្រេចលើសំណើសុំនោះ។ បើអង្គជំនុំជម្រះសម្រេចយក អាហ្នឹងទើបអាចយកឯកសារនោះមកដេញដោលបាន។

**លោក វីណ្ឌៀម ស្មីត៖**

បាទ សូមអរគុណលោកប្រធាន។

[១៣:៥៤:៥៧]

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** លោកសាក្សី ទាក់ទងទៅនឹងក្រុមដាវវែង តើនៅមុនឆ្នាំ១៩៧៧ កងយុទ្ធជនដែលធ្វើការនៅក្នុងស្រុកហ្នឹងគឺដែលយើងហៅថា គឺមាននៅពេលគឺថាមានតែឈ្លបទេ។ អ៊ីចឹងឬក៏យ៉ាងណា?

**លោក សំរិត មុយ៖**

**ឆ៖** បាទ នៅក្នុងភូមិមានតែឈ្លបទេ អត់មានដាវវែង ដាវអីទេ មានតែឈ្លបទេកាលនោះ។

**ស៖** ហើយលោកគឺជាមនុស្សម្នាក់ធ្វើការជាមួយនឹងក្រុមកងឈ្លបនេះ មុននឹងមានវត្តមានក្រុមដាវវែង។ ត្រឹមត្រូវដែរឬអត់ទេ?

**ឆ៖** បាទ មែន។

**ស៖** លោកសាក្សី លោកបាននិយាយអំពីការចាប់ខ្លួន និងការឃុំខ្លួនប្រជាជនចាមនៅវត្ត

អូរត្រកួន។ ប្រជាជនចាមដែលគេនាំខ្លួនមកពីសាច់សូ ក្រៅពីភូមិនេះនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យលោកមានបានដឹងថា ប្រជាជនចាម ក្រុមគ្រួសារចាមមកពីកន្លែងដទៃទៀតត្រូវបានចាប់ខ្លួនដែរទេ?

**ឆ៖** បាទ ត្រង់ហ្នឹងខ្ញុំអត់ដឹងទេលោក ដឹងតែដែលចាប់ប្រមូលមកអស់មួយសារហ្នឹងមក ដល់ក្រោយទៀត ខ្ញុំអត់ដឹងទេ។

**ស៖** ខ្ញុំសូមសួរលោកដោយយកចម្លើយពីបុគ្គលម្នាក់ដែលបានផ្តល់ភស្តុតាង ហើយដែលបុគ្គលរូបនេះក៏ធ្វើការនៅក្នុងក្រុមដាវវែងនោះដែរ។ ឯកសារ E -- បាទ សូមអធ្យាស្រ័យខ្ញុំមិនដឹងតាមរកចម្លើយនេះមកវិញ ដោយសារឯកសារកំពុងតែលើកនិយាយនេះ គឺថាបានដាក់ជូនចំពោះមុខអង្គជំនុំជម្រះហើយ។ នៅក្នុងឃុំរបស់លោក ជាពិសេសភូមិរបស់លោក គឺភូមិសំប្អរមាស “ក”។ តើមានប្រជាជនចាមរស់នៅក្នុងភូមិសំប្អរមាស “ក” ដែរទេ?

**ឆ៖** បាទ អត់មានទេលោកនៅភូមិសំប្អរមាស “ក” មានតែសាច់សូហ្នឹងមួយ។

**ស៖** តើមានប្រជាជនចាមប្រហែលជាប៉ុន្មាននាក់រស់នៅក្នុងភូមិនោះ ភូមិសាច់សូ?

**ឆ៖** ច្រើនណាស់អានេះ ព្រោះបើនិយាយពីចាមច្រើន មួយភូមិសាច់សូហ្នឹង ប៉ុន្តែខ្ញុំ ព្រោះខ្ញុំគ្មានដឹងថាចំនួនប៉ុន្មានៗទេ ខ្ញុំដឹងតែច្រើននៅក្នុងភូមិសាច់សូហ្នឹង។

[១៣:៥៩:០៤]

**ស៖** ហើយមុនពេលប្រជាជនចាមទាំងនេះត្រូវបានចាប់ខ្លួន និងនាំខ្លួនទៅវត្តនោះ មុនពេលចាប់ខ្លួននោះ តើប្រជាជនចាមត្រូវបានអនុញ្ញាតឱ្យគោរពប្រតិបត្តិសាសនារបស់ខ្លួនទេ?

**ឆ៖** តាមដែលខ្ញុំរស់នៅជាមួយបងប្អូនអ៊ីស្លាមនៅភូមិសាច់សូ មានអី ទំនៀមទម្លាប់ គ្រាន់ថាអីចេះ វាថ្វាយបង្គំថ្វាយអីហ្នឹងបាន ប៉ុន្តែរឿងហូបចុកអី គឺខ្ញុំអត់ដឹងទេ គឺគ្រាន់តែថ្វាយបង្គំអី ឲ្យថ្វាយបង្គំម្តងម្យាមបានទេ ឃើញគេធ្វើហ្នឹងតើ។

**ស៖** លោកដឹងដែរថា ហេតុអ្វីបានជាប្រជាជនចាមនៅ រស់នៅភូមិសាច់សូហ្នឹងត្រូវបានគេនាំខ្លួនទៅវត្តនោះ?

**ឆ៖** ត្រង់ហ្នឹងដូចខ្ញុំបានជម្រាបរួចមកហើយ ថាខ្ញុំចេញពីផុតពីភូមិហ្នឹងមកហើយ ខ្ញុំអត់ដឹងទេអារឿងផែនការគេចាប់អីហ្នឹង គ្រាន់តែថាឃើញចាប់យកមក ព្រោះខ្ញុំពេលហូបនៅកន្លែងផ្ទះបាយហ្នឹងប៉ុនអារឿងអីផ្សេងទៀត ខ្ញុំអត់ដឹងដែរ ខ្ញុំបញ្ចេញផុតមកហើយ។

**ស៖** ហេតុអ្វីក៏ត្រូវបាន -- លោកត្រូវគេដកហូតចេញពីក្រុមកងឈ្លប ហើយឲ្យទៅធ្វើការនៅសហករណ៍? ហេតុអ្វី?

**ឆ៖** បាទ ទៅហ្នឹង ព្រោះខ្ញុំត្រូវឲ្យមក វាមិនដឹងហេតុអី ប៉ុនត្រូវតែឲ្យ គេឲ្យមកអ៊ីចឹង ព្រោះខ្ញុំទៅធ្វើការ ព្រោះខ្ញុំនៅសាច់សូហ្នឹង ទោះបីខ្ញុំឈ្លបក៏ខ្ញុំកាន់គោ កាន់អី ធ្វើការជាមួយក្នុងសហករណ៍ដែរ ជាមួយបងប្អូនអ៊ីស្លាមហ្នឹងទាំងអស់គ្នា ប៉ុន្តែរួចទៅគេឲ្យមកនៅផ្ទះវិញ មកៗនៅសហករណ៍វិញមក ផ្ដាច់ពីនុ៎ងមករហូតមកនេះ។

[១៤:០១:២០]

**ស៖** តើលោកមានធ្វើអ្វីខុសដែរឬទេ ទើបបានជាត្រូវបានគេដកហូបចេញពីតួនាទីឈ្លបនេះ?

**ឆ៖** ខ្ញុំអត់ដឹងទេ គ្រាន់ថាគេឲ្យមកសហករណ៍ មកសហករណ៍មកអង្កាល់នុ៎ង អត់មានដឹងថាខុស មិនខុសអីទេ ខ្ញុំអត់ដឹងផង។

**ស៖** តើអ្នកណាជាមេកងឈ្លបរបស់លោក?

**ឆ៖** កាលនុ៎ងឈ្មោះ ណាំ និងឈ្មោះ អ៊ី ប៉ុន្តែគេយកសម្លាប់ទៅហើយលោក។

**ស៖** ហើយនៅក្នុងក្រុមកងឈ្លបរបស់លោកនេះ មានគ្នាទាំងអស់ប៉ុន្មាននាក់?

**ឆ៖** ១២នាក់មានទាំងបងប្អូនចាមនៅជាមួយខ្ញុំដែរ ដើរធ្វើទាំងអស់គ្នា។

**ស៖** ហើយតើមូលហេតុអីបានជា ណាំ និង អ៊ី នេះត្រូវបានគេសម្លាប់ចោល?

**ឆ៖** ខ្ញុំអត់ដឹងទេ រឿងហ្នឹង អត់បានដឹងទេ ដែលគេយកទៅសម្លាប់ មិនដឹងជាគាត់មានខុសអីមិនដឹង ខ្ញុំអត់ដឹងដែរ។

**ស៖** លោកបានឆ្លើយពីខាងដើមថា កម្មាភិបាលភូមិភាគនិរតីបានចូលមកដល់តំបន់របស់លោក។ តើលោកជឿថា អ្នកទាំងពីរនេះត្រូវបានសម្លាប់ដោយកម្មាភិបាលមកពីភូមិភាគនិរតី ឬក៏ត្រូវបានអ្នកផ្សេងសម្លាប់?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់លោកប្រធាន។ សាក្សីជឿជាក់ថា អ្វីដែលគាត់បានដឹង និងបានឃើញការសួរគាត់ជឿជាក់ លោកជឿជាក់ថាយ៉ាងនេះ យ៉ាងនោះ គឺថា គឺជាសំណួរឧបមានវិធានហើយ។

**លោក វីល្លៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូម ខ្ញុំអាចដូរសំណួរបាន។

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី លោកដឹងថា អ្នកទាំងពីរនេះត្រូវបានសម្លាប់ដោយកម្មាភិបាលនិរតី ឬក៏អត់?

**លោក សំរិត មុយ៖**

**ឆ៖** បាទ សម្លាប់ដោយកម្មាភិបាលនិរតីចូលមកនោះតែម្តង។

[១៤:០៤:២៥]

**ស៖** ចុះហេតុម៉េចបានជាលោកដឹងថាពួកអ្នកទាំងនេះត្រូវកម្មាភិបាលនិរតីជាអ្នកសម្លាប់?

**ឆ៖** ការណ៍ទាំងនេះហ្នឹង ឃើញគាត់នៅនេះហ្នឹង ដល់តាំងពីនិរតីចូលមកហ្នឹង បាត់គាត់សូន្យតែម្តង។

**ស៖** ហើយនៅពេលអ្នកទាំងពីរនេះបាត់ខ្លួន តើលោកក្លាយទៅជាប្រធានកងឈ្លបឃុំឬ?

**ឆ៖** បាទ គេដកខ្ញុំមកបាត់ទៅហើយលោក ឲ្យខ្ញុំមកនៅសហករណ៍ហើយ គេអត់មានទៅពាក់ព័ន្ធអីទេ ព្រោះគាត់នៅគេចាប់ក្រោយ ព្រោះខ្ញុំ ខ្ញុំគេឲ្យមកសហករណ៍ផុតទៅហើយ។

**ស៖** ខ្ញុំមិនបាននិយាយថា លោកជាអ្នករៀបចំការចាប់ខ្លួនអ្នកទាំងនេះទេ ខ្ញុំសួរទៅថា នៅពេលអ្នកទាំងពីរនេះ ណាំ និង អ៊ី ត្រូវបានបាត់ខ្លួននោះ តើលោកបានក្លាយទៅជាប្រធានកងឈ្លប ឬក៏អត់ទេហ្នឹងមួយ។ មួយទៀត បើអត់ទេហ្នឹង ហេតុអ្វីបានជាលោកគេបញ្ឈប់លែងឲ្យធ្វើឈ្លប?

**ឆ៖** សូមម្តង សួរខ្ញុំម្តងទៀតលោក ស្តាប់មិនសូវបានអំមិញ ទី១។

[១៤:០៦:០៥]

**ស៖** នៅពេលដែលអ្នកទាំងពីរនាក់ ត្រូវបានគេយកនាំខ្លួនទៅបាត់ទៅ តើអ្នកណាឡើងដឹកនាំកងឈ្លប?

**ឆ៖** ខាងនិរតីហ្នឹង គេយកពីក្រោមមកលោក គេចាត់តាំងមនុស្សថ្មីពីក្រោមមក ខាងរាយប៉ាយយកមកដាក់ត្រង់ហ្នឹង។

**ស៖** ហើយចុះក្រុមរបស់លោកនេះ គេចាត់តាំងឲ្យអ្នកណាដឹកនាំក្រុមកងឈ្លបរបស់លោកនេះ?

**ឆ៖** បាទ ខ្ញុំជម្រាបហើយថាខ្ញុំអត់ដឹង ព្រោះខ្ញុំមកផុតមក គេរៀបក្រោយៗ ខ្ញុំមិនដឹងពីណាទេ

ខ្ញុំអត់ដឹងផង។

**លោក វីណ្ណៀម ស្មីត៖**

លោកប្រធាន អនុញ្ញាតឲ្យខ្ញុំ៤០នាទី វានឹងទៅដល់ម៉ោងពីរដប់នាទី ប៉ុន្តែខ្ញុំសូមការអនុញ្ញាតថែម ១០នាទីទៀត ដើម្បី ដោយសារយើងបានចំណាយពេលច្រើនពិភាក្សាគ្នាទៅលើឯកសារ ដែលខ្ញុំស្នើសុំយកមកប្រើប្រាស់ មុននេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**សួរដោយលោក វីណ្ណៀម ស្មីត៖**

**ស៖** ចុះអ្នកដែលគេៗគេចាត់តាំងលោកឡើងវិញនោះ ឲ្យចេញពីហ្នឹងៗ អ្នកណាគេ?

**លោក សំរិត មុយ៖**

**ឆ៖** ខ្ញុំគ្រាន់គេហៅទៅ អត់មានចាត់តាំងទៅជាឈ្លបធម្មតានោះ ហើយក្រោយមកទៀត ដូចខ្ញុំបានជម្រាបថា ក្រោយពីខ្ញុំគេឲ្យមកនៅសហករណ៍មក មិនដឹងពីណាគេរៀបចំអី ព្រោះខ្ញុំអត់ដឹងផង បើខ្ញុំមកនៅសហករណ៍ហើយ។

[១៤:០៨:០៩]

**ស៖** ខ្ញុំយល់ហើយបញ្ហានេះ ប៉ុន្តែខ្ញុំគ្រាន់តែសួរឲ្យចំថា នៅពេលដែលអ្នកទាំងពីរនេះគេត្រូវបានបាត់ខ្លួនទៅហ្នឹង តើអ្នកណាជាអ្នកបញ្ជាប់ឲ្យលោកធ្វើឈ្លបតទៅទៀតនោះ?

**ឆ៖** តាំងពីអ្នកទាំងពីរហ្នឹងនៅ គេឲ្យខ្ញុំមកនៅសហករណ៍នុ៎ង។

**ស៖** សូមឆ្លើយនឹងសំណួរខ្ញុំឲ្យចំៗតែម្តងលោកសាក្សី។ អ្នកណាជាអ្នកបញ្ជូនលោក បញ្ឈប់លោកឲ្យៗឈប់ឲ្យធ្វើឈ្លប ហើយបញ្ជូនលោកឲ្យទៅនៅសហករណ៍?

**ឆ៖** មិត្តណាំ, មិត្តអ៊ី ហ្នឹងតែម្តង ឲ្យខ្ញុំមកនៅហ្នឹង គេដកខ្ញុំឲ្យមកនៅសហករណ៍ហ្នឹង។

**ស៖** ហើយចុះពេលដែលគេដកលោកឈប់ឲ្យធ្វើឈ្លបហ្នឹង គេមានប្រាប់មូលហេតុថា ម៉េចបានជាគេដកលោកឈប់ឲ្យឈ្លបដែរ?

**ឆ៖** អត់បានដឹងខ្លួនទេលោក គេឲ្យមក ខ្ញុំមកតែម្តង។ ហើយបើដឹងថា គេប្រាប់ថាយ៉ាងម៉េចៗ គេយល់ឃើញថាម៉េច អត់ដឹង ប៉ុនគេឲ្យខ្ញុំមកសហករណ៍ ខ្ញុំមកនៅសហករណ៍វិញមក។

**ស៖** ឥឡូវនេះ ខ្ញុំសូមយកចម្លើយរបស់សាក្សីម្នាក់ផ្សេងទៀត គឺឯកសារ E3/5252, ត្រង់

ERN 00235516 ជាភាសាអង់គ្លេស, ហើយជាភាសាបារាំង 000269890 ហើយខ្មែរ 00235021 សាក្សីរូបនេះបាន និយាយអំពីរូបលោកផ្ទាល់។

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចលោក ស្មីត!

សូមអញ្ជើញសហព្រះរាជអាជ្ញា -- សហមេធាវីការពារក្ដីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ នេះមិនមែនជាការជំទាស់ទេ។ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញា -- សូមអភ័យទោសផង ដែលខ្ញុំកាត់ផ្ដាច់។ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា អ្នកដែលមាននៅក្នុងកំណត់ហេតុហ្នឹងបានផ្ដល់សក្ខីកម្មហើយ។ អ៊ីចឹងដើម្បីឲ្យច្បាស់លាស់ លោកអាចប្រាប់ឈ្មោះតែម្ដងទៅថា ឈ្មោះសាក្សីហ្នឹងឈ្មោះអី បាននិយាយចំណុចហ្នឹងៗ។

**លោក វីល្លៀម ស្មីត៖**

ខ្ញុំរីករាយនឹងទទួលយកសំណើនេះ។

[១៤:១១:២៥]

**សួរដោយលោក វីល្លៀម ស្មីត៖**

**ស៖** លោកសាក្សី តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ សេង ស៊្រុន ដែរទេ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ ខ្ញុំបាទស្គាល់ ទាន។

**ស៖** តើធ្វើម៉េចបានលោកស្គាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** គាត់នៅក្នុងភូមិខ្ញុំដែរ។

**ស៖** សូមអរគុណលោក។ គាត់ត្រូវបានសួរថា៖ “តើនៅពេលណាដែល មុយ ក្លាយទៅជាប្រធានឈ្លបឃុំ?” គាត់ឆ្លើយថា៖ “គាត់ធ្វើជាប្រធានឈ្លបឃុំតាំងពីឆ្នាំ៧៣ រហូតដល់ចុងបញ្ចប់នៃរបប ប៉ុល ពត ក្នុងឆ្នាំ១៩៧៩។” “ហេតុអីបានជាគាត់ -- ឈ្មោះអី ប្រធានឈ្លបហ្នឹង?” “ណាំ គឺជាប្រធានឈ្លបឃុំ ឯ មុយ គឺជាប្រធានឈ្លបពីឆ្នាំ៧៣ ដល់ឆ្នាំ៧៩។ ហើយគាត់មានឡានសម្រាប់ឲ្យកូនគាត់រត់ឈ្នួល ហើយឥឡូវគាត់រស់នៅភូមិសំបួរមាស “ក” នេះ។” តើលោកអាចផ្ដល់ការពន្យល់ត្រង់ចំណុចនេះបន្តិចបានទេ?

**ឆ៖** បាទ អរគុណណាស់តុលាការ។ កាលនោះដែលគាត់សម្គាល់លើខ្ញុំ ព្រោះខ្ញុំដូចបានជម្រាបហើយ ព្រោះខ្ញុំក្នុងនាមជាឈ្លបមួយនៅក្នុងសមាជិកគេទានណា ព្រោះខ្ញុំជាកូនឈ្លបមួយនៅតាំងពីនោះមក។ ប៉ុនពី៧៣ មកខ្ញុំអត់បាននៅទេ ព្រោះខ្ញុំនៅក្នុងភូមិ។ ទាល់ដល់៧៥ ព្រោះកាលនោះឈ្លបគេជាប្រធានឈ្លប គ្រាន់ថាពេលណាដែលទៅត្រៀមកំពង់ចាម គេរ៉ៃហ្នឹង ត្រៀមអីគេរ៉ៃហ្នឹង ពួកខ្ញុំប្រមូលពួកខ្ញុំគេត្រៀមស្នែង ត្រៀមអីអ៊ីចឹងទៅ កាលនៅខ្ញុំអត់មានទៅនៅកន្លែងឃុំទេ។ បាទ ពី៧៣ មកខ្ញុំអត់បានទៅនៅកន្លែងឃុំទេ ៧៣, ៧៤ ជិតដល់ ៧៥ ហើយទាន។ ជិតដល់ ៧៥ គេប្រមូលកម្លាំងទាំងអស់ទៅត្រៀមៗឲ្យគេរ៉ៃ ៧៥ ហ្នឹង។ ទៅបានតែប៉ុន្នានេះ មិនទាន់បានទៅផង ក៏វាដាច់ទៅ ៧៥ ហ្នឹង។ អ៊ីចឹងគាត់ឃើញខ្ញុំទៅនេះហ្នឹង ប៉ុនខ្ញុំនៅក្នុងភូមិទេ។ ការណ៍ដែលខ្ញុំបានជម្រាបពីដើមទីមកហើយកាលនោះខ្ញុំនៅតាំងពីអាម៉ារីន តាំងពីអីមក ដែលរត់នេះហ្នឹង គេឲ្យខ្ញុំកាន់ស្នាយាមយប់ៗរាល់ថ្ងៃ។ មិនមែនតែខ្ញុំទេ គឺក្នុងភូមិហ្នឹងច្រើនណាស់។ ហើយខ្ញុំនេះ កម្លាំងខ្ញុំនេះគ្រាន់ថា ពី៧៣ មកអត់មានតួនាទីអីនៅក្នុងឃុំទេ នៅក្នុងភូមិទេ។ ឈ្លបខ្ញុំ គ្រាន់ឈ្លបតែថ្ងៃណាមួយដូចថា គេឲ្យទៅត្រៀមទៅអីប្រមូលគ្នាទៅត្រៀមទៅ បាទ។ ដូចខ្ញុំបានជម្រាប ដល់មកឆ្នាំចិត ចុង៧៦ ចូល៧៧ គឺខ្ញុំមករស់នៅជាមួយគាត់ដែរ ការងាររហូតទាល់មកដាច់ លំបាកវេទនាម៉េច ក៏បាយជាមួយគ្នា។ នៅធ្វើការងារជាមួយគ្នា ជាមួយ សេង ស៊្រុន ហ្នឹង។ បាទ អរគុណ។

[១៤:១៤:៣៨]

**ស៖** គាត់ក៏បានឆ្លើយផងដែលនៅពេលផ្តល់សក្ខីកម្មថា លោក ហើយនិងកូនចៅរបស់លោកបានចាប់គាត់ ហើយយកគាត់ទៅកាន់មន្ទីរសន្តិសុខដំណាក់ស្នាយ។ តើមានការចាប់ខ្លួនគាត់អ៊ីចឹងមែនទេ?

**ឆ៖** អរគុណណាស់តុលាការ។ រឿងចាប់នេះ គ្មានរឿងរបស់ខ្ញុំទេ ព្រោះខ្ញុំជាកូនជាចៅគ្រាន់តែថា គេឲ្យទៅត្រៀមទៅអី គេចាប់គាត់ទៅមែន ប៉ុន្តែអង្កាល់នោះ សម័យនោះ អង្កាល់ជំនាន់នោះគ្រាន់តែគេចាប់ទៅគេអប់រំ គេឲ្យបកមកវិញ ជំនាន់នុំងមិនរ៉ៃ មិនតប់អីទេ។ ព្រោះរឿងចាប់ទៅក៏មិនមែនរឿងខ្ញុំ លែងមកវិញក៏មិនមែនរឿងពួកខ្ញុំ ជាកូនឈ្លប ខ្ញុំអត់ដឹងទេ។

**ស៖** បាទ ដំបូងខ្ញុំសូមសួរក្រោយពីឆ្នាំ១៩៧៥ ក្រោយពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ តើការចាប់ខ្លួនបានចាប់ផ្តើមមានឡើងនៅក្នុងឃុំរបស់លោកភ្លាមៗ ក្រោយពេលខ្មែរក្រហមឡើងកាន់កាប់អំណាចនៅក្នុងទីក្រុងភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥ដែរឬទេ យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប! សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា សំណួរនេះជាសំណួរដែលពិបាកណាស់ ដោយសារតំបន់ដែលគាត់រស់នៅ គឺត្រូវបានរំដោះមុន ១៧ មេសា ៧៥។ គាត់ប្រហែលជាដឹងច្រើនអំពីក្រុងកំពង់ចាម ក៏ប៉ុន្តែការសួរពីថ្ងៃរំដោះទីក្រុងភ្នំពេញ ប្រហែលជាមិនមានន័យសម្រាប់សាក្សីរូបនេះទេ។

**សួរដោយលោក វីណ្ឌៀម ស្មីត៖**

**ស៖** ឥឡូវខ្ញុំសួរតាមរបៀបផ្សេងវិញម្តង។ លោកដឹងទេថា ខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅឆ្នាំណាដែរទេ? លោកដឹងទេ?

**លោក សំរិត មុយ៖**

**ឆ៖** នៅឆ្នាំ១៩៧៥។

**ស៖** ក្រោយពេលខ្មែរក្រហមត្រួតត្រាទីក្រុងភ្នំពេញហើយ តើការចាប់ខ្លួននោះ បានចាប់ផ្តើមឡើង ឬក៏កើនឡើងភ្លាមៗ ឬនៅក្នុងតំបន់របស់លោក ក្រោយពេលរំដោះ?

**ឆ៖** តុលាការជាទីគោរព! ខ្ញុំជាកសិណសាក្សីមួយសូមផ្តល់យោបល់ សូមឲ្យលោកជ្រាបទាំងអស់គ្នា។ ការណ៍ដែលខ្ញុំដឹងកន្លង ព្រោះអង្គាល់ប្រជាពលរដ្ឋចេញពី៧៥ ពីភ្នំពេញទៅ គឺគេយកទៅដាក់នៅក្នុងវត្តអូរត្រកួននុ៎ងពេញទាំងអស់។ ខ្ញុំនៅជាមួយនុ៎ង ប៉ុន្តែគ្រាន់តែខ្ញុំដឹងថា គេកាប់សម្លាប់ គ្រាន់តែថាគេយក ថាឲ្យទៅរៀនទាន ថាឲ្យទៅរៀន ប៉ុន្តែវាបាត់រហូតមក បានខ្ញុំឆ្លើយថា មុខជាគេសម្លាប់ហើយអ្នកអស់ហ្នឹង ប្រហែលជាមិនទៅរៀនទេ។ គ្រាន់ដឹងប៉ុណ្ណឹងអស់លោក។ ព្រោះខ្ញុំនៅជាមួយប្រជាពលរដ្ឋដែលទៅពីភ្នំពេញទៅ ខ្លះក៏ឆ្លងទន្លេ ខ្ញុំរកធ្យូង រកអីដុតឲ្យគេឆ្លងទន្លេហ្នឹងទៀត ប៉ុន្តែប្តីយកទៅថាយកទៅរៀនបាត់រហូត។ បានខ្ញុំថា ជំនាន់នោះដែលវាត្រូវធ្វើបាប វាកាប់សម្លាប់តាំងពី៧៥ហ្នឹងមក។ ខ្ញុំធានាអះអាងថា ប្រាកដជាពួកហ្នឹងកាប់សម្លាប់តាំងពី៧៥ហ្នឹងមក។

[១៤:១៨:៤៤]

**ស៖** នៅក្នុងតំបន់របស់លោកហ្នឹង អ្នកណាជាអ្នកកាប់សម្លាប់ពួកហ្នឹង ពួកណាជាអ្នកកាប់សម្លាប់?

**ឆ៖** កាលនោះ ខ្ញុំអត់បានដឹងទេលោក ព្រោះខ្ញុំនៅជាមួយគេ ឮគេថាទៅរៀនៗ គេបណ្តើរ

ទៅ ប៉ុន្តែបណ្តើរទៅនុ៎ងអត់មានពីណាចងពីណាអីទេ។ ឃើញបណ្តើរទៅវាបាត់រហូតពាក្យថា "ទៅរៀន" ហ្នឹងមិនដឹងទៅដល់ឯណា។ ប៉ុន្តែក្នុងចិត្តខ្ញុំ ខ្ញុំថាមុខតែគេសម្លាប់ចោលអស់ហើយ ព្រោះទៅរៀនបាត់រហូត។ ហើយក្រោយមកទៀត បានគេរំសាយទៅតាមភូមិ ខ្ញុំអ្នកបងប្អូនទៅពីភ្នំពេញខ្លះដែលមាន គេថាការងារស្អី ប្តីអីណាហ្នឹងទៅនៅជាមួយខ្ញុំរហូតមក។ ខ្ញុំថាកុំភ័យបើងាប់ៗទាំងអស់គ្នានៅចុះ។

**ស៖** ហើយចុះជនជាតិភាគតិច ដូចជាចាម តើពួកគាត់ត្រូវបានបញ្ជូនទៅកន្លែងផ្សេង ឬក៏ត្រូវបានចាប់ខ្លួន ឬក៏យ៉ាងណានៅដើមឆ្នាំ១៩៧៥ មុនពេលក្រុមដារវែងចូលទៅដល់តំបន់របស់លោក?

**ឆ៖** ខ្ញុំបាទ បានជម្រាបរួចមកហើយថា អង្កាល់ដែលខ្ញុំរស់នៅជាមួយពី៧៦ហ្នឹង មិនដែលមានបងប្អូនអ៊ីស្លាមណាត្រូវគេសម្លាប់មួយ គ្មានទេ។ អត់ដែលមានទេ ទាល់មកឆ្នាំ៧៧ និរតីមកដល់ ចាប់ផ្តើមនេះតែម្តង ខ្ញុំមកផុតមកហ្នឹងប្រមូលកម្ទេចចោលតែម្តង។

**ស៖** លោកបានឆ្លើយថា មុនពេលក្រុមដារវែងទៅដល់ឃុំ ឬក៏ទីកន្លែងរបស់លោកនេះ កងទ័ពនៅក្នុងតំបន់នោះគឺៗគេហៅថា ឈ្លបឃុំនៅក្នុងឃុំរបស់លោក។ តើឈ្លបឃុំ ឬដែលជាប់ពាក់ព័ន្ធនៅក្នុងការសម្លាប់ ការចាប់ខ្លួន ពីឆ្នាំ៧៥ រហូតមកដល់ក្រុមដារវែងមកដល់?

**ឆ៖** ការដែលឈ្លបឃុំពីឆ្នាំ៧៥មក មុននឹងដារវែងមកនេះ បើនិយាយពីរឿងចាប់ ដែលយកទៅបាត់ៗហ្នឹងមានតែខាងសន្តិសុខទេ គេមកចាប់ទៅ។ ខាងសន្តិសុខគេមកចាប់យកទៅ ហើយបើ -- ដូចខ្ញុំបានជម្រាបខ្ញុំថា បើគ្រាន់តែក្នុងឃុំដូចតា សេង ស្រ៊ុន ដែលគាត់ផ្តល់យោបល់អីចឹង បើដូចសម័យដែលក្រោយនេះហ្នឹងមិនរស់ទេ។ ហើយហ្នឹងគ្រាន់ថា អ្នកខុសយកមកអប់រំនៅក្នុងភូមិ គេឲ្យទៅផ្ទះវិញទៅ។ អាហ្នឹងគ្រាន់ថាខ្ញុំមិនមែនអ្នកចាប់ មិនអ្នកនេះគេទេ ព្រោះខ្ញុំជាកូនឈ្លប គ្រាន់តែអង្កាល់នោះខ្ញុំចាប់គាត់ទៅ ខ្ញុំហើយអ្នកយកបាយយកអីឲ្យគាត់ហូប។ ដល់ពេលដែលខ្ញុំមកនៅសហករណ៍វិញ ក៏ខ្ញុំមកនៅជាមួយគាត់ដែរ រស់នៅជាមួយគ្នា ការងារជាមួយគ្នាក្នុងសហករណ៍។

[១៤:២២:០០]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរអីទេ? បាទ បើមិនមានទេជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តី ដែលដំបូងនេះផ្តល់វេទិកាទៅក្រុមមេធាវី

ការពារក្តីលោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកសាក្សី។ ខ្ញុំសូមចាប់ផ្តើមសួរលោកបន្តនូវអ្វីដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិទើបសួរលោកអំពីឈ្មោះ សេង ស្រ៊ុន។ សហព្រះរាជអាជ្ញាអានសម្រង់ចេញពីចម្លើយរបស់សាក្សី សេង ស្រ៊ុន ដែលនេះចោទពាក់ព័ន្ធលោកនេះ។ តើនេះជាចម្លើយរបស់លោកឬថា សេង ស្រ៊ុន នេះគឺថាមិននិយាយការពិតឬ? លោកចង់ឆ្លើយថាអីចឹងឬក៏អត់ទេ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកថា គាត់ចង់និយាយពីរឿងការពិតដែលការដែលគេចាប់គាត់យកមកដាក់នៅកន្លែងឃុំ ដែលខ្ញុំយកបាយ យកទឹកទៅឲ្យគាត់។

[១៤:២៣:៤៨]

**ស៖** ប្រសិនណាជាលោកដឹង ហេតុអីបានជាគាត់និយាយអំពីរូបលោក ហើយលោកជឿជាក់ថាវាមិនមែនជាការពិតនោះ?

**ឆ៖** បាទ រឿងនេះខ្ញុំបាទសូមជម្រាបលោក ឲ្យលោកជ្រាបថា រឿងថាមិនរឿងការពិត ព្រោះកាលនោះដូចខ្ញុំបានជម្រាបហើយថា ខ្ញុំគ្រាន់តែឈ្លបកូនចៅគេ។ ហើយការដែលចាប់ ដូចខ្ញុំបានជម្រាបថាខ្ញុំមិនមែនអ្នកចាប់ទេ ខ្ញុំគ្មានតួនាទីទៅដាក់គាត់ទេ ខ្ញុំមានតួនាទីយកបាយ យកទឹកទៅឲ្យគាត់ហួបបានជាគាត់រស់ដល់សព្វថ្ងៃហ្នឹង។

**ស៖** គាត់ក៏បានឆ្លើយកាលពីម្សិលមិញនេះផងដែរថា ផ្ទះរបស់គាត់នោះគឺមានចម្ងាយប្រហែល ២០០ម៉ែត្រពីវត្តអូរត្រកួន។ ហើយព្រឹកមិញនេះលោកខ្លួនឯងឆ្លើយថា ផ្ទះរបស់លោកក៏មានចម្ងាយប្រហែលជា២០០ម៉ែត្រពីវត្តអូរត្រកួនដែរ។ តើលោក ហើយនិង សេង ស្រ៊ុន ជាញាតិជិតខាងគ្នា ជាមនុស្សដែលរស់នៅជាប់របងជាមួយគ្នាឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំសូមជម្រាបលោកថា សេង ស្រ៊ុន ២០០ម៉ែត្រដែរ ប៉ុនគាត់នៅខាងលិចវត្ត។ ខ្ញុំ ២០០ម៉ែត្រដែរ ខ្ញុំនៅខាងកើតវត្ត។

**ស៖** បាទ វាអាចអ៊ីចឹងហើយ។ តើលោកដឹងថា តួនាទី ឬការងាររបស់ សេង ស្រ៊ុន ជាការងារធ្វើអីទេ គិតពីដើមឆ្នាំ១៩៧៧ ទៅដល់១៩៧៩? តើការងារប្រចាំថ្ងៃរបស់ សេង ស្រ៊ុន ហ្នឹងធ្វើអី?

**ឆ៖** គាត់នៅក្នុងសហករណ៍លោក គ្មានតួនាទីអី នៅក្នុងសហករណ៍ហ្នឹងតែម្ដង។

[១៤:២៦:១៦]

**ស៖** តើគាត់ជាសមាជិកនៃកង ឬក៏ថាក្រុមអ្នកឡើងត្នោតដែរឬទេ?

**ឆ៖** បាទ កាលនោះ ខ្ញុំដូច សេង ស្រ៊ុន ខ្ញុំបាទចង់ជម្រាបថា គ្រាន់តែខ្ញុំនៅជាមួយ ប៉ុន្តែអារឿងឡើងត្នោតឡើងអីនេះ ខ្ញុំមិនបាននេះទេ សេង ស្រ៊ុន ហ្នឹង ព្រោះការដែលនៅសហករណ៍នៅទាំងអស់គ្នា ប៉ុន្តែឲ្យខ្ញុំសួរខ្ញុំថា គាត់នៅឡើងត្នោតឡើងអីនេះ វាខ្ញុំបាទសូមជម្រាបលោកថា ខ្ញុំផ្នែកខាងភ្ជួរខាងរាស់។ អ៊ីចឹង សេង ស្រ៊ុន នោះ ពេលហូបបាយហូបជុំគ្នា ចេញការងារយប់អីចេញការងារទាំងអស់គ្នា ប៉ុនអារឿងឡើងត្នោតអង្កាល់នុំង ខ្ញុំអត់បានពិនិត្យថាអ្នកណាធ្វើអីៗ ខ្ញុំដឹងតែការងារខ្ញុំ ព្រោះខ្ញុំរងគ្រោះ ខ្ញុំខ្លាចតែជីវិតខ្ញុំមួយ គ្រួសារខ្ញុំមួយ ខ្ញុំដឹងតែរឿងធ្វើការខ្លួនឯង។

**ស៖** តើលោកធ្លាប់បានឃើញគាត់ឡើងដើមត្នោតទេ ធ្លាប់ដែលឃើញគាត់ឡើងដល់ចុងត្នោតទេ?

**ឆ៖** បាទ សម័យនោះលោក ពិបាកណាស់អ្នកមិនចេះក៏ត្រូវតែប្រឹងឡើងដែរ ទោះបីថា សេង ស្រ៊ុន នោះ ឧទាហរណ៍ថាបើទៅខ្ញុំគ្រាន់ជម្រាបលោកថា បើគាត់ទៅឡើងត្នោតទោះបីជាមិនចេះ ក៏ប្រឹងឡើងដែរ។ ឲ្យតែគេចាត់តាំងហើយ អត់ប៉ានប្រកែក បើប្រកែកពេលណាគឺអត់ជីវិតពេលហ្នឹង។

[១៤:២៧:៥៩]

**ស៖** តើលោកដឹងថា គាត់ធ្លាប់បានទទួលការបញ្ជា ឬក៏ការណែនាំណាមួយឲ្យឃាម និងឲ្យ -- ឲ្យឃាម ហើយនិងអមដំណើរប្រជាជនចាម ដែលគេចាប់មួយក្រុមធំនោះ ដែរឬទេ លោកដឹងទេ?

**ឆ៖** គាត់គ្មានពាក់ព័ន្ធអីទេលោក អារឿងចាប់ចាមចាប់អី សេង ស្រ៊ុន អីដូចខ្ញុំអីអត់មានពាក់ព័ន្ធទេ ខ្ញុំសូមជម្រាបលោកថាផុតហើយពួកខ្ញុំនេះ អត់មានទៅពាក់ព័ន្ធ វាក់វិនជាមួយបងប្អូនអ៊ីស្លាមហ្នឹងទេ។

**ស៖** ពីម្សិលមិញនេះគាត់បានឆ្លើយថា គាត់ចូលរួមនៅក្នុងការប្រមូល ហើយនិងបណ្ដើរចាមមួយក្រុមធំ ដែលត្រូវបានគេចាប់ខ្លួន ហើយគាត់បាន ក៏បានអមដំណើរប្រជាជនចាមទាំងអស់ហ្នឹងរហូតមកដល់ខ្លោងទ្វារវត្ត នៅពេលដែលគេយកអ្នកទាំងនោះចូលទៅក្នុងវត្ត។ តើចម្លើយរបស់គាត់ឆ្លើយយ៉ាងនេះៗ វាត្រឹមត្រូវទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:២៩:៣៣]

**លោក វីណ្សៀម ស្មីត៖**

លោកប្រធាន សំណួរនេះគឺសំណួរនាំមុខហើយ គឺថាភស្តុតាងមិនបានបញ្ជាក់ថា គាត់នេះដើរតួសំខាន់នៅក្នុងការប្រមូលជនជាតិចាម ហើយបណ្តើរយកទៅវត្តនោះទេ។ មេធាវីការពារក្តី សូមឲ្យដកស្រង់សម្តីរបស់សាក្សីឲ្យបានសុក្រឹត។

**លោក វ៉ិចទ័រ កូប៉េ៖**

ប្រហែលជាដោយសារពាក្យអង់គ្លេស ពាក្យអង់គ្លេសថា "*អ៊ិនស្ត្រូមិនថល*" នេះ វាមានន័យថា ចម្បង សំខាន់។ ដូច្នេះខ្ញុំសូមអានសម្រង់ ពីចម្លើយគាត់ឆ្លើយទៅការិយាល័យសហព្រះរាជអាជ្ញា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងអានសម្រង់ខ្លីមួយពីសក្ខីកម្មរបស់ សេង ស៊្រុន ទាក់ទងទៅនឹងអ្វីដែលគាត់បានធ្វើ។ ឯកសារ E3/5302, ERN អង់គ្លេស 00210488, ខ្មែរ 00635176, បារាំង 00623191។ សូមដកស្រង់៖ "ខ្ញុំត្រូវបានគេស្នើឲ្យនាំចាម២០០ ទៅ៣០០នាក់ បណ្តើរពួកគេមកវត្តអូរត្រកួន គេគ្រាន់តែបញ្ជាស្រីជាជនជាតិចាមឲ្យដើរប៉ុណ្ណឹង។ ចំណែកបុរសវិញ ត្រូវគេដាក់ខ្នោះ និងវាយដំ។ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមពីរនាក់ដែលបានដឹកនាំក្រុមនោះ ហើយមានមនុស្សពីរនាក់ផ្សេងទៀតដើរតាមពីក្រោយ ពួកយើងទាំងបួននាក់ជាអ្នកឡើងត្នោត។ មនុស្សបីនាក់ដែលបានចូលរួមដំណើរជាមួយខ្ញុំឈ្មោះ ស្រ៊ន, ធួក អ៊ើង និង ថូវ វ៉ាន់ថា។ អ្នកទាំងបីរស់នៅសព្វថ្ងៃ អ៊ើង និង វ៉ាន់ថា រស់នៅក្នុងភូមិជាមួយខ្ញុំ។" អ៊ីចឹងឯងបានជាខ្ញុំប្រើពាក្យថាវាជាមនុស្សម្នាក់ដែលសំខាន់នៅក្នុងរឿងៗនេះ។ លោកសាក្សី តើ សេង ស៊្រុន មានជាប់ពាក់ព័ន្ធ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វីណ្សៀម ស្មីត៖**

នេះមិនមានជាការជំទាស់ទេ ដើម្បីប្រតិចារឹក មេធាវីការពារក្តីថា សក្ខីកម្មនេះជាសក្ខីកម្មដែលបានឆ្លើយកាលពីម្សិលមិញ ប៉ុន្តែនៅពេលនេះ បែរជាយកចម្លើយឆ្លើយជូនការិយាល័យសហព្រះរាជ

អាជ្ញាតាំងពីប៉ុន្មានឆ្នាំមុនមកម៉្លេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថា នេះជាកិច្ចសម្ភាសន៍ដោយការិយាល័យសហព្រះរាជអាជ្ញា ហើយខ្ញុំក៏បានលើកឡើងក្នុងឯកសារ E3 ដែរ មិនមានកំហុសអីទេ នៅក្នុងការបង្ហាញឯកសារនេះ នៅក្នុងការលើកយកភស្តុតាងនេះ ទោះបីភស្តុតាងនេះ បានមកពីណាក្តី ប៉ុន្តែមានឯកសារ E3 ហើយ។

[១៤:៣២:៥០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះសាជាថ្មី លោកសាក្សី សេង ស្រ៊ុន គាត់និយាយអំពីតួនាទីរបស់គាត់ នៅក្នុងការបណ្តើរ និងអមដំណើរប្រជាជនចាម ដែលត្រូវបានគេនាំទៅទីពិឃាដនៅខាងក្នុងវត្តអូរត្រកួន។ តាមការដឹងរបស់លោក និងពេលវេលារបស់លោករស់នៅក្នុងឃុំនោះ តើចម្លើយរបស់ សេង ស្រ៊ុន នេះ វាត្រឹមត្រូវទេ វាសុក្រឹតទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រម នេះគឺជាការជំទាស់មួយ ទាក់ទងទៅនឹងភាពត្រឹមត្រូវនៃសំណួរនេះ គឺថាសាក្សីរូបនេះបានផ្តល់ចម្លើយថា គាត់មិនបានឃើញ ហើយគាត់មិនបានប្រមូលជនជាតិចាមដែលយកទៅវត្តនោះទេ។ ការដែលគេសួរថាចម្លើយរបស់គាត់ត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវនោះ គឺថាមិនជាការត្រឹមត្រូវនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំដឹងហើយ សហព្រះរាជអាជ្ញាកំពុងតែការពារលោក សេង ស្រ៊ុន។ ហើយឥឡូវនេះ គាត់គឺជាផ្នែកមួយនៃកងឈ្លប។ ដឹងថា ពិតជាដឹងអ្វីដែលបានកើតឡើង អ៊ីចឹងទើបបានជាខ្ញុំសួរសំណួរបែបនេះ ហើយខ្ញុំគួរត្រូវបានអនុញ្ញាតឲ្យសួរសំណួរបែបនេះ។

**លោក វីល្លៀម ស្មីត៖**

នេះ គឺជាសំណួរពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ជាក់លាក់ សក្ខីកម្មនេះគាត់បានឆ្លើយហើយថា គាត់មិនបានដឹងអំពី សេង ស្រ៊ុន នេះជារួមទេ។

[១៤:៣៤:៣៩]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៤:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់សហព្រះរាជអាជ្ញារងអន្តរជាតិក្នុងតាំងសំណួរនេះ។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយមេធាវីការពារក្ដីអម្បាញ់មិញនេះ ប្រសិនបើលោកចាំ បើលោកមិនចាំទេ លោកឲ្យមេធាវីសួរសំណួរសាឡើងវិញ។ ហើយក៏សូមរំឭកលោកមេធាវីដែរ សូមតាំងសំណួរឲ្យបានងាយៗយល់ ដែលអាចសាក្សីស្ដាប់យល់ ហើយនិងឆ្លើយតបបានច្បាស់លាស់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកចង់ឲ្យខ្ញុំសួរលោកឡើងវិញ ឬក៏លោកនៅចាំសំណួរខ្ញុំនៅឡើយទេ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ សូមសួរម្ដងទៀតមក។

**ស៖** ខ្ញុំទើបតែអានសម្រង់ចេញពីចម្លើយរបស់ សេង ស៊្រុន យោងទៅតាមការដឹង និងតួនាទីរបស់លោកដែលធ្វើជាឈ្លបនោះ ខ្ញុំអានសម្រង់នេះឡើងវិញ ហើយខ្ញុំសួរមើលតើលោកមានប្រតិកម្មយ៉ាងម៉េចដែរ។ នេះ គឺជាអ្វីដែល សេង ស្រ៊ុន បាននិយាយ៖ "ពួកវាបានបញ្ជាឲ្យខ្ញុំនាំជនជាតិចាមប្រហែល២០០ទៅ៣០០នាក់ ដើរទៅកាន់វិហារក្នុងវត្តអូរត្រកួន។ គេគ្រាន់តែបញ្ជាស្ត្រីជនជាតិចាមឲ្យដើរប៉ុណ្ណោះ ចំណែកបុរសនោះត្រូវបានគេដាក់ខ្នោះ និងវាយដំ។ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមមនុស្សពីរនាក់ដែលបានដឹកនាំក្រុមនោះ។ ហើយមានមនុស្សពីរនាក់ទៀតដើរយាមពីខាងក្រោយ។ ពួកយើងទាំងបួននាក់ជាអ្នកឡើងត្នោត។ នៅពេលដែលយើងទៅដល់វត្តឆ្នាំគុក និងពេជ្ឈឃាដបានមកយកប្រជាជនទាំងនោះ។ គេអ្នកដែលប្រាប់ខ្ញុំឲ្យប្រមូលជនជាតិ -- អ្នកប្រាប់ខ្ញុំឲ្យប្រមូលជនជាតិឈ្មោះ ហឿន"។ ដូច្នេះ លោកសាក្សី យោងតាមការដឹងរបស់លោកនៅពេលវេលានោះ ខ្ញុំសូមឲ្យលោកឆ្លើយទៅនឹងសម្រង់នេះ តើលោកយល់ម៉េច មានប្រតិកម្មយ៉ាងម៉េចចំពោះចម្លើយសាក្សីរូបនេះ?

**ឆ៖** បាទ ខ្ញុំបាទសូមឆ្លើយទាន។ រឿងដែលខ្ញុំបាទ ដូចបានជម្រាបហើយ ឆ្លើយរួចមកហើយថាខ្ញុំ ក្រោយពីខ្ញុំបានមកនៅសហករណ៍ផុតមកបានគេចាប់ចាមហ្នឹង។ ហើយចាប់ចាមហ្នឹងទៀត ខ្ញុំសូម

ជម្រាបលោក សូមលោកជ្រាបថា ខ្ញុំគ្រាន់តែឃើញពីចម្ងាយ រឿងអ្នកណាដែលចូលរួមក្នុងកម្មវិធីចាប់ចាមយកមកវត្តអូរត្រកួននេះ ខ្ញុំអត់បានដឹងទេ ខ្ញុំមិនហ៊ានទៅជិតទេ ព្រោះគ្រាន់តែឃើញពីចម្ងាយដែលខ្ញុំនៅកន្លែងហូបបរ ហូបបាយហ្នឹង ឃើញគេបណ្ដើរមកហ្នឹង ប៉ុន្តែមិនដឹងជាអ្នកណាចូលរួម ដូចសេង ស្រ៊ុន ដែលគាត់ឆ្លើយ ក៏ខ្ញុំអត់បានដឹងថាគាត់ហ្នឹងទៅចូលរួមក្នុងកម្មវិធីបណ្ដើរចាមហ្នឹងដែរ។

[១៤:៣៨:១៣]

**ស៖** តើក្រោយមកលោកធ្លាប់បានឮថា សេង ស្រ៊ុន ជាប់ពាក់ព័ន្ធនៅក្នុងការនាំប្រជាជនចាមទាំងនេះ ទៅកាន់វត្តអូរត្រកួនដែរទេ?

**ឆ៖** ខ្ញុំជម្រាបលោកថា តាំងពីនុំងមកខ្ញុំមិនដែលឮទេលោក ទើបតែចម្លើយ សេង ស្រ៊ុន នៅពេលហ្នឹងតែម្ដង។ គាត់បានចូលរួម ហើយខ្ញុំអត់ដឹង។ ដូចខ្ញុំបានជម្រាបថា ខ្ញុំតាំងពីគេឲ្យមកហ្នឹង ខ្ញុំប្រឹងតែធ្វើការ ដាច់ខាត ហើយដូចចាមហ្នឹង ខ្ញុំបានជម្រាបអំមិញហើយថា ឃើញតែគេបណ្ដើរពីចម្ងាយ អត់ហ៊ានចូលជិតគេ ដល់ចម្លើយគាត់យ៉ាងណានោះ គឺខ្ញុំអត់ដឹងទេ។

**ស៖** សេង ស្រ៊ុន គាត់បាននិយាយខ្លះៗដែរ កាលពីម្សិលមិញអំពីមនុស្សម្នាក់ឈ្មោះ មឿន។ តើឈ្មោះ មឿន ជាប់ពាក់ព័ន្ធអ្វីទៅនឹងវត្តអូរត្រកួនអីដែរទេ?

**ឆ៖** បាទ អរគុណណាស់ បើនិយាយពីអាឈ្មោះ មឿន នេះវានៅកន្លែងសន្តិសុខនុំងតែម្ដង។ បាទ នៅកន្លែងសន្តិសុខ ស្រុកកំណើតវាក៏នៅគោរដេក ពាមក្នុងហ្នឹងបាទ។

**ស៖** ឥឡូវនេះ ខ្ញុំយល់ហើយប្រហែលជាអាចមានឈ្មោះ មឿន នេះពីរនាក់ តើមានឈ្មោះ មឿន ពីរនាក់ ឬក៏យ៉ាងណា?

**ឆ៖** មឿន ហ្នឹងខ្ញុំស្គាល់តែ អាមឿន សន្តិសុខហ្នឹងទេ ក្រៅពី មឿន ហ្នឹងខ្ញុំអត់ដឹង មឿន ណាទៀតទេ។

**ស៖** តើលោកដឹងថា មឿន ដែលជា មឿន នេះក៏ជាសមាជិកនៃៗក្រុមកងឡើងត្នោតដែរ ឬក៏អត់ទេ?

**ឆ៖** អត់មានទេ អាមឿន ហ្នឹងនៅកន្លែងសន្តិសុខតែម្ដង មិនដែលនៅក្នុងមូលដ្ឋានទេ អាហ្នឹង។

**ស៖** តើហេតុម៉េចបានជាលោកដឹងថា មឿន មិនមែនជាសមាជិកក្រុមឡើងត្នោត?

**ឆ៖** ព្រោះបានតែខ្ញុំធានាថា វាមិននៅក្នុងក្រុមឡើងត្នោត ព្រោះវាអត់នៅក្នុងសហករណ៍ទេ អាមឿន ហ្នឹងវានៅកន្លែងសន្តិសុខ។

[១៤:៤១:២៤]

**ស៖** តើលោកដឹង អាមឿន នេះជាមិត្តភក្តិជិតដិតរបស់ សេង ស៊្រុន ដែរឬក៏អត់ទេ?

**ឆ៖** ត្រង់ហ្នឹងខ្ញុំអត់បានដឹងទេលោក ព្រោះ សេង ស៊្រុន នេះខ្ញុំធ្លាប់តែនៅភូមិជាមួយគ្នា ធ្វើការជាមួយគ្នា រឿងមិត្តភក្តិមិនមិត្តភក្តិវា ខ្ញុំអត់ដែលដឹងទេ ព្រោះអាមឿន ហ្នឹងៗ ខ្ញុំមិនដែលបានទៅក្បែរមិនៗប៉ានទៅជិតវាទេ ព្រោះអានេះវាសាហាវណាស់អស់លោក សាហាវមែនទែន សាហាវត្រង់វាចាប់មនុស្សទៅសម្លាប់ហ្នឹងតែម្តង។ រឿង សេង ស៊្រុន ទាក់ទងអីជាមួយខ្ញុំអត់ដែលដឹងទេ ព្រោះខ្ញុំដឹងពីការងារដូចខ្ញុំជម្រាបលោកអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី ហើយអរគុណសាក្សី។ បាទ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំ សម្រាប់សាក្សីដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:០៧]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយតទៅនេះ ផ្តល់វេទិការជូនទៅ

ក្រុមសហមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងនឹង មឿន។ តើលោកធ្លាប់ឃើញ មឿន ហ្នឹងជូនដំណើរ -- ដើរជាមួយ សេង ស្រ៊ុន ទេ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ ខ្ញុំមិនដែលឃើញទេ។

**ស៖** តើលោកធ្លាប់ដឹងក្រោយឆ្នាំ១៩៧៩ ក្រោយមកហ្នឹងថា មឿន ជាមិត្តភក្ដិជិតស្និទ្ធរបស់ សេង ស្រ៊ុន ដែរឬទេ?

**ឆ៖** ក្រោយពីឆ្នាំ៧៩ មកលោក អត់មានទេ រឿងឈ្មោះ មឿន ហ្នឹងមិនដែលឃើញមកទាក់ទងឈ្មោះ ស្រ៊ុន ហ្នឹងទេ។

**ស៖** ប្រហែលជាមានបញ្ហាបកប្រែហើយមើលទៅ។ តើលោកធ្លាប់ឮគេនិយាយក្រោយឆ្នាំ ១៩៧៩ ហើយដែរទេ ថាកាលពីឆ្នាំមួយពាន់-- មុនឆ្នាំ១៩៧៩ នោះ បានន័យថានៅក្រោមរបបខ្មែរក្រហមហ្នឹង ពីរនាក់ហ្នឹងធ្លាប់ជាមិត្តភក្ដិរាប់អានគ្នាជិតស្និទ្ធ។

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងទេលោក។

[១៥:០២:៥២]

**ស៖** កាលពីម្សិលមិញ សេង ស្រ៊ុន បានផ្ដល់សក្ខីកម្មនៅទីនេះ គាត់បាននិយាយថា មឿន ជាអ្នកឡើងត្នោតដូចគាត់ដែរ ហើយជាអ្នកដែលនិយាយរឿងអាថ៌កំបាំងប្រាប់គាត់ជាច្រើន។ ហើយគាត់បានប្រាប់ឲ្យ ប្រាប់គាត់ឲ្យដឹងពីការសម្លាប់មនុស្សជាច្រើន សេង ស្រ៊ុន គាត់ថា មឿន ហ្នឹងប្រាប់គាត់ពីរឿងសម្លាប់មនុស្សជាដើម។ តើលោកអាចពន្យល់ជូនតុលាការទេ លោកដឹងពីរឿងហ្នឹងទេ អាចជម្រាបជូនរឿងពីរនាក់ហ្នឹងបានទេ?

**ឆ៖** តុលាការជាទីគោរព! លោកបានសួរមកខ្ញុំថា សេង ស្រ៊ុន ធ្លាប់ទាក់ទងជាមួយ មឿន ដូចខ្ញុំបានជម្រាបហើយថា ខ្ញុំមិនដែលបានឃើញទេ ហើយមិនដែលដឹង មិនដឹងឮ សេង ស្រ៊ុន ជាមួយ

មឿន ទាក់ទងយ៉ាងម៉េចៗ គឺខ្ញុំអត់ដឹងទេ។

**ស៖** មុនពេលសម្រាកអម្បាញ់មិញនេះ ខ្ញុំបានសួរលោកថា លោកមានបានស្គាល់ មឿន ម្នាក់ទៀតទេ លោកឆ្លើយថាមិនស្គាល់ទេ។ អ៊ីចឹង តើលោកដឹងដែរឬទេថាអ្នកណាជាប្រធានមន្ទីរសន្តិសុខស្រុក?

**ឆ៖** បាទ អត់ដែលដឹងទេ លោក។

**ស៖** មុនពេលដែលកម្មាភិបាលភូមិភាគនិរតីមកដល់ តើលោកដឹងដែរឬទេថាអ្នកណាជាប្រធានតំបន់៤១?

**ឆ៖** ខ្ញុំមុន -- សួរៗម្តងទៀតលោក។

**ស៖** តើលោកដឹងដែរឬទេថា ប្រធានមន្ទីរសន្តិសុខនៃតំបន់៤១ នេះចន្លោះឆ្នាំ១៩៧៦-៧៧ អីហ្នឹង តើអ្នកណាជាប្រធានសន្តិសុខនៃតំបន់៤១ ហ្នឹង?

**ឆ៖** សួរខ្ញុំៗ អត់ដែលដឹងទេលោក។

**ស៖** តើឈ្មោះ សុង លោកស្គាល់ឈ្មោះ សុង ទេ?

**ឆ៖** បាទ មិនដែលស្គាល់ទេលោក។

[១៥:០៦:០១]

**ស៖** តើអ្នកដែលកាន់តំណែងមុនឈ្មោះ កាង ហ្នឹងជាអ្នកណាដែរ ដែលគាត់ -- អ្នកណាជាចៅហ្វាយស្រុកកងមាសមុនពេលដែល កាង នេះមកដល់?

**ឆ៖** ខ្ញុំអត់ស្គាល់ទេលោក។ ឈ្មោះចៅហ្វាយស្រុកហ្នឹងមិនដែលស្គាល់ឈ្មោះវាទេ ទើបឈ្មោះកាន ហ្នឹងវាមកប្រកាសថាវាឈ្មោះ កាន អ៊ីចឹងតែម្តង។

**ស៖** ជុំ អុល ហៅ មាស – ឈុន អុល ហៅ មាស ហ្នឹង លោកស្គាល់គាត់ទេ?

**ឆ៖** ឈ្មោះអីទាន ឈ្មោះអី បញ្ជាក់?

**ស៖** ឈុន អុល ហៅ មាស លោកស្គាល់គាត់ទេ? ប្រហែលជាខ្ញុំអានឈ្មោះនេះមិនត្រូវទេមើលទៅ ខ្ញុំសូមឱ្យសហភាតាខ្ញុំជួយអានពាក្យនេះ ឈ្មោះនេះជូនលោកស្តាប់។

**លោក លីវ សុវណ្ណា៖**

បាទ គាត់ឈ្មោះ ជួន អុលៗ ហៅ មាស – ជួន អុល ហៅ មាស។ គាត់ជាលេខាស្រុកកងមាស។

**លោក សំរិត មុយ៖**

**ឆ៖** ខ្ញុំអត់ស្គាល់ទេលោក ព្រោះខ្ញុំមិនដែលបានចូលប្រជុំអីជាមួយគេទេ។ ឲ្យខ្ញុំស្គាល់ ខ្ញុំអត់ស្គាល់ ព្រោះខ្ញុំនៅនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីលោកជាល្ហបនៅតំបន់៤១ យ៉ាងហោចណាស់ក៏លោកដឹងថា នៅសម័យនោះអ្នកណាជាលេខាតំបន់៤១ដែរ មុនពេលដែលរូបគាត់ហ្នឹងត្រូវបានចាប់ខ្លួន។ បើនិយាយម្យ៉ាងវិញទៀតគឺថា តើអ្នកណាជាអ្នកកាន់តំណែងហ្នឹងមុន អាន។ ចង់និយាយថាមុន អាន មកដល់ អ្នកណាកាន់តំណែងជាគណៈតំបន់ហ្នឹង?

[១៥:០៨:៥១]

**ឆ៖** ខ្ញុំអត់ដែលស្គាល់ទេរឿងគណៈតំបន់ហ្នឹងលោក។ រឿងគណៈតំបន់៤១ សែអីហ្នឹងគ្មានដែលស្គាល់ទេ មិនដែលឃើញមុខថាគាត់ម៉េចផង ខ្ញុំមិនដែលបានឃើញទេ ប៉ុន្តែឮប្រធានតំបន់ៗហ្នឹងមិនដឹងជាគាត់នៅត្រង់ណា អីត្រង់ណាផងទេ។

**ស៖** ក៏ប៉ុន្តែមុនពេលសម្រាកអម្បាញ់មិញនេះ លោកនិយាយថា កម្មាភិបាលនិរតី -- តំបន់៤១ហ្នឹងត្រូវបានគេយកទៅសម្លាប់។ អ៊ីចឹងខ្ញុំសួរលោកថា ហេតុអីក៏លោកដឹងថា កម្មាភិបាលតំបន់៤១នេះត្រូវបានគេយកទៅសម្លាប់នោះ?

**ឆ៖** ព្រោះខ្ញុំជម្រាបលោកថា បានតែខ្ញុំ ក្នុងចិត្តខ្ញុំថាគេសម្លាប់អស់អត់ទុកហ្នឹង ព្រោះបើអស់លោកប្រធានតំបន់ ប្រធានអីចាស់ ដែលមុនហ្នឹងនៅនោះឃើញហើយ អានេះបាត់ទាំងអស់ អត់មាននៅទេ។

**ស៖** ចន្លោះឆ្នាំ១៩៧៥ ដល់៧៩នោះ លោកមិនដែលឃើញដោយផ្ទាល់ភ្នែកនូវការកាប់សម្លាប់មនុស្សដែរឬទេ? តើលោកដែលឃើញអ្នកណាម្នាក់ត្រូវបានគេសម្លាប់នៅចំពោះមុខលោកទេ?

**ឆ៖** បាទ គ្រាន់តែដូចខ្ញុំបានជម្រាបថា បើឃើញគេបណ្តើរៗទៅ ប៉ុនឲ្យគេ ឲ្យខ្ញុំឃើញថាគេធ្វើបាបអីផ្ទាល់ កាប់សម្លាប់ ខ្ញុំមិនដែលបានឃើញគេផ្ទាល់គេ។

**ស៖** សេង ស្រ៊ុន បាននិយាយអំពីកិច្ចប្រជុំមួយ ដែលនៅក្នុងកិច្ចប្រជុំនោះ តាអាន គាត់ទំនងជាបានចូលរួមប្រជុំដែរ។ តើលោកធ្លាប់ឮ តាអាន និយាយអំពីអតីតលេខាភូមិភាគឧត្តរដែលឈ្មោះ កុយធួន ដែរឬទេ?

[១៥:១១:៥៧]

**ឆ៖** ការដែលខ្ញុំស្ដាប់ប្រជុំប្រជាពលរដ្ឋទាំងអស់នៅក្នុងសហករណ៍ ដូចគ្មានលើកពីអាដែងហ្នឹងទេ វាលើកតែឲ្យគោរព ប្រឹងធ្វើការ គោរពបក្ស គោរពអីហ្នឹង។ មិនមានប្រកាសថា ឈ្មោះនេះ ឈ្មោះនោះនោះទេ អស់លោក។

**សៈ** បាទ ត្រង់ចំណុចនេះតែម្ដង អាន លោកនិយាយថា អាន នេះមានវត្តមាននៅទីនុ៎ង អ៊ីចឹងខ្ញុំសួរលោកថា ម៉េចក៏លោកនោះ ដឹងថា អ្នកដែលធ្វើឧទ្ទេសនាមហ្នឹង ឈ្មោះ អាន នៅក្នុងកិច្ចប្រជុំហ្នឹង?

**ឆ៖** បាទ គេឧទ្ទេសនាមខ្លួនគេ លោក។

**សៈ** តើគាត់មានប្រាប់ឈ្មោះគាត់ទេ ព្រោះថាសាក្សីនេះ និយាយថា គាត់គ្រាន់តែប្រាប់ឈ្មោះគាត់ ឬគាត់ប្រាប់មុខងារ មុខតំណែងរបស់គាត់?

**ឆ៖** គាត់គ្រាន់តែប្រកាសថា ឲ្យប្រជាពលរដ្ឋទទួលស្គាល់ថា គាត់ប្រធានតំបន់ ឈ្មោះ អាន ហ្នឹង។

**សៈ** តើ អាន មាននិយាយអំពីខ្មាំងទេ នៅពេលនុ៎ង គឺខ្មាំងនៅក្នុងចំណោមប្រជាជន?

**ឆ៖** បាទ និយាយលោក លោកប្រធានតំបន់ អាន ហ្នឹងលោកលើករឿងខ្មាំង នៅក្នុងចំណោមប្រជាជនហ្នឹង។

**សៈ** តើលោកយល់យ៉ាងម៉េចដែរ អំពីការប្រកាសរបស់គាត់ហ្នឹង ហើយលោកយល់ពាក្យថា ខ្មាំងបង្កប់ខ្លួនហ្នឹងជានរណាដែរ?

**ឆ៖** ខ្ញុំអត់យល់ទេលោក ព្រោះប្រជាពលរដ្ឋមួយៗ ប្រឹងណាស់ ប្រឹងធ្វើការហ្នឹង។ អត់ ដល់រឿងសួរថាខ្មាំងបង្កប់ហ្នឹង ខ្ញុំអត់ដឹងតែម្ដង មិនដឹងជាមួយណាខ្មាំង ទាំងគេ ទាំងខ្ញុំហ្នឹង។

[១៥:១៤:៣៩]

**សៈ** តើលោកមាន -- គាត់នុ៎ងមានបាននិយាយសំដៅទៅអ្នកណាទេ? ទៅកម្មាភិបាលតំបន់៤១ ដែលត្រូវបានគេចាប់ខ្លួនដែរឬទេ នៅពេលហ្នឹង?

**ឆ៖** ខ្ញុំអត់ឮប្រកាសទេ ឮតែប្រកាសអារឿងខ្មាំងបង្កប់ហ្នឹង។

**សៈ** តើគាត់មាននិយាយអំពីខ្មាំងទាំងអស់ហ្នឹងទេ ខ្មាំងបង្កប់ហ្នឹងដែលមានតួនាទី ឬក៏មុខតំណែងសំខាន់នៅក្នុងស្រុក នៅក្នុងតំបន់ហ្នឹង គាត់មានបាននិយាយពីខ្មាំងអស់ហ្នឹងទេ?

**ឆ៖** គាត់មិននិយាយ ព្រោះខ្មាំងក៏ដោយ ប្រជាពលរដ្ឋក៏ចាប់ទៅដែរ។ អ៊ីចឹងមិនដឹងពីណាខ្មាំង

ខ្ញុំអត់ដឹងផង។

**ស៖** តើគាត់មាននិយាយថា ឧទាហរណ៍ថា “អូ៎! ថ្មីៗហ្នឹងយើងបានចាប់គណៈស្រុកហើយ ហើយនិងចាប់មនុស្សមួយចំនួននៅតំបន់៤១ ហ្នឹងព្រោះថា ពួកនេះ សុទ្ធតែជាខ្មាំងស៊ីរូងផ្ទៃក្នុង”។ តើគាត់មានបាននិយាយរបៀបហ្នឹងដែរទេនៅក្នុងកិច្ចប្រជុំហ្នឹង?

**ឆ៖** ក្នុងកិច្ចប្រជុំហ្នឹងគាត់និយាយថា គ្រាន់តែថា ខ្មាំងបង្កប់ ប៉ុន្តែក្រោយមកទៀត ខ្មាំងបង្កប់ហ្នឹងប្រជាពលរដ្ឋស្លូតត្រង់អត់មានរឿងអីក៏ខ្មាំងដែរ ចាប់ទាំងអស់។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោក ហេតុអីក៏លោកដឹងថា អតីតចៅហ្វាយស្រុក ហើយនិងគណៈតំបន់៤១ អីហ្នឹងសុទ្ធតែជាមនុស្សស្លូតត្រង់អត់មានកំហុសអី លោកដឹងតាមរបៀបណាដែរ?

**ឆ៖** ខ្ញុំមិនបានឆ្លើយថា លោកអស់ហ្នឹងអ្នកស្លូតត្រង់ទេ។ ប៉ុន្តែគ្រាន់ថា កាលនោះដែលនៅហ្នឹងរឿងចាប់ទាំងពូជៗ យកទៅសម្លាប់ចោលមិនដែលនេះ មិនដែលឃើញមានទេអស់លោក ទើបតែមកនីរតីចូលហ្នឹងលេងទាំងពូជៗតែម្តង។

**ស៖** តើលោកយល់ស្របជាមួយនឹងខ្ញុំដែរឬទេក្នុងការនិយាយថា ពាក្យថាសម្លាប់នេះ គ្រាន់តែជាការស្មានៗពីសំណាក់លោកទេ តាមពិតទៅលោកមិនបានដឹងអ្វីទាំងអស់។ ខ្ញុំនិយាយអ៊ីចឹង លោកយល់ស្របនឹងខ្ញុំទេ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេសាក្សី សំណួរដឹកមុខអ៊ីចឹង គឺហាមមិនឲ្យប្រើទេ។

[១៥:១៧:៥៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ មិនថ្វីទេ។ នៅពេលដែលគាត់និយាយនៅក្នុងកិច្ចប្រជុំហ្នឹង តាអាន គាត់មាននិយាយសំដៅ ទៅលើពួកចាមអីដែរឬទេ?

**លោក សំរិត មុយ៖**

**ឆ៖** កាលនោះ អត់មាននិយាយពីរឿងចាម រឿងអីទេ។ គ្រាន់តែខ្មាំងបង្កប់ៗ ខ្ញុំឮតែខ្មាំងបង្កប់ហ្នឹងរួចចាប់បងប្អូនអ៊ីស្លាមហ្នឹងតែម្តង។

**ស៖** ឥឡូវ ខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងទៅនឹងវត្តអូរត្រកួន។ តើលោកធ្លាប់ទៅមើលនៅក្នុងបរិវេណវត្តអូរត្រកួនហ្នឹងដែរឬទេ?

**ធ៖** សូមសួរម្តងទៀត លោកចង់សួរពីពេលណាមកដែលខ្ញុំចូលទៅមើលវត្តអូរត្រកួន សូមសួរម្តងទៀត។

**ស៖** បាទ នៅឆ្នាំ១៩៧៧ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីមកដល់ តើលោកធ្លាប់មានបានចូលទៅមើលនៅក្នុងបរិវេណវត្តអូរត្រកួនដែរឬទេ? ហើយនិងអាចមើលឃើញថា មានរឿងអីកើតឡើងនៅក្នុងអគារផ្សេងៗ នៅក្នុងនោះៗ?

**ធ៖** បាទ នៅក្នុងឆ្នាំ៧៧ ខ្ញុំអត់ប៊ានចូលទេលោក។

[១៥:២០:១០]

**ស៖** តើលោកធ្លាប់ឮនិយាយថា គេឲ្យអាហារអ្នកទោសហូបចុកដែរឬទេ?

**ធ៖** អត់ដឹងទេលោក។

**ស៖** តើលោកធ្លាប់ឃើញអ្នកទោសដែរឬទេ អ្នកទោសស្គមស្គាំងអីជាដើមនេះ?

**ធ៖** ខ្ញុំបានឆ្លើយរួចហើយ ខ្ញុំឃើញតែគេបណ្តើរមក តែត្រង់ថា ឲ្យខ្ញុំឃើញយ៉ាងម៉េចទៅទៀត ខ្ញុំមិនឃើញទេពេលនោះ ព្រោះអត់ប៊ានទៅជិត។

**ស៖** សំណួរចុងក្រោយ ប្រហែលជាសំណួរពិបាកបន្តិចហើយ។ ខ្ញុំនឹងសួរសំណួរនេះឲ្យស្រួល។ លោកបាននិយាយថា នៅពេលដែលគេចាក់មីក្រូពេលយប់ គឺមានគេសម្លាប់មនុស្ស។ តើលោកដឹងរឿងហ្នឹង ក្រោយឆ្នាំ៧៩ហើយទេ ឬក៏លោកដឹងតាំងពីសម័យកម្ពុជាប្រជាធិបតេយ្យតែម្តង? ហើយបើមិនករណីទាំងពីរហ្នឹងមិនចូលទេ លោកដឹងតាមរបៀបណាដែរ?

[១៥:២២:០៥]

**ធ៖** បាទ ដូចខ្ញុំបាទឆ្លើយរួចមកហើយអស់លោក ព្រោះផ្ទះខ្ញុំចម្ងាយ២០០ម៉ែត្រ ហើយគេចាប់រាល់ថ្ងៃ ដែលខ្ញុំឃើញហ្នឹង ទាំងតូច ទាំងតាច ខ្លះពោះធំ ខ្លះបណ្តើរកូនទៅ ពេលណាទៅដល់យប់ហ្នឹងតែចាក់មីក្រូ ខ្ញុំដឹងថាសម្លាប់អ៊ីចឹង ព្រោះមានសំឡេងស្រែក ដូចខ្ញុំបានឆ្លើយរួចមកហើយ។

**ស៖** តើលោកដឹងតាមរបៀបណាដែរ នៅពេលដែលលោកថា មានការសម្លាប់មនុស្ស ពេលគេចាក់មីក្រូ ម៉េចក៏លោកដឹង?

**ធ៖** បាទ រាល់ពេលខ្ញុំជម្រាបលោកឲ្យជ្រាបថា ក្រោយពីចាប់បងប្អូនអ៊ីស្លាមចូលមកចាក់មីក្រូល្ងាចហ្នឹង បាត់ចាមអស់ហើយអត់មាននេះទេ បញ្ចូលមកទៀត បើកាលណាមិនសម្លាប់ទេ អត់មានកន្លែងបញ្ចូល ព្រោះដឹកមករាល់ថ្ងៃទាំងខ្មែរ ទាំងចាម អស់លោក។

**ស៖** បាទ លោកសាក្សីសំណួរចុងក្រោយរបស់ខ្ញុំ តើលោកយល់ស្របនឹងខ្ញុំដែរឬទេ គឺថានេះគ្រាន់តែជាការសន្និដ្ឋានរបស់លោកទេ ហើយលោកមិនដែលបានឃើញដោយផ្ទាល់ភ្នែកនោះទេ? លោកយល់ស្របនឹងខ្ញុំទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ សំណួរប្រភេទនេះ។ សាក្សីគ្មានភារកិច្ចឆ្លើយតបទៅលើសេចក្តីសន្និដ្ឋានរបស់មេធាវីទេ។ បាទ អញ្ជើញ!

**លោក លីវ សុវណ្ណា៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីក្នុងក្រុមការពារក្តីលោក នួន ជា ខ្ញុំបាទមានសំណួរបីសំណួរ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ទី១ លោកមុននេះ លោកបានមានប្រសាសន៍ថា មុនដែលពួកនិរតីទៅ គឺជនជាតិចាមពុំមានការកាប់សម្លាប់ជនជាតិចាមទេ ហើយនៅពេលដែលពួកនិរតីទៅហ្នឹង លោកបានឃើញគេបណ្តើរជនជាតិចាមហ្នឹងពីចម្ងាយ លោកមិនបាន -- លោកមិនប៉ានចូលជិតទេ។ សំណួរខ្ញុំសួរថា តើពេលដែលលោកឃើញនោះម៉ោងប្រហែលជាប៉ុន្មាន?

[១៥:២៤:៥២]

**លោក សំរិត មុយ៖**

**ឆ៖** បាទ អរគុណណាស់លោក។ ខ្ញុំឃើញនោះពេលហូបបាយនៅពេលល្ងាច គេបណ្តើរចាមចូលហ្នឹង។

**ស៖** តើមេឃភ្លឺ ឬក៏ងងឹតហើយ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ! ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក សំរិត មុយ៖**

**ឆ៖** បាទ អត់យប់ប៉ុន្មានទេអស់លោក។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** ទម្លាប់ដែលគេហូបបាយហ្នឹង ចាប់ផ្ដើមពីម៉ោងប៉ុន្មានដែរ?

**ឆ៖** បាទ ពេលព្រឹកម៉ោងមួយដណ្ដប់ ឡើងពីភ្ជួរមក ពេលល្ងាចម៉ោងប្រាំទៅប្រាំកន្លះ។

**ស៖** អ៊ីចឹងលោក តាមការកត់សម្គាល់របស់លោក ពេលដែលលោកឃើញហ្នឹង ប្រហែលជានៅចន្លោះម៉ោងប៉ុន្មានដែរ?

**ឆ៖** ចន្លោះទៅម៉ោងប្រាំទៅប្រាំមួយ លោក។

**ស៖** សំណួរខ្ញុំបាទមួយទៀត គឺលោកអំមិញ លោកបានថ្លែងថាឈ្មោះ មឿន ជាមនុស្ស -- ជាពេជ្ឈឃាដដែលកាចសាហាវ។ ប៉ុន្តែបើយោងទៅលើឯកសារចម្លើយរបស់លោក សេង ស្រ៊ុន ឯកសារលេខ E3/5302 ទំព័រខ្មែរអត់មានលេខ ERN ទេ មានទំព័រទី៧ ហើយនៅក្នុងភាសា ERN ជាភាសាអង់គ្លេសលេខ 00210489, ERN ជាភាសាបារាំងមានលេខ 00623192។ លោក សេង ស្រ៊ុន បាន -- ខ្ញុំបាទសូមដកស្រង់ លោក សេង ស្រ៊ុន បានឆ្លើយថា៖ “មឿន មិនធ្លាប់សម្លាប់មនុស្សដោយផ្ទាល់ដៃឡើយ គាត់គ្រាន់តែអមដំណើរពេជ្ឈឃាដ ដើម្បីជួយ និងឈរមើលពួកវាសម្លាប់មនុស្សតែប៉ុណ្ណោះ។” តើលោកយល់ថា រវាងសម្ដីលោក ហើយសម្ដីលោក សេង ស្រ៊ុន នោះតើសម្ដីណាមួយជាក់លាក់បាទ?

[១៥:២៧:៤៨]

**ឆ៖** អរគុណហើយលោក។ បើលោកសួរអ៊ីចឹងរឹតតែល្អទៅទៀត ព្រោះឈ្មោះ មឿន នេះមិនមែនតែត្រឹមខ្ញុំម្នាក់ទេ ប្រជាពលរដ្ឋទូទៅឲ្យតែឮឈ្មោះ មឿន នេះញាក់សាច់ហើយលោក។

**ស៖** អ៊ីចឹងលោកយល់យ៉ាងណាចំពោះចម្លើយរបស់លោក សេង ស្រ៊ុន ដែលថា មឿន ហ្នឹងគាត់អត់ធ្លាប់សម្លាប់មនុស្សទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! ហើយសាក្សីមិនមានកាតព្វកិច្ចបង្ហាញពីការយល់ដឹងអត្តនោម័តិទៅលើ វាយតម្លៃទៅលើសក្ខីកម្មអ្នកដទៃទេ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ ខ្ញុំបាទសូមទៅសំណួរមួយទៀត គឺមុនហ្នឹងលោកបានថា លោកធ្លាប់យកបាយឲ្យលោក សេង ស្រ៊ុន នៅពេលដែលគេចាប់ខ្លួនគាត់។ តើលោកដឹងថាមូលហេតុអី ដែលគេចាប់ខ្លួនលោក សេង ស្រ៊ុន ទេ?

**លោក សំរិត មុយ៖**

**ឆ៖** ខ្ញុំបានជម្រាបរួចមកហើយលោក ព្រោះរឿងដែលចាប់ រឿងដែលលែងមកវិញ គ្មានរឿងរបស់ខ្ញុំ ខ្ញុំអត់ដឹងទេ។ គ្រាន់តែថាយកបាយទៅឱ្យគាត់ហូប ហើយគាត់រួចមកវិញ រស់ជីវិតទាល់នឹងសព្វថ្ងៃ។

**ស៖** តើមានឮអ្នកណាប្រាប់លោកថា មូលហេតុអីបានគេចាប់ សេង ស៊្រុន ទេ នៅអំឡុងពេលនុ៎ង?

**ឆ៖** កាលនោះអត់ដឹងទេលោក។ ដល់តែឃើញ សេង ស៊្រុន ទៅ ឮនៅនោះ ហើយខ្ញុំនៅនេះហ្នឹង យកបាយទៅឱ្យហូបហ្នឹង រួចគេលែងមកវិញមក រឿងគេហ្នឹង ខ្ញុំអត់ដឹង ដូចខ្ញុំបានជម្រាបថាគ្រាន់តែថាខ្ញុំបានយកបាយទៅឱ្យគាត់ហូប ហើយគេលែងមកវិញ រស់ជីវិតទាល់សព្វថ្ងៃ រួចធ្វើការជាមួយខ្ញុំ ជាមួយសហករណ៍តមកហ្នឹង។

[១៥:២៩:៤៣]

**លោក លីវ សុវណ្ណា៖**

បាទ ខ្ញុំបាទសូមអរគុណលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក សំរិត មុយ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនក្នុងឋានៈខ្ញុំជាមេធាវី។ ជាដំបូងខ្ញុំចង់ត្រឡប់មកនិយាយអំពីប្រវត្តិផ្ទាល់ខ្លួនរបស់លោក ដូចដែលលោកបានបញ្ជាក់នៅក្នុងឯកសារលេខ E3/9346, ERN ជាភាសាបារាំង គឺ 00283946, ERN ជាភាសាអង់គ្លេស 00235507, ជាភាសាខ្មែរ គឺERN 00235014។ នៅពេលដែលខ្ញុំអានកំណត់ហេតុរបស់លោក គឺលោកបានឈប់រៀននៅថ្នាក់ទី៩ ដោយសារឪពុកម្តាយរបស់លោកជាអ្នកក្រ។ ខ្ញុំមិនមែនជាខ្មែរនេះ ខ្ញុំចង់ដឹងថាតើថ្នាក់ទី៩ ហ្នឹងមានន័យយ៉ាងម៉េច បឋមសិក្សា មធ្យមសិក្សា ព្រោះខ្ញុំមិនមែនជាខ្មែរ ខ្ញុំអត់យល់អំពីប្រព័ន្ធនៃការអប់រំ

ហ្នឹងទេ ហើយលោកឈប់រៀនថ្នាក់ទី៩ ហ្នឹងនៅអាយុប៉ុន្មានដែរ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ សូមជម្រាបថ្នាក់ទី៩ បឋមសិក្សា ហើយខ្ញុំឈប់រៀនហ្នឹង ប្រហែលជាអាយុ១៥, ១៦ ឆ្នាំ ព្រោះដល់ម្ដាយឪពុកខ្ញុំក្រ ដូចក្នុងប្រវត្តិខ្ញុំដាក់មកហើយ ខ្ញុំទៅធ្វើកម្មករចៀវជ័រ។

**ស៖** ហើយលោកធ្វើការនៅចម្ការកៅស៊ូហ្នឹង គឺរហូតដល់ឆ្នាំ៧១។ អ៊ីចឹងខ្ញុំយល់ថាលោកហ្នឹងធ្វើការនៅក្នុងចម្ការកៅស៊ូហ្នឹងគឺតាំងពីមុនឆ្នាំ៧១ មកម្ល៉េះមែនទេ?

**ឆ៖** បាទ។

[១៥:៣២:២២]

**ស៖** សំណួរខ្ញុំចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធនឹងចំណុចនេះ។ ខ្ញុំចង់ដឹងថា នៅកន្លែងរបស់លោកហ្នឹងគឺមានអ្នកធ្វើការច្រើនដូចលោកទេ ដែលធ្វើការជាមួយឪពុកម្ដាយតាមចម្ការកៅស៊ូ ឬក៏នៅតាមស្រែចម្ការអីនោះ?

**ឆ៖** បាទ ច្រើនលោក។

**ស៖** អ៊ីចឹងលោកឯកភាពទេថា គឺហេតុការណ៍ហ្នឹង គឺនៅពេលដែលខ្មែរក្រហមចូលមកដល់តំបន់របស់លោកមែនទេ?

**ឆ៖** បាទ សូមសួរម្ដងទៀតលោក ខ្ញុំអត់យល់ទេត្រង់ហ្នឹង។

**ស៖** រយៈពេលដែលលោកថាមានមនុស្សច្រើនធ្វើការកសិកម្មជាមួយឪពុកម្ដាយហ្នឹង ខ្ញុំចង់ដឹងថា តើការងារហ្នឹង គឺធ្វើហ្នឹង គឺមុនពេលដែលខ្មែរក្រហមហ្នឹងចូលមកដល់តំបន់របស់លោក គឺមុនឆ្នាំ ៧១ មែនទេ?

**ឆ៖** បាទ ខ្ញុំរស់នៅក្នុងចម្ការកៅស៊ូតាំងពី ៦៤, ៦៥ មករហូតទាល់មកដល់ឆ្នាំ៧១ ហ្នឹងទម្លាក់គ្រាប់បែកទម្លាក់អី គឺខ្ញុំនៅរត់មកតែម្ដង។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។ ឥឡូវនេះ ខ្ញុំចូលទៅរយៈកាលក្រោយឆ្នាំ១៩៧៥ គឺខ្ញុំនិយាយអំពីក្រោយឆ្នាំ៧៧ ឲ្យជាក់លាក់តែម្ដង។ លោកចាំទេថា កន្លែងរបស់លោកហ្នឹង ពេលហ្នឹងគឺស្ថិតនៅក្នុងភូមិភាគអី?

**ឆ៖** ខ្ញុំអត់ចាំទេលោក ព្រោះនៅ ដឹងតែមកត្រើយម្ខាងហ្នឹង ខ្ញុំអត់ដឹងថាតំបន់អីៗទេ អត់យល់ពីតំបន់អីៗទេ កាលហ្នឹង។

[១៥:៣៤:៣១]

**ស៖** លោកបាននិយាយអំពីមនុស្សមួយចំនួនដែលមានទំនួលខុសត្រូវ ខ្ញុំចង់ត្រឡប់មកនិយាយអំពីអ្នកទាំងអស់នេះ។ លោកធ្លាប់ជាឈ្លបពីឆ្នាំ៧៣ រហូតទៅដល់ឆ្នាំ៧៥។ ខ្ញុំយល់អ៊ិចឹងត្រឹមត្រូវទេ លោកធ្វើជាឈ្លបហ្នឹងពីរ ៧៣ ដល់ ៧៥?

**ឆ៖** បាទ ត្រឹមត្រូវហើយ ព្រោះខ្ញុំធ្វើឈ្លបភូមិ នៅក្នុងភូមិតាំងពី៧៣ រហូត៧៥។

**ស៖** ពីឆ្នាំ៧៥ ដល់ឆ្នាំ៧៦ លោកជាឈ្លបឃុំមែនទេ?

**ឆ៖** បាទ ឆ្នាំ៧៥រួចហ្នឹង គេឲ្យមកនេះវិញ ដល់ឆ្នាំពាក់កណ្ដាលឆ្នាំ៧៦នោះ គេឲ្យទៅធ្វើឈ្លបឃុំវិញ។

**ស៖** អ្នកណាជាមេរបស់លោក ពេលលោកធ្វើជាឈ្លបឃុំនោះ?

**ឆ៖** បាទ ខ្ញុំបានទជម្រាបរួចហើយ ឈ្មោះ អ៊ី និងឈ្មោះ ណាំ ហ្នឹង។

**ស៖** លោកធ្លាប់ឮឈ្មោះ រុន ទេ?

**ឆ៖** ខ្ញុំដូចមិនដែលឮឈ្មោះ រុន ហ្នឹង លោក។

**ស៖** លោកបាននិយាយជាមួយសហព្រះរាជអាជ្ញាអំពីក្រុមដាវវែង ដែលលោកបានពន្យល់ថា លោកខ្លាចក្រុមនេះណាស់។ លោកចាំឈ្មោះសមាជិកក្រុមដាវវែងនេះទេ?

[១៥:៣៧:០៩]

**ឆ៖** ខ្ញុំបាទបានជម្រាបរួចហើយថា ខ្ញុំមិនប៉ានចូលជិត ហើយខ្ញុំក៏មិនដែលស្គាល់ឈ្មោះពួកអស់ហ្នឹងដែរ ព្រោះអត់ប៉ានទេ អស់លោក។

**ស៖** លោកស្គាល់ឈ្មោះ ឡាវ ខួយ ទេ?

**ឆ៖** ខ្ញុំដូចមិនដែលឮ ឡាវ ខួយ ហ្នឹង អស់លោក។

**ស៖** ចុះឈ្មោះ ម៉េង លី លោកធ្លាប់ស្គាល់ទេ?

**ឆ៖** បាទ បើ ម៉េង លី នៅក្នុងភូមិខ្ញុំ។

**ស៖** លោកដឹងទេថា ម៉េង លី ក៏ជាសមាជិកក្រុមដាវវែងដែរ?

**ឆ៖** បាទ នៅក្នុងភូមិខ្ញុំ ខ្ញុំដឹងមួយ ម៉េង លី ហ្នឹង គ្រាន់តែដឹងថា គាត់ហ្នឹងនៅក្រុមដាវវែងកាលនោះ។ ឃើញគាត់ដើរហើរអីទៅខាង លើកទំនប់លើកអី។

**ស៖** លោកស្គាល់ឈ្មោះ ហេង ប៉ា ទេ?

**ឆ៖** ស្គាល់ លោក។

[១៥:៣៩:០៤]

**ស៖** លោកដឹងថា ហេង ប៉ា ហ្នឹងមកពីណាទេ ហើយគាត់នៅក្នុងក្រុមដាវវែងហ្នឹងដែរឬទេ?

**ឆ៖** ជំនាន់ខ្ញុំ ដូចជាមិនបានច្បាស់ទេ អស់លោក ព្រោះ ហេង ប៉ា ហ្នឹងនៅក្នុងភូមិមែន ប៉ុន ជំនាន់នុ៎ង ដូចខ្ញុំបានជម្រាបហ្នឹងថា គេរៀបចំកម្លាំងថ្មីនេះ ខ្ញុំអត់ដែលទៅជិតគេយ៉ាងម៉េចទេ។

**ស៖** លោកស្គាល់ឈ្មោះ យឿន ទេ?

**ឆ៖** ស្គាល់។

**ស៖** លោកដឹងថា យឿន នេះមកពីណាទេ? គឺគាត់រស់នៅភូមិណា ហើយគាត់ជាសមាជិកក្រុមដាវវែងដែរឬទេ?

**ឆ៖** ដូចខ្ញុំបានជម្រាបថា ឈ្មោះ យឿន ឈ្មោះអីនេះ នៅក្នុងភូមិខ្ញុំ ប៉ុន្តែដូចខ្ញុំបានជម្រាបហើយថា រឿងពួកនេះ ធ្វើអីៗ ខ្ញុំអត់ដឹងទេ អស់លោក ព្រោះដូចខ្ញុំបានជម្រាបថា មិនដែលបានទៅទាក់ទងជាមួយពួកអស់ហ្នឹងទេ។

**ស៖** ឈ្មោះចុងក្រោយ លោកស្គាល់ ឈ្មោះ តាយ គឹមប៊ាន់ ទេ? លោកដឹងថា គាត់មកពីណាទេ? ហើយគាត់ជាក្រុមដាវវែងដែរឬទេ?

**ឆ៖** តាយ គឹមប៊ាន់ ហ្នឹងខ្ញុំបានជម្រាបម្តងហើយ ខ្ញុំអត់ដែលដឹងថាគាត់ក្រុមដាវវែងហ្នឹងផង។

**ស៖** ប៉ុន្តែលោកស្គាល់គាត់ អ៊ីចឹងលោកអាចបញ្ជាក់បានទេ ថា តាយ គឹមប៊ាន់ ហ្នឹងគាត់មកពីណា?

**ឆ៖** តាយ គឹមប៊ាន់ ហ្នឹងភូមិកំណើតគាត់នៅខាងភូមិអង្គរបាន ប៉ុន្តែគាត់មានគ្រួសារនៅសំបួរមាស "គ" ហ្នឹង ជាមួយភូមិខ្ញុំហ្នឹង។ ហើយខ្ញុំគ្រាន់តែដឹងថា កាលដែលនៅសហករណ៍ហ្នឹង គាត់ក៏នៅធ្វើការងារហ្នឹង ប៉ុន្តែដល់មកថា ឲ្យទៅជាដាវវែង ដាវអី ខ្ញុំអត់ដែលដឹងគាត់ទេ ទើបមកពេលហ្នឹងលោកសួរតែម្តង។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកធ្លាប់ចូលរួមជួយចាប់មនុស្សដែលធ្វើជាមួយនឹងក្រុមដាវវែងហ្នឹងទេ?

**ឆ៖** ខ្ញុំមិនដែលជួបប្រទះទេលោក រឿងចូលរួមជាមួយ រឿងចាប់ជាមួយពួកអាហ្នឹង។ ដូចខ្ញុំបាន ជម្រាបថា គ្រាន់តែ តាយ គឹមប៊ាន់ មួយដែលលោកសួរខ្ញុំ ខ្ញុំមិនដែលដឹង តាយ គឹមប៊ាន់ ហ្នឹង

ធ្វើអីផង។

[១៥:៤២:៣០]

**ស៖** លោកបាននិយាយអំពីក្រុមចាមដែលត្រូវបានគេចាប់ខ្លួនហើយដើរទៅវត្ត។ តើលោកដឹងទេ ថាអ្នកណាជាបណ្តើរ ឬនាំជនជាតិចាមទាំងអស់ហ្នឹងទៅវត្តនោះ ក្នុងចំណោមអ្នកដែលខ្ញុំបានរៀបរាប់អម្បាញ់មិញនេះ ខួយ, តាយ គឹមហ៊ាន់, ម៉េងលី, ហើយនិង ប៉ា, យឿន អីហ្នឹងលោកឃើញអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងហ្នឹងនាំជនជាតិចាមទាំងអស់ហ្នឹងទៅវត្តទេ?

**ឆ៖** បាទ ខ្ញុំបានឆ្លើយរួចមកហើយ ព្រោះខ្ញុំគ្រាន់តែឃើញពីចម្ងាយទេ។ អ៊ីចឹងហើយបានខ្ញុំថាដឹង តាយ គឹមហ៊ាន់ ខ្ញុំអត់ដែលឮសោះ ទើបលោកសួរខ្ញុំអ៊ីចឹង ខ្ញុំឃើញតែពីចម្ងាយ ដែលបណ្តើរចាមទាំងតូចទាំងតាច ទាំងកូនចៅ ប៉ុន្តែរឿងឲ្យឃើញពីណាបណ្តើរ គឺខ្ញុំមើលពីចម្ងាយ ខ្ញុំអត់ហ៊ានសន្និដ្ឋានថា ឈ្មោះណាៗទេ ព្រោះខ្ញុំអត់មានចូលចិត្តគេ។

**ស៖** ប្រសិនបើខ្ញុំយល់មិនច្រឡំទេ តាមរយៈសក្ខីកម្មរបស់លោក គឺនៅពេលដែលក្រុមមនុស្សដើរទៅវត្តហ្នឹង គឺលោកនៅក្នុងរោងបាយសហករណ៍របស់លោក។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ខ្ញុំមិនដឹងថា ខ្ញុំភ្លេចកត់ ឬក៏យ៉ាងម៉េច តើលោកអាចបញ្ជាក់បានទេ ថាពីរោងបាយហ្នឹងទៅវត្តចម្ងាយប្រហែលប៉ុន្មានដែរ?

**ឆ៖** ពីកន្លែងរោងបាយខ្ញុំទៅកន្លែងវត្តហ្នឹងចម្ងាយតែ ៣០០ម៉ែត្រ។

**ស៖** ចម្ងាយ ៣០០ម៉ែត្រហ្នឹង គឺលោកឆ្លើយថាលោកមិនអាចមើលឃើញច្បាស់ថាអ្នកណាជាអ្នកបណ្តើរជនជាតិចាមហ្នឹងទៅវត្តទេ អ៊ីចឹងមែនទេ ៣០០ម៉ែត្រ ហ្នឹងគឺមើលមិនច្បាស់ទេ?

**ឆ៖** បាទ ពិតមែន។

[១៥:៤៤:៥០]

**ស៖** គេបានអាននូវចម្លើយរបស់សាក្សី សេង ស្រ៊ុន ដែលបានផ្តល់សក្ខីកម្មមុនលោកបន្តិចនេះ ដែលគាត់បានពន្យល់ថា លោកហ្នឹងស្ថិតនៅក្នុងក្រុមដែលអ្នកចាប់ខ្លួនគាត់នៅឆ្នាំ៧៦ ហើយ សេង ស្រ៊ុន ហ្នឹងក៏បានឆ្លើយថា លោកហ្នឹងធ្វើជាឈ្លបរហូតទៅដល់ឆ្នាំ៧៩តែម្តង។ អ៊ីចឹង ខ្ញុំសូមអានសម្រង់ពីរនៃចម្លើយរបស់គាត់ ដែលវាខុសពីកំណត់ហេតុជាលាយលក្ខណ៍អក្សរ គឺគាត់ឆ្លើយនៅក្នុងសវនាការនេះតែម្តង ហើយខ្ញុំនឹងសួរសំណួរលោក។ សម្រង់ទី១ គឺនៅម៉ោង ០៣:៤០នាទី កាលពីម្សិលមិញ គាត់

និយាយអំពីការចាប់ខ្លួនគាត់នៅឆ្នាំ៧៦ គាត់ថា “សំរិត មុយ មកចាប់គាត់ ហើយគាត់មិនដឹងថា អ្នកណាបញ្ជាទេ គឺគាត់ -- សំរិត មុយ ហ្នឹងមកចាប់ខ្ញុំ ហើយខ្ញុំស្គាល់មនុស្សជាច្រើននៅក្នុងកងសន្តិសុខមាន ស្រេង, មាន មុយ ហើយមានអ្នកផ្សេងទៀត ដែលមកពីខាងសន្តិសុខ”។ សូមបញ្ចប់ការដកស្រង់។

សំណួរទី១ របស់ខ្ញុំ ខ្ញុំសួរលោកថា តើលោកពិតជាស្ថិតនៅក្នុងក្រុមកងសន្តិសុខ ឬក៏អត់? ហើយលោកពិតជាបានចាប់ សេង ស្រ៊ុន ឬក៏អត់ ព្រោះគាត់ឆ្លើយកាលពីម្សិលមិញថា លោកហ្នឹងហើយជាអ្នកចាប់គាត់នោះ?

**ឆ៖** បាទ ខ្ញុំបាទ ឆ្លើយរួចមកហើយ។ ក្នុងនាមខ្ញុំជាឈ្លប ជាកូនចៅគេ ខ្ញុំគ្មានតួនាទីអីទៅចាប់គាត់ ឬក៏មកបង្ខំគាត់ទេ។ រឿងដូចខ្ញុំបានជម្រាបហើយ ថារឿងដែលចាប់គាត់នេះ រឿងអីៗខ្ញុំអត់ដឹងទេ។ ដល់ពេលគេលែងទៅវិញ ដូចខ្ញុំបានជម្រាបហើយថា ខ្ញុំអត់ដឹងទេ។ បើគេលែង គេលែងទៅហើយ បានរស់ជីវិតទាល់សព្វថ្ងៃហ្នឹង។

**ស៖** សម្រង់ទី២ ដែលខ្ញុំចង់អានឲ្យលោកស្តាប់ គឺកាលពីម្សិលមិញដដែល សវនាការម៉ោង ១៥:៥៤:២៥វិនាទី នៅពេលហ្នឹងគេសួរគាត់ថា៖ “តាមរយៈចម្លើយរបស់លោកហ្នឹង គឺលោកបានឃើញ សំរិត មុយ ហ្នឹងធ្វើជាឈ្លបរហូតដល់ឆ្នាំ៧៩ មែនទេ?” ពេលនោះ គាត់ឆ្លើយថា៖ “បាទ គឺអ៊ីចឹងហើយ”។ ហើយបន្ទាប់មកទៀត គាត់បញ្ជាក់បន្ថែមទៀត គឺកាលពីម្សិលមិញដដែល គឺប្រហែលជាមុនម៉ោង ១៥:៥៤:២០វិនាទី គាត់និយាយអំពីលោក គាត់ឆ្លើយថា៖ “បើតាមខ្ញុំដឹង គាត់កាន់តំណែងតាំងពីឆ្នាំ៧៣ ដល់ឆ្នាំ៧៩ ហើយអ៊ីចឹងហើយបានជាក្រោយមកគាត់អត់ប៊ានរស់នៅក្នុងភូមិទេ គាត់រត់ទៅពួននៅចំការលើនោះ”។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកច្បាស់ទេ ថាលោកមិនបានកាន់តំណែងជាកងឈ្លបហ្នឹងរហូតដល់ឆ្នាំ៧៩ទេ? ហើយសំណួរបន្ទាប់មកទៀត គឺដូចដែល សេង ស្រ៊ុន និយាយដែរឬទេថា លោករត់គេចខ្លួន ពេលបែកខ្មែរក្រហម របបខ្មែរក្រហមនុ៎ងលោករត់គេចខ្លួនទៅពួននៅចំការលើ។ តើអ៊ីចឹងមែនទេ?

[១៥:៤៨:២២]

**ឆ៖** បាទ អរគុណណាស់លោកមេធាវី។ ខ្ញុំជម្រាបលោកឲ្យបានច្បាស់ ដូចខ្ញុំបានជម្រាបហើយថា ពី៧៣ មកដល់៧៥ ខ្ញុំជាឈ្លបភូមិ ពេលដែលគេត្រូវឲ្យទៅត្រៀមទៅអី គេរុញខ្ញុំឲ្យទៅត្រៀមប្រមូលគ្នាមក។ អត់ឈ្លបឃុំទេខ្ញុំ ហ្នឹងទី១ ខ្ញុំជម្រាប។ ហើយបញ្ហាទី២ លោក សេង ស្រ៊ុន ថាខ្ញុំសួរទៅដល់៧៩ ខ្ញុំសូមអះអាងថា ខ្ញុំសច្ចាប្រណិធានរួចហើយពី៧៧ ខ្ញុំលំបាកវេទនាណាស់ ដែលគេឲ្យមក

នៅក្នុងនេះវិញហ្នឹង ខ្ញុំ កន្ទក់ក៏ខ្ញុំហូបហើយ ស្អីក៏ខ្ញុំ -- ពិសេសទៀត គឺខ្ញុំតែម្តងជាមួយគាត់ហ្នឹង ៧៩ ដែលកំពុងនេះហ្នឹង ៧៨ ចិតអីទឹកលិចធំហ្នឹង។ ខ្ញុំហើយទៅចាក់ពស់ជាមួយគាត់ រឿងអីដែលខ្ញុំនៅឈ្លបដល់៧៩? សូមឲ្យលោកបញ្ជាក់ត្រង់ហ្នឹង ច្បាស់លាស់ឲ្យខ្ញុំ។

**ស៖** ខ្ញុំអានចម្លើយនេះឲ្យលោកស្តាប់ពីព្រោះថា លោក សេង ស្រ៊ុន នៅពេលដែលគេសួរគាត់ថារហូតដល់៧៩មែនទេ ដែលលោកធ្វើជាឈ្លបហ្នឹង គាត់បានឆ្លើយកាលពីម្សិលមិញហ្នឹងថ្ងៃទី១៤ កញ្ញា គឺមុនម៉ោង ១៥:៥៤:២៥វិនាទីបន្តិចនោះ គាត់ថា៖ "ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ ខ្ញុំមិនមែននិយាយដើម្បីចោទប្រកាន់អ្នកណា ឬក៏បរិហារកេរ្តិ៍អ្នកណាម្នាក់ទេ។ ខ្ញុំនិយាយក្នុងនាមជាសាក្សី ខ្ញុំនិយាយការពិតអំពីអ្វីដែលខ្ញុំឃើញផ្ទាល់ភ្នែក អ្វីដែលខ្ញុំដឹង។ ខ្ញុំរស់នៅសំបួរមាសហ្នឹង គឺតាំងពីខ្ញុំអាយុ១ឆ្នាំមក អ៊ីចឹងរស់នៅហ្នឹងរាប់ឆ្នាំមកហើយ អ៊ីចឹងខ្ញុំនិយាយតែពីអ្វីដែលខ្ញុំឃើញតែប៉ុណ្ណោះ ខ្ញុំនិយាយតែការពិតប៉ុណ្ណោះ។" អ៊ីចឹងបើតាមចម្លើយរបស់លោកហ្នឹង លោកថា សេង ស្រ៊ុន មិននិយាយការពិតទេ។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើហេតុអ្វីបានជាគាត់កុហកពាក់ព័ន្ធនឹងលោកនេះ? តើលោកធ្លាប់ឈ្លោះទាស់ទែងអីជាមួយគាត់ ឬក៏យ៉ាងម៉េច? លោកអាចពន្យល់បានទេ? ម៉េចក៏គាត់និយាយបរិហារលោកនេះ ហេតុអី? ហើយលោក លោកថាមិនពិតទេ លោកពន្យល់បានទេ?

[១៥:៥០:៥០]

**ឆ៖** បាទ អរគុណណាស់លោកមេធាវី។ រឿងពាក្យមួយគាត់ថាខ្ញុំធ្វើដល់៧៩ ហើយតាមលោកមានប្រសាសន៍អំមិញថា សេង ស្រ៊ុន ហ្នឹងមិនប៉ាននៅទេ រត់ទៅចម្ការកៅស៊ូ។ មិនមែនមិនប៉ានទេអស់លោក កាលទៅចម្ការនោះ កាលនោះខ្ញុំក៏សុំចុះឈ្មោះទៅដែរ ប៉ុន្តែគេមិនឲ្យទៅ ជម្រាបឲ្យត្រង់។ អ៊ីចឹង សេង ស្រ៊ុន នេះទៅនៅចម្ការនេះ គួរណាស់តែគាត់មកវិញហ្នឹង ៧៩ហ្នឹង គាត់ជាមួយខ្ញុំហ្នឹង ចែវទូកជាមួយគ្នា លំបាកវេទនានេះ ហើយម៉េចក៏ថាខ្ញុំនៅ៧៩។ ដូចខ្ញុំបានជម្រាបហើយថា ពី៧៧មកអ្នកដាវវែងចូលមក ខ្ញុំពី៧៧មក លំបាកប៉ិះតែស្លាប់ប៉ិះតែរស់ទៅហើយ រឿងអីខ្ញុំធ្វើដល់៧៩។ សូមលោកជ្រាប។

**ស៖** ខ្ញុំសួរដដែល តើមានហេតុអីក៏បានជា សេង ស្រ៊ុន គាត់មកកុហកនៅមុខតុលាការនេះ?

**ឆ៖** ដូចលោកបានជ្រាបហើយ ដូចគាត់បានឆ្លើយថា ខ្ញុំចាប់គាត់ទៅ ហើយខ្ញុំអ្នកឲ្យបាយគាត់ហូប ដល់រួចមកវិញក៏រស់មានជីវិតទាល់សព្វថ្ងៃ។ ត្រង់ហ្នឹងហើយដែលគេគំនុំខ្ញុំ ប៉ុន្តែគំនុំនេះគាត់រស់អស់លោក មិនមែនគាត់ស្លាប់ទេណា! ខ្ញុំអ្នកយកបាយទៅឲ្យហូប ឥឡូវគាត់រស់ជីវិតទាល់សព្វថ្ងៃ។

អ៊ីចឹងគាត់អត់ស្លាប់ទេ សូមលោកជ្រាប។

**ស៖** តាមរយៈចម្លើយរបស់លោក គឺតាំងពីឆ្នាំ៧៧មក គឺលោកលែងធ្វើជាឈ្លបហើយ ហើយលោកក៏លែងមានសិទ្ធិពិសេសអីដូចមុនដែរ។ ដូច្នេះខ្ញុំអាចយល់បានថា ក្រោយឆ្នាំ១៩៧៧ហ្នឹង លោកមិនធ្លាប់បានចូលរួមក្នុងការប្រជុំរបស់កងឈ្លប ឬក៏ការប្រជុំថ្នាក់ភូមិ ថ្នាក់ឃុំអីទៀត អ៊ីចឹងមែនទេ?

[១៥:៥៣:០២]

**ឆ៖** បាទ អត់ដែលមានទេលោក។

**ស៖** អម្បាញ់មិញនេះ ខ្ញុំអត់ទទួលបានការបកប្រែពីចម្លើយលោកទេ សូមលោកនិយាយម្ដងទៀតលោកសាក្សី?

**ឆ៖** បាទ បកប្រែយ៉ាងម៉េច ក៏សូមបញ្ជាក់មួយសាទៀតលោក។

**ស៖** អម្បាញ់មិញនេះ ខ្ញុំសួរលោកថាក្រោយឆ្នាំ៧៧មក លោកលែងចូលក្នុងកិច្ចប្រជុំ ឬក៏ក្នុងមីទ្ទិងអី នៅក្នុងកងឈ្លបភូមិ ឬក៏ឃុំអីទៀតហើយ មែនទេ?

**ឆ៖** បាទ គ្មានទេអស់លោក។

**ស៖** ដូច្នេះខ្ញុំអាចនិយាយបានទេថា លោកមិនបានចូលរួមប្រជុំអីទេ រវាងកងសន្តិសុខ ហើយនិងក្រុមដារ ហើយនិងមេឃុំ ឬក៏ប្រធានតំបន់អីនុ៎ង គឺលោកមិនធ្លាប់ចូលរួមប្រជុំបែបហ្នឹងទេ មែនទេ?

**ឆ៖** បាទ មែន។

**ស៖** ពីឆ្នាំ៧៧មក គឺលោកអ្នកធ្វើការធម្មតាដូចប្រជាជនដទៃ ហើយលោកអត់មានទទួលបានព័ត៌មានអីពាក់ព័ន្ធទៅនឹងខាងសន្តិសុខ ឬក៏ពីអ្នកដែលធ្វើការនៅថ្នាក់ឃុំ ឬថ្នាក់តំបន់អីទេ។ ខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៥:៥៥:០៤]

**ស៖** ចំណុចចុងក្រោយរបស់ខ្ញុំ គឺខ្ញុំចង់ឲ្យលោកបំភ្លឺពាក់ព័ន្ធនឹងចំណុចមួយ នៅពេលដែលលោកឆ្លើយទៅនឹងលោកប្រធាន លោកបានបញ្ជាក់ថាលោកបានជួបអ្នកស៊ើបអង្កេតពីរដង។ តើលោកឆ្លើយឲ្យបានច្បាស់បានទេថាការសម្ភាសពីរដងដែលលោកបានជួបជាមួយនឹងអ្នកស៊ើបអង្កេតហ្នឹងនៅពេលណាខ្លះ?

**ឆ៖** បាទ សម្ភាសទី១ ខ្ញុំភ្លេចថ្ងៃហើយ។ សម្ភាសទី១ ហ្នឹង គឺមានឯកសារ ចងក្រងឯកសារ។

ដល់ទៅទី២ នេះ គាត់គ្រាន់តែទៅសម្ភាសហើយគាត់ជម្រាបថា ខែ១០នេះ ឲ្យខ្ញុំអញ្ជើញមកសាលាក្ដីខ្មែរក្រហម គ្រាន់ប៉ុណ្ណឹង អស់លោកសូមជ្រាប។

**ស៖** ដូច្នេះ ការសម្ភាសទី២ហ្នឹង មិនមែនជាមួយអ្នកស៊ើបអង្កេតទេ គឺជាមួយខាងៗមន្ត្រីតុលាការដែលប្រាប់ឲ្យលោកមកផ្ដល់សក្ខីកម្មនៅក្នុងតុលាការនេះ គឺអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** សូមអរគុណចំពោះការឆ្លើយបញ្ជាក់នេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន ក៏ប៉ុន្តែលោកមេធាវី គង់ សំអុន គាត់នៅមានសំណួរទៀតលោក។

**ប្រធានអង្គជំនុំ៖**

បាទអញ្ជើញបាទ!

[១៥:៥៦:៤១]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំសូមតាំងសំណួរខ្លីទេទាក់ទងទៅនឹងពេលវេលាដែលលោកបញ្ជាក់អំពីការណ៍ដែលលោកឃើញគេបណ្ដើរជនជាតិចាម នៅពេលដែលលោកនៅរោងបាយនៅសហករណ៍។ មុននេះលោកបានបញ្ជាក់ពីម៉ោង ប៉ុន្តែខ្ញុំចង់សួរពីឆ្នាំ និងខែ ឬក៏ថ្ងៃបើលោកអាចចាំបាន ឆ្នាំណាពិតប្រាកដ។ លោកអាចឆ្លើយបានទេ?

**លោក សំរិត មុយ៖**

**ឆ៖** បាទ គ្រាន់ដឹងថាឆ្នាំ៧៧ បើរឿងសួរថាថ្ងៃ ថាខែ ពេលនោះ តែអាទិត្យ ចន្ទ ក៏អត់ដឹងថាថ្ងៃណា ថ្ងៃណីដែរលោក។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឯកសារ D166/26, ERN ជាភាសាខ្មែរលេខ 00235015 ជាភាសាអង់គ្លេស 00235508, ជាភាសាបារាំង 00283947 ដែលជាកំណត់ហេតុស្ដាប់ចម្លើយរបស់លោក។ លោកបានបញ្ជាក់នូវពីរចំណុច ទាក់ទងទៅនឹងឆ្នាំ ដែលលោកបានឃើញគេប្រមូលជនជាតិ

ចាមនេះគឺចុងឆ្នាំ៧៦ និងដើមឆ្នាំ៧៧។ អ៊ីចឹងពាក្យសម្ដីដែលលោកបានឆ្លើយអម្បាញ់មិញថាក្នុងឆ្នាំ៧៧ នេះ លោកច្បាស់នៅពេលវេលាណាមួយ នៃខែណាមួយច្បាស់លាស់ ឬមួយក៏លោកមិនមានភាពច្បាស់លាស់ទេថា ក្នុងឆ្នាំ ចុងឆ្នាំ៧៦ ឬអាចដើមឆ្នាំ៧៧។ មួយណាត្រឹមត្រូវ?

**ឆ៖** ៧៧ លោក ត្រឹមត្រូវ។

[១៥:៥៨:៥៤]

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ម្ដងទៀតបានទេថា លោកឃើញព្រឹត្តការណ៍ដែលគេចាប់ជនជាតិចាមហ្នឹងប៉ុន្មានដងដែរក្នុងឆ្នាំ៧៧ ឬក៏ក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលក្នុងពេលដែលលោកនៅសហករណ៍មូលដ្ឋានរបស់លោកនោះ?

**ឆ៖** បាទ ខ្ញុំបាទជម្រាបរួចហើយលោកមេធាវី ថាតាំងពីខ្ញុំរស់នៅជាមួយបងប្អូនអ៊ីស្លាម ថាមិនដែលបានលិខិតបងប្អូនអ៊ីស្លាមណាមួយ គេយកទៅណាមួយទេ អត់មានសោះ។ ទើបតែឆ្នាំ៧៧ហ្នឹងប្រមូលតែមួយថ្ងៃសម្រេចតែម្ដង។

**ស៖** បាទ សូមអរគុណ។ នេះជាចម្លើយមួយដែលលោកបានផ្ដល់ពីព្រឹកមិញដែរ នៅក្នុងប្រហែលជាម៉ោងដប់ព្រឹក ប៉ុន្តែនៅក្នុងឯកសារដដែល នៅក្នុងកថាខណ្ឌដដែលហ្នឹង គឺបន្ទាត់ចុងក្រោយមួយលោកបានបញ្ជាក់ថា ការសម្លាប់នេះ គឺមានជាបន្តបន្ទាប់រហូតដល់ឆ្នាំ១៩៧៩។ អ៊ីចឹងលោកបញ្ជាក់មើល ថាមួយណាត្រឹមត្រូវ? អ្វីដែលលោកទើបតែនិយាយអម្បាញ់មិញនេះត្រឹមត្រូវ ឬក៏អ្វីដែលមានសរសេរនៅក្នុងសក្ខីកម្មរបស់លោកហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទសូមជម្រាបលោកមេធាវី ដែលខ្ញុំបាទបានឆ្លើយថាក្រោយពីឆ្នាំ៧៧ មកដល់៧៩ បានបន្តរហូតសម្លាប់ហ្នឹង មិនមែនត្រឹមតែបងប្អូនអ៊ីស្លាមមួយទេអស់លោក និយាយពីប្រជាជនអ៊ីស្លាមចប់រួចស្រេចស្រួលបួល និយាយពីខ្មែរប៉ុនណាក៏មានដែរលោក។ មកខ្លះពោះធំ តូចតាមបណ្ដើរមកថ្ងៃណា ក៏ថ្ងៃសម្លាប់ដែរ។ បាទ ខ្ញុំសូមជម្រាបអ៊ីចឹង បានថា ដូចខ្ញុំបានជម្រាបរួចហើយថា ខ្ញុំមិនដែលប៊ានទៅក្បែរគេទេ ឲ្យស្គាល់គេ បានរឿងអី រឿងថាវារាល់ថ្ងៃតែម្ដង រឿងយកប្រជាពលរដ្ឋមកសម្លាប់ដោយគ្មានទោសកំហុសអីហ្នឹង។

**ស៖** បាទ អ៊ីចឹងលោកៗអាចឆ្លើយនឹងសំណួរខ្ញុំបានទេថា លោកសម្គាល់ឃើញការសម្លាប់ជនជាតិចាមហ្នឹងតែមួយថ្ងៃ តែមួយលើក មិនមែនបន្តបន្ទាប់ទេ ឬមួយក៏លោកឃើញបន្តបន្ទាប់ មានការសម្លាប់ជារៀងរាល់ថ្ងៃដែរ? សូមលោកឆ្លើយឲ្យខ្លី។

[១៦:០១:២៣]

**ឆ៖** បាទ ដូចខ្ញុំជម្រាបហើយថា ភូមិសាច់សូមួយ យកតែមួយពេលហ្នឹងមកតែម្តង។

**ស៖** បាទ សូមអរគុណ។ លោកមានដឹងថា មានការសម្លាប់ជនជាតិចាមនៅភូមិផ្សេងទេ ក្រៅពីភូមិសាច់សូហ្នឹង?

**ឆ៖** បាទ ខ្ញុំជម្រាបពេលនោះ អត់មានប៉ានទៅឆ្លងកាត់ទៅណាទេលោក ដឹងតែកន្លែងសាច់សូហ្នឹ សាច់សូហើយ អត់មានដើរហើរទៅណាបានទេ អត់មានសិទ្ធិទេ។

**ស៖** បាទ សូមអរគុណ។ ចុះម៉េចបានលោកដឹងថា ការសម្លាប់ជនជាតិចាមនៅក្នុងថ្ងៃតែមួយហ្នឹង យកពីភូមិសាច់សូហ្នឹងតែម្តង អស់ទាំងអស់គ្នា? លោកដឹងដោយរបៀបណា?

**ឆ៖** បាទ ដូចខ្ញុំបាទបានជម្រាបហើយលោកមេធាវី ព្រោះខ្ញុំនៅរោងបាយ បានថាខ្ញុំឃើញហ្នឹងបានថាមួយពេលហ្នឹង ព្រោះទាំងតូច ទាំងតាច ទាំងធំ ទាំងចាស់ ទាំងក្មេង គាត់ប្រមូលមកទាំងអស់។ បាទ គ្រាន់ឃើញ ខ្ញុំបាទគ្រាន់ជម្រាបអ៊ីចឹងថា ឃើញដែលខ្ញុំឃើញពីចម្ងាយហ្នឹង គឺអត់ប្រហែលគ្មាននៅទេអស់លោក ព្រោះទាំងតូច ទាំងតាច ទាំងចាស់ងងក់ អីម៉េច បណ្តើរមកអស់ហើយ។

[១៦:០២:៥១]

**ស៖** បាទ សូមអរគុណ។ លោកបញ្ជាក់ពីដើមមក លោកថាលោកឃើញមួយដង ហើយពេលហ្នឹង វារៀង អាចថាពេលញ៉ាំបាយ លោកមិនបានដឹងពីចំនួនជាក់លាក់ទេ ប៉ុន្តែចំណុចមួយ លោកបានឆ្លើយពីព្រឹកមិញ លោកថានៅភូមិសាច់សូហ្នឹង មានជនជាតិចាមច្រើនជាងខ្មែរបន្តិច។ តើលោកចាំចម្លើយរបស់លោកនេះទេ?

**ឆ៖** បាទ ខ្ញុំបាទចាំលោក ព្រោះអ៊ីចេះបានថានេះហ្នឹង បើនិយាយពីចាមច្រើនណាស់មួយភូមិសាច់សូហ្នឹង ហើយខ្មែរហ្នឹង ទៅលោកហ្នឹងមួយៗទេ អស់លោក--

**ស៖** បាទៗ សូមអរគុណ--

**ឆ៖** បាទ គេឲ្យទៅនៅសាច់សូហ្នឹង។

**ស៖** បាទ។ សំណួររបស់ខ្ញុំបន្ទាប់ទៀត ចំណុចនេះ គឺបើលោកអត់ៗបានរាប់ចំនួន អត់ដឹងចំនួនពីចំនួនជនជាតិចាមដែលត្រូវចាប់ពីឃុំសាច់សូផង តើធ្វើម៉េចបានលោកអាចដឹងពីថា គេចាប់ជនជាតិចាមទាំងអស់ពីភូមិសាច់សូក្នុងពេលតែមួយហ្នឹង មួយថ្ងៃហ្នឹង?

**ឆ៖** បាទ ព្រោះខ្ញុំបាទឃើញគេចាប់ហ្នឹងមក ភូមិសាច់សូអត់មានចាមនៅ។

**ស៖** ម៉េចលោកដឹងថាអត់មានចាមនៅ? លោកអាចបញ្ជាក់ពីចំណុចនេះបានទេ?

**ឆ៖** បាទ អរគុណណាស់ លោកមេធាវី ដែលលោកបានផ្តល់យោបល់សួរខ្ញុំម្តងហើយម្តងទៀត ខ្ញុំឆ្លើយដោយខ្លី។ រឿងប្រជាពលរដ្ឋដែលនៅក្នុងភូមិសាច់សូ បងប្អូនអ៊ីស្លាមគឺគេយកមកអស់ហើយរួចមួយ ខ្ញុំជម្រាបក្រោយមកទៀត ដែលខ្ញុំបានជួប ហ្នឹងទៅនៅរោងបាយជាមួយខ្ញុំឈ្មោះ ម៉ាន ពីរនាក់ប្តីប្រពន្ធរត់គេចចូលក្នុងបឹងអស់លោក។

[១៦:០៥:០៤]

**ស៖** បាទ បញ្ហានេះ ខ្ញុំមិនជំទាស់ទៅនឹងអង្គហេតុសក្ខីកម្មដែលលោកឆ្លើយមកទេ ប៉ុន្តែអ្វីដែលខ្ញុំមានការសង្ស័យ គឺទៅលើចំនួនជនជាតិចាមដែលត្រូវចាប់ម្តងអស់ពីភូមិ។ អ៊ីចឹងខ្ញុំចង់ឲ្យលោកបញ្ជាក់ពីព្រោះលោកថាលោកឃើញតែម្តង ហើយលោកអត់បានរាប់ចំនួន ហើយលោកដឹងថាមានប្រជាជនចាមហ្នឹងត្រូវគេចាប់អស់តែភូមិក្នុងពេលតែមួយ។ អ៊ីចឹងអ្វីដែលខ្ញុំចង់បាននោះថា តើវាជាព័ត៌មានដែលលោកទទួលជាផ្លូវការណាមួយក្នុងតួនាទីលោកជាអ្វីមួយដែលដឹងអំពីការចាប់ជនជាតិចាមនេះទាំងអស់ឬមួយក៏ជាសន្និដ្ឋានរបស់លោកថា ជនជាតិចាមនេះត្រូវគេចាប់អស់ពីភូមិ?

**ឆ៖** បាទ ដូចខ្ញុំបាទបានជម្រាបហើយថា បើគេប្រមូលអស់ហើយ អស់ចាមរលីងហើយ ឲ្យខ្ញុំឆ្លើយថាយ៉ាងម៉េចអស់លោក។

**ស៖** លោកមានទៅភូមិសាច់សូនោះទេ ក្រោយពីចាប់ចាមហ្នឹងភ្លាមៗ?

**ឆ៖** ខ្ញុំអត់បានទៅទេ អស់លោក។

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសវនាការថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-873 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

សវនាការស្តាប់សក្ខីកម្ម សំរិត មុយ បានដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោក

សំរិត មុយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេលមួយថ្ងៃកន្លងមកនេះ។ សក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ហើយវត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលលោមានបំណងចង់ទៅបានហើយ ហើយសូមលោកជួបតែសំណាងល្អ បានសេចក្តីសុខ សេចក្តីចម្រើន។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក សំរិត មុយ វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកមេធាវី ម៉ម រិទ្ធា ជាមេធាវីប្រឹក្សាសាក្សី។ ហើយលោកមេធាវី អាចសម្រាកបានហើយ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការ នៅថ្ងៃស្អែកវិញ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*